ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការអនុវត្ត
# គណនេយ្យភាពសង្គម
# សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
# នៅថ្នាក់ក្រោមជាតិ
# ឆ្នាំ ២០១៤-២០១៦

ថ្ងៃទី ២៤ ខែមិនា ឆ្នាំ២០១៤

# មាតិកា


**ផ្នែកទី ១ សេចក្តីផ្តើម** ........ 1

**ផ្នែកទី២ វិសាលភាពនិងខ្លឹមសារ** ........ 3

២.១. ការរៀបចំសមាសភាគនានាសម្រាប់ការអនុវត្ត ........ 3

២.២. វដ្តនៃការអនុវត្តសកម្មភាព ........ 4

២.៣ . ទំហំការងារ និងទីកន្លែងអនុវត្ត ........ 5

**សមាសភាគទី១ ភាពងាយទទួលបានព័ត៌មានស្តីពីស្តង់ដា ថវិកា និងការបំពេញមុខងារ** ........ 6

**អនុសមាសភាគទី១ក ព័ត៌មានពាក់ព័ន្ធការបំពេញការងារ និងលទ្ធផល** ........ 11

លទ្ធផល ១.១ ទិន្នន័យ ត្រូវបានប្រមូល ពិនិត្យ ផ្ទៀតផ្ទាត់ ដើម្បីចងក្រងព័តិមានសម្រាប់ប្រជាពលរដ្ឋ(I4Cs) 11

លទ្ធផល ១.២ កញ្ចប់ព័តិមានសម្រាប់ប្រជាពលរដ្ឋ (I4Cs) ត្រូវបានបោះពុម្ព និងផ្សព្វផ្សាយ ........ 12

**អនុសមាសភាគទី១ខ ការបើកចំហព័ត៌មានថវិកា** ........ 12

លទ្ធផល ១.៣ ព័តិមានអំពីថវិកាត្រូវបានប្រមូល ពិនិត្យឡើងវិញ និងចងក្រង ........ 12

លទ្ធផល ១.៤ ព័តិមានថវិកាដែលមានលក្ខណៈសាមញ្ញត្រូវបានបង្ហាញ និងបិទផ្សាយ ........ 13

**អនុសមាសភាគទី១គ ការរៀបចំប្រព័ន្ធ លិខិតបទដ្ឋាន និងការអនុវត្តតាមគោលការណ៍ណែនាំ** ........ 13

លទ្ធផល ១.៥ នីតិវិធីក្នុងការគ្រប់គ្រងទិន្នន័យនៅថ្នាក់ស្រុកត្រូវបានបង្កើត និងអនុវត្ត ........ 13

លទ្ធផល ១.៦ លិខិតបទដ្ឋាន និងសេចក្តីណែនាំនានាសម្រាប់ការបើកចំហព័តិមានថវិកា និងព័តិមាននានានៅមូលដ្ឋានត្រូវបានបង្កើត និងអនុវត្ត ........ 14

លទ្ធផល ១.៧ ប្រព័ន្ធត្រួតពិនិត្យ និងការអនុវត្តតាមគោលការណ៍ណែនាំ សម្រាប់ការបើកចំហព័តិមានថវិកានៅមូលដ្ឋាន ត្រូវបានបង្កើត និងបានអនុវត្ត ........ 14

លទ្ធផល ១.៨ ដំណើរការត្រួតពិនិត្យរបស់សង្គមស៊ីវិល ចំពោះការបើកចំហព័តិមានស្តីពីថវិកានៅមូលដ្ឋាន ត្រូវបានបង្កើត និងអនុវត្ត ........ 15

**អនុសមាសភាគទី១ឃ ការលើកកម្ពស់ការយល់ដឹងនិងការពង្រឹងសមត្ថភាព** ........ 15

លទ្ធផល១.៩៖ សមត្ថភាពអ្នកសម្របសម្រួលនៅសហគមន៍ត្រូវបានបណ្តុះបណ្តាលអំពីគណនេយ្យភាពសង្គម ព័តិមាននានា និងព័តិមានថវិកា ........ 15

លទ្ធផល ១.១០ សមាជិកក្រុមប្រឹក្សា មន្ត្រីមូលដ្ឋាននិងអ្នកផ្តល់សេវានៅមូលដ្ឋាននឹងបានទទួលការបណ្តុះបណ្តាលស្តីពីព័តិមាននានា និងព័តិមានថវិកា ........ 16

លទ្ធផល ១.១១ ការយល់ដឹងរបស់អង្គការសហគមន៍មូលដ្ឋាន សហគមន៍នានា និងប្រជាពលរដ្ឋទាក់ទងនឹងព័តិមាន និងថវិកាត្រូវបានលើកកម្ពស់ ........ 16

សមាសភាគទី ២ ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ ........ 19

អនុសមាសភាគ ទី២ក ការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ ........ 22

លទ្ធផល ២.១ ការដាក់ពិន្ទុលើការផ្តល់សេវាតាមវិស័យនានានៅសហគមន៍ត្រូវអនុវត្តប្រចាំឆ្នាំនៅក្នុងស្រុកគោលដៅនីមួយៗ ........ 22

លទ្ធផល ២.២ ផ្អែកតាមតម្រូវការរបស់សហគមន៍ បង្កើតឱ្យមានការត្រួតពិនិត្យតាមដានស៊ីជម្រៅ ដោយប្រជាពលរដ្ឋ ចំពោះសេវាកម្មមូលដ្ឋាននិងបញ្ហាជាក់លាក់មួយចំនួន ........ 23

អនុសមាសភាគទី២ខ កិច្ចប្រជុំរួមគ្នា និងផែនការសកម្មភាពរួមគ្នា ........ 23

លទ្ធផល ២.៣ កិច្ចប្រជុំរួមគ្នាត្រូវបានដំណើរការ ហើយផ.ស.គ.រ ត្រូវបានរៀបចំ ........ 25

លទ្ធផល ២.៤ ផែនការសកម្មភាព ផ.ស.គ.រ ត្រូវបានផ្សព្វផ្សាយ និងអនុវត្ត ........ 26

លទ្ធផល ២.៥ គណៈកម្មការតាមដាន ត្រូវបានបង្កើតដើម្បីត្រួតពិនិត្យការអនុវត្ត“ផ.ស.គ.រ” ........ 26

អនុសមាសភាគទី២គ ការរៀបចំលិខិតបទដ្ឋាននានាដើម្បីគាំទ្រការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងការពិនិត្យមើលពីលើរបស់សមាជិកក្រុមប្រឹក្សា ........ 27

លទ្ធផល២.៦ ប្រកាស និងសេចក្តីណែនាំស្តីពីតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ ត្រូវបានតាក់តែង អនុម័ត និងអនុវត្ត ........ 27

លទ្ធផល២.៧ ក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តិសម្រាប់ការត្រួតពិនិត្យរបស់ឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ លើការផ្តល់សេវាមូលដ្ឋាន ត្រូវបានកែសម្រួល ........ 27

អនុសមាសភាគទី២ឃ ការលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាព ........ 28

លទ្ធផល ២.៨ កម្មវិធីបណ្តុះបណ្តាល ការផ្តល់យោបល់ណែនាំ និងការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ត្រូវបានអនុវត្ត ........ 28

លទ្ធផល ២.៩ ការលើកកម្ពស់ការយល់ដឹង អំពីការងារត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ និងការរៀបចំ ផ.ស.គ.រ សម្រាប់អង្គការសហគមន៍មូលដ្ឋាន សហគមន៍និងប្រជាពលរដ្ឋ ........ 28

លទ្ធផល ២.១០ ការបណ្តុះបណ្តាល អំពីការរៀបចំផ.ស.គ.រ ការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងមុខងារត្រួតពិនិត្យមើលពីលើ នឹងរៀបចំធ្វើឡើងសម្រាប់មន្ត្រីមូលដ្ឋាន និងអ្នកផ្តល់សេវាមូលដ្ឋាន ..... 29

សមាសភាគទី៣ ការសម្របសម្រួល និងការពង្រឹងសមត្ថភាព ........ 31

អនុសមាសភាគទី៣ក ការសម្របសម្រួល ........ 33

លទ្ធផល ៣.១ អង្គការមិនមែនរដ្ឋាភិបាលជាដៃគូនៅមូលដ្ឋាន ដែលគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពនៅមូលដ្ឋានត្រូវបានជ្រើសរើស និងចុះកិច្ចសន្យា ........ 33

លទ្ធផល ៣.២ ដៃគូអង្គការសហគមន៍មូលដ្ឋានជាយុទ្ធសាស្ត្រ (ដោយផ្តោតលើ អ្នកតំណាងជាស្ត្រី និងយុវវ័យ) ត្រូវបានជ្រើសរើស ........ 34

លទ្ធផល ៣.៣ អ្នកសម្របសម្រួលគណនេយ្យភាពនៅសហគមន៍ (ដោយផ្តោតលើស្ត្រី និងយុវវ័យ) ត្រូវបានជ្រើសរើស និងចងក្រងជាក្រុម ..... 34
លទ្ធផល ៣.៤ សហគមន៍អនុវត្ត ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការគាំទ្រជាប្រចាំ ដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ..... 35
**អនុសមាសភាគ៣ខ ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន និងពង្រឹងសមត្ថភាព** ..... 36
លទ្ធផល ៣.៥ ដៃគូជំនាញបណ្តុះបណ្តាលស្តីពីគណនេយ្យភាពសង្គមត្រូវបានជ្រើសរើស ..... 36
លទ្ធផល ៣.៦ កម្មវិធីបណ្តុះបណ្តាល សម្ភារៈ និងវិធីសាស្ត្រ ត្រូវបានបង្កើតឡើង សម្រាប់ទាំងផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ ..... 36
លទ្ធផល ៣.៧ ការពង្រឹងសមត្ថភាពដល់ដៃគូអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ និងមូលដ្ឋានឱ្យក្លាយជាគ្រូបង្គោល ..... 37
លទ្ធផល ៣.៨ ការបណ្តុះបណ្តាលមន្ត្រីថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក ឱ្យក្លាយជាគ្រូបង្គោល ..... 38
**សមាសភាគទី ៤ ការប្រមូលមេរៀនបទពិសោធន៍ និងការត្រួតពិនិត្យតាមដាន** ..... 40
**សមាសភាគ ៤ក ការប្រមូលមេរៀនបទពិសោធន៍ និងការផ្តល់យោបល់ត្រឡប់** ..... 41
លទ្ធផល ៤.១ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ក្នុងការប្រមូលមេរៀនបទពិសោធន៍ ដែលមានលក្ខណៈច្នៃប្រឌិតត្រូវបានបង្កើតឡើង ..... 41
លទ្ធផល ៤.២ ឧបករណ៍ និងឯកសារណែនាំនានាត្រូវបានរៀបចំ និងផ្សព្វផ្សាយ ..... 41
លទ្ធផល ៤.៤ ការផ្តល់យោបល់ត្រឡប់ និងដំណើរការពិនិត្យកែសម្រួលគោលនយបាយ ដើម្បីលើកកម្ពស់ការអនុវត្ត ផ.អ.គ.ស ត្រូវបានបង្កើត ..... 41
លទ្ធផល ៤.៥ ការសិក្សាជាក់លាក់ត្រូវបានរៀបចំដោយដៃគូជំនាញលើការសិក្សារៀនសូត្រ ដើម្បីគាំទ្រដល់ការអភិវឌ្ឍគោលនយោបាយ និងការអនុវត្ត ផ.អ.គ.ស ..... 42
**សមាសភាគ ៤ខ ការត្រួតពិនិត្យតាមដាន និងលទ្ធផល** ..... 43
លទ្ធផល ៤.៦ ការត្រួតពិនិត្យតាមដានលើលទ្ធផលត្រូវបានរៀបចំឡើងស្របតាមក្របខ័ណ្ឌការងារដែលបានព្រមព្រៀង ..... 43
លទ្ធផល ៤.៧ ការវាយតម្លៃលើផលប៉ះពាល់ត្រូវបានអនុវត្ត ..... 44
លទ្ធផល ៤.៨ ដំណើរការចងក្រងជាឯកសារ និងសវនកម្មត្រូវបានរៀបចំអនុវត្ត ..... 44
**ផ្នែកទី៣ ការរៀបចំស្ថាប័ន** ..... 46
៣.១. ការរៀបចំស្ថាប័នទូទៅ ..... 46
៣.២ ការទទួលខុសត្រូវរបស់អង្គភាពរដ្ឋ ..... 47
៣.៣ ការទទួលខុសត្រូវរបស់សង្គមស៊ីវិល ..... 49

**ផ្នែកទី៤ ការចាប់ផ្តើមអនុវត្តគម្រោង** ........ 55
៤.១ ការចាប់ផ្តើម ........ 55
៤.២ ក្របខ័ណ្ឌពេលវេលាសម្រាប់អនុវត្ត ........ 56
**ផ្នែកទី ៥ សង្ខេបការផ្តល់ហិរញ្ញវត្ថុ និងថវិកា** ........ 57
៥.១. ការចំណាយ ........ 57
**ផ្នែកទី ៦ ការគ្រប់គ្រងហានិភ័យ** ........ 64
៦.១. ហានិភ័យនិងវិធានការកាត់បន្ថយ ........ 64
**ផ្នែកទី ៧ លទ្ធផលរំពឹងទុកពីការអនុវត្ត** ........ 66
៧.១. គោលបំណង និងសូចនាកររួម ........ 67
៧.២ សមាសភាគគោលបំណង និងសូចនាករ ........ 67

# ផ្នែកទី ១

# សេចក្តីផ្តើម

ផែនការអនុវត្តការងារគណនេយ្យភាពសង្គម(ផ.អ.គ.ស) បង្ហាញអំពី វិសាលភាព ខ្លឹមសារ និងអភិក្រម សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម (ផ.យ.គ.ស) ដែលបានពិភាក្សាយោបល់ជាមួយ តំណាងសង្គមស៊ីវិល និងបានអនុម័តដោយគ.ជ.អ.ប នៅថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៣។

ជាទិដ្ឋភាពរួមផ.អ.គ.ស មានបង្ហាញអំពីសកម្មភាព និងការរៀបចំនានាដែលអនុវត្តដោយរាជរដ្ឋាភិបាល (ផ្នែកផ្គត់ផ្គង់) និងសង្គមស៊ីវិល (ផ្នែកតម្រូវការ)។ ឯកសារនេះចែកចេញជា៧ផ្នែករួមមានវិសាលភាពនិងខ្លឹមសារ នៃសមាសភាគនានា ការរៀបចំស្ថាប័ន ថវិកា និងការផ្តល់ហិរញ្ញប្បទាន លទ្ធផលរំពឹងទុក និងហានិភ័យដែល អាចកើតឡើង។

គណនេយ្យភាពសង្គម គឺជាដំណើរការនៃការផ្សារភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើរ រវាងប្រជាពលរដ្ឋ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយវាក៏ជាមធ្យោបាយមួយដែលបន្សុីគ្នារវាងគោលការណ៍ទាំងឡាយ នៃអភិបាលកិច្ច ដែលក្នុងនោះរាល់ការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសកម្មភាពជាសាធារណៈនានា របស់រដ្ឋបាលថ្នាក់ ក្រោមជាតិ ត្រូវបានប្រកាន់យកតាមកិច្ចដំណើរការនេះ។ កិច្ចសហការរវាងរដ្ឋបាលមូលដ្ឋាន អ្នកផ្តល់សេវា និង ប្រជាពលរដ្ឋ (អ្នកប្រើប្រាស់សេវា) សំដៅគាំទ្រដល់អ្នកផ្តល់សេវាសាធារណៈឲ្យបំពេញការងាររបស់ខ្លួនបាន ប្រសើរជាងមុន។ បទពិសោធន៍កន្លងមកបានបង្ហាញថា ឧបករណ៍គណនេយ្យភាពសង្គមនានា (ដូចជាប័ណ្ណដាក់ ពិន្ទុសហគមន៍) ជួយជំរុញឲ្យមានការគោរពគ្នា និងការចូលរួមរវាងប្រជាពលរដ្ឋ និងរដ្ឋបាលមូលដ្ឋាន។

ផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម បានដាក់ចេញនូវយុទ្ធសាស្ត្រចំនួន៥ ដើម្បីសម្រេចបាន នូវគោលបំណងរួម ក្នុងការពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ និងពង្រឹងគណនេយ្យភាពសង្គមនៅកម្ពុជា។ យុទ្ធសាស្ត្រទាំងប្រាំនៃផ.យ.គ.ស ត្រូវបានរៀបចំទៅជាសមាសភាគចំនួន៤ នៅក្នុងផ.អ.គ.ស ដើម្បីជំរុញការ អនុវត្តប្រកបដោយប្រសិទ្ធភាព ដូចមានបង្ហាញខាងក្រោម៖

| ផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម | សមាសភាគនៃផែនការអនុវត្ត |
|---|---|
| ១. ការលើកកម្ពស់តម្លាភាព និងភាពងាយទទួលបាននូវព័ត៌មានស្តីពីស្តង់ដា ថវិកា និងការបំពេញមុខងារ | **សមាសភាគទី១**<br>ភាពងាយទទួលបានព័ត៌មានស្តីពីស្តង់ដា ថវិកា និងការបំពេញមុខងារ |
| ២. ការសម្របសម្រួលឲ្យមានការត្រួតពិនិត្យ តាមដានរបស់ប្រជាពលរដ្ឋលើសកម្មភាព និងការផ្តល់សេវាកម្មមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ ក្រោមជាតិ | **សមាសភាគទី២**<br>ការសម្របសម្រួលឲ្យមានការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ |
| ៣ .ការលើកកម្ពស់សមត្ថភាពយល់ដឹងរបស់ប្រជាពលរដ្ឋអំពីថវិកា | បញ្ចូលទៅក្នុងសមាសភាគទី១<br>ភាពងាយទទួលបានព័ត៌មានស្តីពីស្តង់ដា ថវិកា និងការបំពេញមុខងារ |
| ៤ .ការគាំទ្រដល់តួអង្គនានា និងការកសាងសមត្ថភាពដល់តួអង្គទាំងនោះ ដើម្បីសម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋ និងកិច្ចដំណើរការនានានៃគណនេយ្យភាពសង្គម | **សមាសភាគទី៣**<br>ការសម្របសម្រួល និងការពង្រឹងសមត្ថភាព |

| ផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម | សមាសភាគនៃផែនការអនុវត្ត |
| --- | --- |
| ៥ .ការប្រមូលមេរៀនបទពិសោធន៍ដែលបានមកពីអន្តរាគមន៍នានានៅមូលដ្ឋាន ដើម្បីប្រែក្លាយបទពិសោធន៍ទាំងនេះដាក់បញ្ចូលទៅក្នុងគោលនយោបាយរបស់ រាជរដ្ឋាភិបាល និងពង្រឹងការបំពេញការងារអង្គការសង្គមស៊ីវិលនានា | **សមាសភាគទី៤**<br>ការប្រមូលមេរៀនបទពិសោធន៍និងការត្រួតពិនិត្យតាមដាន |

# ផ្នែកទី២
# វិសាលភាពនិងខ្លឹមសារ

## ២.១. ការរៀបចំសមាសភាគនានាសម្រាប់ការអនុវត្ត

ផ.អ.គ.ស ចែកចេញជា៤សមាសភាគ រួមមាន (១) ភាពងាយទទួលបានព័ត៌មានស្តីពីស្តង់ដា ថវិកា និងការបំពេញមុខងារ (២) ការសម្របសម្រួលឲ្យមានការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ (៣) ការសម្របសម្រួលនិងការពង្រឹងសមត្ថភាព និង(៤)ការប្រមូលមេរៀនបទពិសោធន៍និងការត្រួតពិនិត្យតាមដាន។ សមាសភាគទាំង៤ មានទំនាក់ទំនងនិងបំពេញគ្នាទៅវិញទៅមក ដែលសមាសភាគនីមួយៗ មានការចូលរួមអនុវត្តដោយតួអង្គទាំងពីរ (រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមប្រជាពលរដ្ឋ)។ សមាសភាគទាំង៤ មានពន្យល់លម្អិតដូចខាងក្រោម៖

**១) ភាពងាយទទួលបានព័ត៌មានស្តីពីស្តង់ដារ ថវិកា និងការបំពេញមុខងារ** មានគោលបំណងពង្រឹងភាពងាយស្រួលក្នុងការទទួលបានព័ត៌មានសាធារណៈរបស់ប្រជាពលរដ្ឋ (រួមមានព័ត៌មានសាមញ្ញៗពាក់ព័ន្ធនឹងថវិកា) និងបង្កើនសមត្ថភាពរបស់ប្រជាពលរដ្ឋ ឲ្យបានយល់ដឹងនិងប្រើប្រាស់ព័ត៌មានទាំងនោះ។ សមាសភាពនេះ គឺសំដៅពង្រឹងសមត្ថភាពរបស់តួអង្គទាំងពីរ ពាក់ព័ន្ធនឹងព័ត៌មាន សាធារណៈ។

**២) ការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ** មានគោលបំណងឲ្យប្រជាពលរដ្ឋ អាចធ្វើការត្រួតពិនិត្យវាយតម្លៃដោយឯករាជ្យលើការផ្តល់សេវាសាធារណៈ ការបំពេញការងាររបស់រដ្ឋបាល និងវិភាគលើព័ត៌មានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ លទ្ធផលនៃការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋនឹងចែករំលែកជាមួយអង្គភាពពាក់ព័ន្ធនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រើប្រាស់សម្រាប់រៀបចំផែនការសកម្មភាពរួមគ្នាស្តីពីគណនេយ្យភាពសង្គម តាមរយៈកិច្ចប្រជុំរួម។ កិច្ចប្រជុំរួម ដើម្បីរៀបចំផែនការសកម្មភាពរួមគ្នានេះ នឹងធានាឲ្យមានសកម្មភាពត្រួតពិនិត្យតាមដានរបស់ភាគីពាក់ព័ន្ធទាំងអស់ ព្រមទាំងបញ្ចូលសកម្មភាពទាំងនោះទៅក្នុងដំណើរការកសាងផែនការ និងការធ្វើសេចក្តីសម្រេចនានានៅថ្នាក់ឃុំ។

**៣) ការសម្របសម្រួល និងការពង្រឹងសមត្ថភាព** មានគោលបំណង ផ្តល់ការបណ្តុះបណ្តាល ផ្តល់ការប្រឹក្សាយោបល់ និងផ្តល់ការហ្វឹកហ្វឺននានា ដល់អ្នកសម្របសម្រួលនៅតាមសហគមន៍ អង្គការសង្គមស៊ីវិល បុគ្គលិក សមាជិកក្រុមប្រឹក្សាឃុំ ស្រុក និងដល់អ្នកផ្តល់សេវាសាធារណៈនៅមូលដ្ឋាន។ ការសម្របសម្រួល និងការពង្រឹងសមត្ថភាពសំដៅគាំទ្រដល់សកម្មភាពសំខាន់ៗពីរ គឺការពង្រឹងសមត្ថភាព និងការធានានូវនិរន្តរភាពរបស់សកម្មភាពនានា ។

**៤) ការប្រមូលមេរៀនបទពិសោធន៍ និងការត្រួតពិនិត្យតាមដាន** មានគោលបំណងបង្កើតឲ្យមានយន្តការ និងទម្លាប់រៀនបណ្តើរអនុវត្តបណ្តើរ ។ លទ្ធផលនៃការត្រួតពិនិត្យតាមដានដែលរកឃើញនៅសហគមន៍ នឹងក្លាយជាធាតុចូល សម្រាប់អភិវឌ្ឍសមត្ថភាព និងកែលំអការអនុវត្តការងារជាក់ស្តែង។

**រូបភាព ២.១**

**វដ្តនៃគណនេយ្យភាពសង្គម**




## ២.២. វដ្តនៃការអនុវត្តសកម្មភាព

សកម្មភាពគណនេយ្យភាពសង្គម នឹងត្រូវអនុវត្តតាមរយៈវដ្តនៃសកម្មភាព រួមមាន ការចែករំលែកព័ត៌មាន និងការពង្រឹងការយល់ដឹងពីថវិកា ការអនុវត្តគណនេយ្យភាពសង្គម (ដូចជា ការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ) ការសម្របសម្រួល ការពង្រឹងសមត្ថភាព ការសិក្សារៀនសូត្រ និងការត្រួតពិនិត្យ។ល។

ការកំណត់ពេលវេលាសម្រាប់សកម្មភាពនានានៅក្នុងសមាសភាគនីមួយៗ មានសារៈសំខាន់ណាស់ ដើម្បីឲ្យសកម្មភាពទាំងនោះ ដើរស្របគ្នាជាមួយពេលវេលានៃដំណើរការដែលមានស្រាប់។ ដើម្បីទទួលបានអត្ថប្រយោជន៍ជាអតិបរមា សកម្មភាពទាំងឡាយត្រូវបញ្ចូលនូវការពង្រឹងសមត្ថភាពការផ្តល់យោបល់ត្រឡប់ និងផ្តល់ជាទុនចូលរួមទៅក្នុងប្រព័ន្ធអភិបាលកិច្ចនានានៅមូលដ្ឋាន។

## ២.៣. ទំហំការងារ និងទីកន្លែងអនុវត្ត

ក្នុងរយៈពេលពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៦ សកម្មភាពគណនេយ្យភាពសង្គម ដែលពិពណ៌នានៅក្នុងផែនការនេះ នឹងត្រូវអនុវត្តប្រហែល១២០ស្រុក។ វិសាលភាពនៃការអនុវត្តមានដូចខាងក្រោមៈ

- **នៅដំណាក់កាលដំបូងនៃការអនុវត្ត កិច្ចការនេះនឹងផ្តោតនៅតាមតំបន់ជនបទ** រីឯតំបន់ទីប្រជុំជន (សង្កាត់ ខណ្ឌ និងក្រុង) នឹងត្រូវអនុវត្តនៅដំណាក់កាលដាក់ឲ្យប្រើប្រាស់បន្ទាប់[1]។
- **គ្រប់ឃុំទាំងអស់ដែលស្ថិតក្នុងស្រុកគោលដៅ នឹងត្រូវអនុវត្តសកម្មភាពគណនេយ្យភាពសង្គម** ដែលមានសកម្មភាពជាច្រើននឹងត្រូវអនុវត្តនៅតាមភូមិ សាលារៀន និងមណ្ឌលសុខភាព ប៉ុន្តែត្រូវចាត់ទុកថាជាក្របខណ្ឌថ្នាក់ស្រុក។
- បើទោះបីជាសកម្មភាព ផ.អ.គ.ស ត្រូវបានផ្តោតនៅថ្នាក់មូលដ្ឋានក៏ដោយ **ថ្នាក់ខេត្តក៏មានសារៈសំខាន់ផងដែរក្នុងដំណើរការអនុវត្ត** ដូច្នេះថ្នាក់ខេត្តមានតួនាទីសំខាន់ក្នុងការសម្របសម្រួល និងទំនាក់ទំនងជាមួយស្ថាប័ន អង្គភាពសំខាន់ៗ។
- **ចៀសវាងការលើកសកម្មភាពជាន់គ្នាឬបង្កការយល់ច្រឡំចំពោះអ្នកពាក់ព័ន្ធនៅមូលដ្ឋាន** ស្រុកដែលមានសកម្មភាពផ្សេងៗទៀតកំពុងអនុវត្ត អាចសម្រេចជ្រើសរើសចូលរួមក្នុងការអនុវត្ត ផ.អ.គ.ស ក្នុងអំឡុងឆ្នាំ២០១៤-២០១៧ ឬក៏អាចរង់ចាំអនុវត្តនៅឆ្នាំ២០១៧ ឬនៅពេលការអនុវត្តសាកល្បងបានបញ្ចប់។ មួយវិញទៀត អង្គការមិនមែនរដ្ឋាភិបាលមួយ នឹងមិនទទួលបានឱកាសសម្រាប់ការអនុវត្តជម្រើស២ផ្សេងគ្នាទេ។
- **គណនេយ្យភាពនៅតាមតំបន់ទីប្រជុំជនៈ** គេត្រូវធ្វើការវិភាគដើម្បីស្វែងយល់ពីបរិបទផ្សេងៗគ្នានៃតំបន់ទីប្រជុំជន (ខណ្ឌ សង្កាត់)។ បញ្ហានេះ នឹងមានពិភាក្សាលម្អិតនៅក្នុងសមាសភាគទី៤ នៅឆ្នាំ២០១៤។

ការជ្រើសរើសស្រុកគោលដៅ ត្រូវផ្អែកលើតំបន់គោលដៅរបស់អង្គការមិនមែនរដ្ឋាភិបាលដៃគូដែលកំពុងបំពេញការងារ។ ផ.អ.គ.ស នឹងមិនបង្កើតនូវរចនាសម្ព័ន្ធពីរស្របគ្នា ឬគម្រោងដាច់ដោយឡែកនោះទេ (សូមពិនិត្យមើលផ្នែកទី៥)។ ការជ្រើសរើសស្រុកណាមួយផ្សេងពីតំបន់គោលដៅដែលមានស្រាប់ គឺមានការលំបាក។ សម្រាប់ដំណាក់កាលដំបូងនៃការសាកល្បង នឹងអនុវត្តនៅក្នុងស្រុកដែលអង្គការដៃគូកំពុងធ្វើសកម្មភាព ដែលបានជ្រើសរើសក្រុមគោលដៅរួចហើយ។

[1] តម្រូវការនៃគណនេយ្យភាពសង្គមនៅតំបន់ជនបទ និងទីប្រជុំជនអាចមានលក្ខណៈខុសគ្នា។

# សមាសភាគទី១
# ភាពងាយទទួលបានព័ត៌មានស្តីពីស្តង់ដា ថវិកា និងការបំពេញមុខងារ

តម្លាភាព ភាពងាយទទួលបានព័ត៌មានស្តីពីស្តង់ដា ថវិកា និងការបំពេញមុខងារ គឺជាសមាសធាតុដ៏សំខាន់នៃដំណើរការប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម។ ប្រសិនបើពុំមានព័ត៌មានអំពីស្តង់ដារនៃសេវាកម្ម ប្រជាពលរដ្ឋមិនអាចដឹងបានថា តើមានសេវាកម្មអ្វីខ្លះដែលត្រូវផ្តល់ ឬថាតើពួកគាត់អាចស្នើសុំអ្វីខ្លះអំពីសេវាកម្មនានា ដែលទាក់ទងនឹងសុខភាព សាលារៀន ឬសេវាកម្មនានាពីរដ្ឋបាលមូលដ្ឋាន។ នៅពេលដែលអ្នកពាក់ព័ន្ធទាំងអស់ បានធ្វើការចែករំលែកព័ត៌មានគ្នាទៅវិញទៅមក ពួកគេនឹងយល់គ្នា ទំនាក់ទំនងគ្នា និងធ្វើសកម្មភាពរួមគ្នាកាន់តែល្អប្រសើរ។ ការពិភាក្សារវាងតួអង្គទាំងពីរ ដោយផ្អែកលើព័ត៌មាន និងបទពិសោធន៍ជាក់ស្តែង ដែលនាំទៅដល់ការកែលំអកាន់តែល្អប្រសើរថែមទៀត។ ផ្ទុយទៅវិញ ប្រសិនបើប្រជាពលរដ្ឋ មិនបានទទួលព័ត៌មានដែលមានភាពសុក្រឹត្យ មិនមានលក្ខណៈជាប្រព័ន្ធ និងមិនទាន់ពេលវេលានោះទេ ពួកគាត់ក៏មិនអាចចូលរួមក្នុងដំណើរការគណនេយ្យភាពសង្គមប្រកបដោយប្រសិទ្ធភាព បានដែរ។ នៅពេលដែលប្រជាពលរដ្ឋមិនអាចទទួលបានព័ត៌មាន និងពុំមានឥទ្ធិពលទៅលើការធ្វើសេចក្តីសម្រេចចិត្ត នឹងធ្វើឲ្យពួកគាត់មិនសូវមានការទាមទារចង់ដឹងអំពីព័ត៌មាននានាឡើយ។

**ពាក់ព័ន្ធនឹងសារៈសំខាន់នៃព័ត៌មានអំពីថវិកានិងការចំណាយ** តាមការស្រាវជ្រាវបង្ហាញថានៅកម្ពុជា ទាំងតម្លាភាពផ្នែកហិរញ្ញវត្ថុសាធារណៈ រួមទាំងការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីបញ្ហាហិរញ្ញវត្ថុសាធារណៈ នៅមានកម្រិតនៅឡើយ។ ការអង្កេតស្តីពី"ការបើកចំហផ្នែកថវិកា"[2]បានបង្ហាញថាប្រទេសកម្ពុជាស្ថិតនៅចំណាត់ថ្នាក់ទាបជាងគេ ក្នុងចំណោមបណ្តាប្រទេសដែលបានអង្កេត ។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) បានជម្រុញមានការបើកចំហព័ត៌មានស្តីពីថវិកាមូលនិធិឃុំសង្កាត់ និងលើកស្ទួយតម្លាភាពក្នុងការប្រើប្រាស់ថវិកាទាំងនោះ ប៉ុន្តែការសិក្សាអង្កេតនាពេលថ្មីៗ បានរកឃើញថាមានប្រជាពលរដ្ឋចំនួនតិចតួចប៉ុណ្ណោះដែលចង់ដឹងព័ត៌មានពាក់ព័ន្ធនឹងថវិកា ហើយតម្លាភាពនៃការប្រើប្រាស់ថវិកាហាក់នៅមានកម្រិតនៅឡើយ។

**<u>ការបរិយាយអំពីសមាសភាគ</u>**

**ដូចបានរៀបរាប់នៅក្នុងយុទ្ធសាស្រ្តទី១ និងទី៣ នៃផែនការយុទ្ធសាស្រ្តស្តីពីគណនេយ្យភាពសង្គម សមាសភាគនេះ ជួយពង្រឹងតម្លាភាព ភាពងាយទទួលបានព័ត៌មាន តម្រូវការព័ត៌មាននានា និងព័ត៌មានថវិកាសម្រាប់សាធារណជន។** សមាសភាគនេះរួមមាន ការរៀបចំព័ត៌មាន ការធ្វើឲ្យព័ត៌មានងាយស្រួលយល់ និងការផ្សព្វផ្សាយព័ត៌មាន ព្រមទាំងពង្រឹងការយល់ដឹងអំពីថវិកា។ ការធ្វើបែបនេះដើម្បី (១) ពង្រឹងការផ្តល់ និងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈនៅថ្នាក់មូលដ្ឋាន (រួមទាំងព័ត៌មានពាក់ព័ន្ធនឹងថវិកា) (២) ធ្វើឲ្យកាន់តែមានភាពងាយស្រួលក្នុងការទទួលបានព័ត៌មាន និង(៣) ពង្រឹងសមត្ថភាពរបស់ប្រជាពលរដ្ឋក្នុងការស្វែងយល់អំពីព័ត៌មានដែលបានផ្តល់ឲ្យ។ ការផ្តល់ព័ត៌មានឲ្យកាន់តែប្រសើរ និងការបង្កើនការយល់ដឹងអំពីព័ត៌មាន នឹងជួយសម្រួលដល់ការពិភាក្សារកដំណោះស្រាយកែលំអការផ្តល់សេវានៅមូលដ្ឋាន។

[2] ការអង្កេតស្តីពីព័ត៌មានថវិកា ឆ្នាំ២០១០

**តើព័ត៌មានអំពីអ្វី?** ដើម្បីឲ្យការចូលរួមមានប្រសិទ្ធិភាព ប្រជាពលរដ្ឋត្រូវការព័ត៌មានស្តីពីគោលនយោបាយ និង ដំណើរការរបស់រដ្ឋបាល អំពីស្តង់ដារសេវា និងអភិបាលកិច្ច ថវិកា និងការចំណាយប្រចាំឆ្នាំ អំពីតំបន់គោលដៅ សម្រាប់ផ្តល់សេវា និងការបំពេញការងារដែលសម្រេចបានជាក់ស្តែង។ ព័ត៌មានទាំងនេះ គួរផ្តោតលើវិស័យជា អាទិភាពរបស់ប្រជាពលរដ្ឋ (ដូចជា បញ្ហាសុខភាព ការសិក្សាអប់រំ បញ្ហាអនាម័យ និងទឹកស្អាត ការគ្រប់គ្រង ធនធានធម្មជាតិ និងសេវាកម្មនានារបស់ឃុំ)។ ព័ត៌មានទាំងនេះ ចែកចេញជាពីរប្រភេទ៖ ព័ត៌មានដែលត្រូវកែ សម្រួលជារៀងរាល់ឆ្នាំ (ដូចជា ព័ត៌មាននៃការបំពេញការងារ) និងព័ត៌មានដែលត្រូវកែសម្រួលតែនៅពេលមាន ការផ្លាស់ប្តូរណាមួយ (ដូចជាគោលនយោបាយ)។ ព័ត៌មានទាំងនេះរួម មាន៖

- **ព័ត៌មានស្តីពីគោលនយោបាយ និងនីតិវិធី៖** ការធ្វើឲ្យគោលនយោបាយ ច្បាប់ ផែនការ និងនីតិវិធីសំខាន់ៗ របស់រដ្ឋាភិបាលមានលក្ខណៈសាមញ្ញងាយយល់ ជួយឲ្យប្រជាពលរដ្ឋយល់ដឹងអំពីបរិបទនៃកិច្ចអភិវឌ្ឍ។ ក្នុងន័យនេះ ពួកគាត់នឹងយល់ថាតើ ការងារទាំងនោះដំណើរការដូចម្តេច តើ សេចក្តីសម្រេចនានាត្រូវ បានធ្វើដូចម្តេចខ្លះ? ត្រង់នេះ ព័ត៌មានដែលត្រូវចែកចាយរួមមាន ឯកសារគោលនយោបាយដែលងាយ ស្រួលយល់ (ឧទាហរណ៍ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ វិធានផ្ទៃក្នុង ក្រមសីលធម៌) និងនីតិវិធីនានារបស់ស្ថាប័នសាធារណៈនៅមូលដ្ឋាន និងការផ្តល់សេវានានា (ឧទាហរណ៍ តើថវិកាត្រូវបានគ្រប់គ្រងចាត់ចែងដូចម្តេច?)។ ប្រជាពលរដ្ឋក៏ត្រូវដឹងពីវិធីក្នុងការទំនាក់ ទំនងជាមួយស្ថាប័នទាំងនោះ (ដូចជា ត្រូវទាក់ទងជាមួយអ្នកណា ត្រូវទៅទទួលព័ត៌មាននៅកន្លែងណា និង ត្រូវធ្វើការប្តឹងផ្តល់ដោយរបៀបណា។ឧទាហរណ៍ នៅតាមសាលារៀន ឬមណ្ឌលសុខភាព គេអាច បញ្ចូលនូវតារាងកម្រៃសេវាដែលត្រូវបង់ តើមានសេវាណាខ្លះដែលមិនត្រូវបង់ថ្លៃ ពេលម៉ោងបំពេញ ការងារ និងក្រមសីលធម៌របស់បុគ្គលិកជាដើម។ នៅថ្នាក់ឃុំ គេអាចបញ្ចូលព័ត៌មានស្តីពីដំណើរការប្រើ ប្រាស់មូលនិធិឃុំ សង្កាត់ (ដូចជា ការដេញថ្លៃ និងការអនុវត្ត គម្រោង)។ ព័ត៌មានប្រភេទនេះធ្លាប់បានផ្តល់ រួចមកហើយដោយគ.ជ.អ.ប ក្រសួងមហាផ្ទៃ និងក្រសួងជំនាញផ្សេងៗទៀត[3] នៅតាមតំបន់មួយចំនួន ។

- **ព័ត៌មានស្តីពីស្តង់ដារ និងសិទ្ធិក្នុងការទទួលបានសេវា៖** ព័ត៌មានទាំងនេះ នឹងជួយឲ្យប្រជាពលរដ្ឋបានដឹង ពីសិទ្ធិតាមផ្លូវច្បាប់របស់ពួកគាត់។ សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានសេវាសំខាន់ៗនៅ មូលដ្ឋាន ត្រូវបានកំណត់នៅក្នុងគោលនយោបាយ និងច្បាប់នានា ដែលបានផ្សព្វផ្សាយដោយក្រសួងជំនាញ ឧទាហរណ៍៖ គោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលសាលារៀនត្រូវបង្ហាញនូវស្តង់ដារ ដូចជាសមាមាត្ររវាងចំនួនសិស្សធៀបនឹងគ្រូម្នាក់។ គោលនយោបាយក្រសួងសុខាភិបាល ស្តីពីការថែទាំ សុខភាពបឋម ដូចជា ការតម្រូវឲ្យមានគិលានុបដ្ឋាយិកាដែលមានការបណ្តុះបណ្តាលត្រឹមត្រូវឬមានថ្នាំ គ្រប់គ្រាន់។ ក្រសួងមហាផ្ទៃក៏មានគោលការណ៍ណែនាំក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន ការណែនាំអំពីការ គ្រប់គ្រង និងប្រើប្រាស់មូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក។

- **ព័ត៌មានពាក់ព័ន្ធថវិកា និងការចំណាយថវិកានានា៖** ប្រជាពលរដ្ឋ គួរដឹងពីចំនួន និងប្រភពនៃថវិកា។ បច្ចុប្បន្ននេះ ព័ត៌មានថវិកាដែលមាន ដូចជាថវិកាសម្រាប់រដ្ឋបាលឃុំ សម្រាប់សាលារៀន មួយចំនួន បានបិទផ្សាយរួចហើយនៅតាមជញ្ជាំងការិយាល័យ សម្រាប់សាធារណជនអាចមើលបាន។ ដោយឡែក

[3] ឧទាហរណ៍ ក្រមសីលធម៌របស់បុគ្គលិក និងព័ត៌មានស្តីពីការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយ ប្រព័ន្ធដោះស្រាយបណ្តឹងតវ៉ានៃក្រុម ការងារគណនេយ្យភាព។

មណ្ឌលសុខភាពភាគច្រើនមិនបានដឹងពីចំនួនថវិកាសរុបរបស់គេទេរហូតដល់ដំណាច់ឆ្នាំ (តែពួកគេក៏អាចយោងចំនួនថវិកាសម្រាប់ឆ្នាំមុនៗមកធ្វើជាមូលដ្ឋានក្នុងការបិទផ្សាយបានដែរ)។ ព័ត៌មានទាំងនេះត្រូវមានការចងក្រងបូកសរុប និងបង្ហាញតាមទម្រង់មួយសម្រាប់ប្រជាពលរដ្ឋស្វែងយល។ ព័ត៌មានថវិកានេះ ត្រូវស៊ីគ្នាជាមួយព័ត៌មាននៃការចំណាយនៅដំណាច់ឆ្នាំនីមួយៗ។

- **ព័ត៌មានស្តីពីគោលដៅអនុវត្តៈ** គោលដៅនានា (ដូចជា គោលដៅអភិវឌ្ឍសហសវត្សរបស់កម្ពុជា ឬគោលដៅកម្មវិធីនានារបស់ក្រសួង) ត្រូវបានកំណត់ឡើងដើម្បីផ្ទៀងផ្ទាត់ និងកែលំអនូវការបំពេញការងារ។ ការតាមដានលទ្ធផលនៃការបំពេញការងារធៀបនឹងគោលដៅកំណត់ នឹងជួយឲ្យរដ្ឋាភិបាល អាចដឹងថាតើ នៅថ្នាក់មូលដ្ឋានបានបំពេញការងារយ៉ាងដូចម្តេច។ ព័ត៌មានទាំងនេះមានបង្ហាញជាសាធារណៈមួយចំនួនរួចហើយ ប៉ុន្តែមិនបានផ្សព្វផ្សាយឲ្យបានទូលំទូលាយនៅតាមមូលដ្ឋាននៅឡើយ។ ឧទាហរណ៍ៈ
  - នៅតាមសាលាបឋមសិក្សាៈ គោលដៅនៃលទ្ធផលសំខាន់ៗរួមមាន អត្រាចុះឈ្មោះចូលរៀនដំបូង (៩៦%) ការចុះឈ្មោះនៅកម្រិតការអប់រំកុមារតូចនៅអាយុ៥ឆ្នាំ (៥០%) សមាមាត្រសិស្សានុសិស្សក្នុងគ្រូ១នាក់ (សិស្ស៤៥នាក់) អត្រាប្រលងជាប់ពីថ្នាក់ទី១ដល់ទី៦ (៧៥%)។
  - ផ្នែកសុខភាពៈ គោលដៅសម្រាប់ឆ្នាំ២០១៧ រួមមានការផ្តល់វ៉ាក់សាំងការពារ (សម្រាប់ក្មេងទទួលវ៉ាក់សាំងបង្ការ៣ដងDPT) ៧០% អត្រានៃការពិនិត្យសុខភាពមុនពេលសម្រាល (មកពិនិត្យបាន ២ដង) ៩៥% ការផ្តល់សេវាសុខភាព ៩០% អត្រាស្លាប់នៅក្រោមអាយុ៥ឆ្នាំ (៧០%)។
  - នៅតាមឃុំៈ មានការបង្កើតឡើងនូវស្តង់ដារនៃសេវាសម្រាប់ការចុះបញ្ជីកំណើត និងចុះបញ្ជីមរណភាព។
- **ព័ត៌មានស្តីពីការបំពេញការងារ និងលទ្ធផលដែលសម្រេចបានៈ** ប្រជាពលរដ្ឋ ត្រូវការព័ត៌មានស្តីពីការបំពេញការងារ និងលទ្ធផលរបស់ភ្នាក់ងារផ្តល់សេវា ដូចជាសាលារៀន មណ្ឌល សុខភាព និងរដ្ឋបាលស្រុក ឃុំ។ "កម្រងព័ត៌មានឃុំ" ដែលមាននៅក្នុងទិន្នន័យមូលដ្ឋានរបស់ឃុំ[4] ធ្លាប់បានយកមកចងក្រងរួចហើយដែរ។ សកម្មភាពផ.អ.គ.ស នឹងជំរុញការចងក្រង និងការផ្សព្វផ្សាយ ព័ត៌មានពាក់ព័ន្ធសូចនាករបំពេញការងារសំខាន់ៗមួយចំនួនជាមុន។ ព័ត៌មានពាក់ព័ន្ធការបំពេញការងារ និងលទ្ធផលមាន ដូចជាៈ
  ១. អត្រាចុះឈ្មោះចូលរៀននៅមុនអាយុកំណត់សម្រាប់កុមារ
  ២. អត្រាចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សា
  ៣. អត្រាសិស្សានុសិស្សរៀនដល់ថ្នាក់ទី៦
  ៤. ចំនួនសិស្សក្នុងគ្រូ១នាក់
  ៥. ចំនួនផ្តល់វ៉ាក់សាំងបង្ការ (កុមារទទួលវ៉ាក់សាំងបង្ការ ៣ដង DPT)
  ៦. អត្រាត្រួតពិនិត្យសុខភាពមុនពេលសម្រាល (មកពិនិត្យ ២ដង)
  ៧. អត្រាផ្តល់សេវាសុខភាព (ទាំងរដ្ឋ និងឯកជន)
  ៨. ចំនួនកុមារស្លាប់ក្រោមអាយុ៥ឆ្នាំ
  ៩. ភាគរយនៃការចុះបញ្ជីកំណើត ធៀបនឹងគោលដៅគ្រោង

[4] គេរំពឹងថារដ្ឋបាលស្រុកនឹងចូលរួមនៅក្នុងឆ្នាំទី២ ឬទី៣នៅពេលដែលមូលនិធិស្រុកដំណើរការ។ រដ្ឋបាលស្រុកមានតួនាទីចងក្រងព័ត៌មាននានា និងព័ត៌មានថវិកា និងកសាងសមត្ថភាពដូចបានកំនត់នៅក្នុងសមាសភាគទី៣។

១០. ភាគរយនៃការចុះបញ្ជីមរណភាព ធៀបនឹងគោលដៅគ្រោង
១១. សូចនាករនៃការអនុវត្តរបស់ឃុំ (ឧទាហរណ៍ ចំនួនគម្រោងមូលនិធិឃុំ សង្កាត់)
១២. សូចនាករផ្នែកសេដ្ឋកិច្ច សង្គម[5]។

ឧបករណ៍ចំបងសម្រាប់ការផ្តល់ព័ត៌មាន "ស្នូល" ដល់ប្រជាពលរដ្ឋនៅក្នុងដំណាក់កាលទី១ ហៅថា "កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ" (ឬI4Cs)។ ដើម្បីចាប់ផ្តើមការចែករំលែក និងការពិភាក្សាព័ត៌មាននៅថ្នាក់មូលដ្ឋាន កញ្ចប់ព័ត៌មានស្នូលទាក់ទងនឹងការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្តល់សេវានៅមូលដ្ឋាន នឹងត្រូវបានប្រមូលចងក្រង[6] ជាកញ្ចប់ព័ត៌មានដែលហៅថា "កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ" (ឬ I4Cs)។ កញ្ចប់ព័ត៌មានI4Cs នឹងធ្វើឡើងដោយថ្នាក់ស្រុក បន្ទាប់មកបែងចែកទៅឲ្យឃុំ អ្នកផ្តល់សេវានៅមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូសម្រាប់ផ្សព្វផ្សាយ និងបែងចែកបន្ត[7]។ កញ្ចប់ព័ត៌មាននេះរៀបចំឡើងដើម្បីឆ្លើយតបនឹងតម្រូវការផ្សេងៗរបស់អ្នកពាក់ព័ន្ធនានា រួមមានស្ត្រី យុវវ័យ និងប្រជាពលរដ្ឋក្រីក្រ។ ក្រោយពេលរៀបចំចងក្រងកញ្ចប់ព័ត៌មាននេះ នឹងកំនត់អំពីអ្វីដែលរដ្ឋាភិបាលបាលកំណត់ថាជាកិច្ចការដែលត្រូវធ្វើ (ស្របតាមស្តង់ដារ និងគោលដៅ) អំពីអ្វីដែលរដ្ឋាភិបាលធ្វើជាក់ស្តែង (សូចនាករបំពេញការងារ) ព្រមទាំងអំពីប្រភពមូលនិធិ (ទាំងថវិកា និងការចំណាយ)។

នៅថ្នាក់មូលដ្ឋាន អ្នកពាក់ព័ន្ធសំខាន់ៗ ត្រូវបានលើកទឹកចិត្តឲ្យបំពេញព័ត៌មានបន្ថែមពាក់ព័ន្ធនឹងស្រុក ឬឃុំជាក់លាក់ណាមួយទៅលើកញ្ចប់ព័ត៌មានI4Cs។ ព័ត៌មានបន្ថែមនោះអាចជាព័ត៌មានពាក់ព័ន្ធធនធានធម្មជាតិក្នុងមូលដ្ឋាន ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជាដើម ឬបន្ថែមព័ត៌មានអ្វីដែលគិតថាចាំបាច់សម្រាប់សហគមន៍។ អាចបន្ថែមព័ត៌មានស្តីពីសុខភាព ឬការសិក្សាអប់រំ (ដូចជាថ្នាក់អប់រំក្រៅប្រព័ន្ធ) ឬ សូចនាករ ទាក់ទងនឹងហានិភ័យណាមួយនៅមូលដ្ឋាននោះ។ ព័ត៌មានដែលប្រមូលបានពីប័ណ្ណផ្តល់ពិន្ទុសហគមន៍ (មានរៀបចំនៅក្នុងសមាសភាគទី២នៃ ផ.អ.គ.ស) នឹងបង្ហាញពីកម្រិតនៃការពេញចិត្តរបស់ប្រជាពលរដ្ឋទៅលើការបំពេញការងារ និងដំណើរការពាក់ព័ន្ធនានា។ ក្នុងករណីខ្លះ អង្គការមិនមែនរដ្ឋាភិបាលក៏អាចទទួលបានព័ត៌មាន លម្អិតពីវិស័យផ្សេងៗ ហើយកែសម្រួលព័ត៌មានទាំងនោះឲ្យកាន់តែងាយស្រួលសម្រាប់ប្រជាពលរដ្ឋ[8]។ ទម្រង់សម្រាប់ការផ្តល់ព័ត៌មានបន្ថែម ត្រូវដូចគ្នានឹងទម្រង់ព័ត៌មានស្នូលខាងលើដែរ ឬក៏អាចជាទម្រង់ជាក់លាក់ទៅតាមគោលបំណងនីមួយៗ តែចំណុចសំខាន់ គឺត្រូវធ្វើយ៉ាងណាឲ្យព័ត៌មាននោះងាយទទួលបាន។

តាមរយៈកញ្ចប់ព័ត៌មានI4Cs ប្រជាជននឹងទទួលបានព័ត៌មាន ដើម្បីប្រៀបធៀបលទ្ធផលការងាររវាងភាគីពាក់ព័ន្ធនានា។ ការប្រៀបធៀបខាងក្រោម ត្រូវបានលើកឡើងនៅក្នុងដំណាក់កាលទីមួយនៃ ផ.អ.គ.ស ហើយរបៀបអនុវត្តការងារនឹងត្រូវរៀបចំឡើងនៅក្នុងដំណាក់កាលចាប់ផ្តើម៖

---

[5] នឹងមានការពិភាក្សា និងព្រមព្រៀងគ្នាក្នុងពេលរៀបចំទម្រង់ I4Cs។
[6] បញ្ហានេះ គួរធ្វើឲ្យបានឆាប់ តើអ្នកណានឹងទទួលខុសត្រូវសម្រាប់ការប្រមូលព័ត៌មាននេះ។
[7] កញ្ចប់ព័ត៌មាននេះរំពឹងថាអាចធ្វើទៅបាន ដោយសារវាតិចជាងរបាយការណ៍ផ្ទៃក្នុងរដ្ឋបាល។
[8] ក្នុងរយៈពេលវែង អង្គការមិនមែនរដ្ឋាភិបាល អាចទទួលបានទិន្នន័យកាន់តែលម្អិតជាងនេះ ព្រមទាំងធ្វើការវិភាគលើទិន្នន័យទាំងនោះ។ ក្នុងពេលនេះ I4Cs គួរបញ្ចូលនូវព័ត៌មានដែលមានលក្ខណៈឯករាជ្យដែលផ្តល់ដោយភាគីទីបី (ដូចជាលទ្ធផលនៃការធ្វើសវនកម្ម)។

- ការប្រៀបធៀបលទ្ធផលជាក់ស្តែង ជាមួយនឹងលទ្ធផល និងដំណើរការរំពឹងទុក រួមទាំងការប្រៀបធៀបគោលដៅ ស្តង់ដារ តម្រូវការនានា ផែនការ និងការប្រៀបធៀបថវិកាជាមួយការអនុវត្តជាក់ស្តែង និងការចំណាយ
- ធ្វើការប្រៀបធៀបអំពីការផ្លាស់ប្តូរនានា និងនិន្នាការប្រែប្រួលតាមពេលវេលា
- ធ្វើការប្រៀបធៀបលទ្ធផលនានារបស់អង្គភាពប្រហាក់ប្រហែលគ្នា។ ព័ត៌មានដែលទទួលបាននឹងជួយឲ្យប្រជាពលរដ្ឋធ្វើការប្រៀបធៀបលទ្ធផលការងាររបស់សាលារៀន សេវាសុខភាព រដ្ឋបាលឃុំ និងស្រុក។ ជាដំបូង ការងារនេះនឹងត្រូវធ្វើនៅថ្នាក់ស្រុក[9]។

"កញ្ចប់ព័ត៌មានI4Cs" ជាយន្តការទំនាក់ទំនងរវាងរដ្ឋបាលមូលដ្ឋានជាមួយប្រជាពលរដ្ឋ។ ព័ត៌មាននេះជួយប្រជាពលរដ្ឋឲ្យយល់ដឹងអំពីដំណើរការនានា សិទ្ធិ និងការបំពេញការងារ។ កញ្ចប់ព័ត៌មានI4Cs រួមមានព័ត៌មានស្តីពីសេវានៅមូលដ្ឋាននិងសកម្មភាពកាត់បន្ថយភាពក្រីក្រ។ កញ្ចប់ព័ត៌មានI4Cs នឹងបង្ហាញព័ត៌មានងាយស្រួលសម្រាប់ប្រជាពលរដ្ឋស្វែងយល់ ចូលរួមចំណែកកែលំអការបំពេញការងារ និងការផ្តល់សេវាកម្ម។

**ទម្រង់ និងខ្លឹមសារព័ត៌មាន៖ ភាពសាមញ្ញ និងងាយយល់គឺជាកត្តាសំខាន់។** ព័ត៌មានត្រូវផ្តល់ដល់ប្រជាពលរដ្ឋក្នុងទម្រង់សាមញ្ញ មានក្រាហ្វិក ងាយស្រួលយល់ និងប្រើប្រាស់។ គំរូនៃទម្រង់ព័ត៌មានត្រូវធ្វើសាកល្បង និងផ្តល់ទៅឲ្យឃុំ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋានសម្រាប់ប្រើប្រាស់។ ព័ត៌មាននេះនឹងត្រូវចងក្រង និងបង្ហាញជាទម្រង់ងាយស្រួលព្រីន ថតចម្លងជាផ្ទាំងធំៗ ជាខិតប័ណ្ណ ឬតាមមធ្យោបាយទំនាក់ទំនងផ្សេងៗ។ គំរូព័ត៌មាននេះ នឹងត្រូវធ្វើការសាកល្បងដើម្បីឲ្យប្រាកដថាមានផ្ទុកនូវខ្លឹមសារដែលចាំបាច់ងាយស្រួលយល់ និងត្រូវពាក់ព័ន្ធជាមួយក្រុមប្រជាពលរដ្ឋដូចជាស្ត្រី យុវវ័យ និងប្រជាពលរដ្ឋក្រីក្រ[10]។

ការរៀបចំកញ្ចប់ព័ត៌មានI4Cs និងការផ្តល់ព័ត៌មានពីរាជរដ្ឋាភិបាល នឹងធានាបាននូវគោលការណ៍បើកចំហ។ គ.ជ.អ.ប នឹងរៀបចំគោលការណ៍ណែនាំ ដែលធានាឲ្យមានការផ្តល់ព័ត៌មានប្រចាំឆ្នាំ ដែលមានភាពត្រឹមត្រូវពិតប្រាកដ មានបិទផ្សាយជាសាធារណៈ អាចរកបាន និងទទួលបានដោយប្រជាពលរដ្ឋ។ គ.ជ.អ.ប នឹងពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ឲ្យបានយល់ដឹង ព្រមទាំងទាមទារឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានការបើកចំហនូវព័ត៌មានទាំងនេះ ហើយត្រូវដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។ ការជំរុញការអនុវត្ត និងការធ្វើអធិការកិច្ច នឹងធានាថាគោលការណ៍ណែនាំទាំងនោះ ត្រូវបានត្រួតពិនិត្យតាមដាន និងអនុវត្តព្រមគ្នា។

**តាមរយៈយុទ្ធនាការបង្កើនការយល់ដឹង ការពង្រឹងសមត្ថភាព និងការខិតខំប្រឹងប្រែងស្វែងយល់អំពីថវិកាប្រជាពលរដ្ឋ អង្គការសហគមន៍មូលដ្ឋាន នឹងបានយល់ដឹង និងប្រើប្រាស់ពីកញ្ចប់ព័ត៌មាន I4Csបានល្អប្រសើរ។** កិច្ចការសំខាន់មួយ គឺធ្វើយ៉ាងណាឲ្យព័ត៌មាននេះបានទៅដល់តំបន់គោលដៅ មានន័យថាត្រូវផ្តល់កញ្ចប់ព័ត៌មាន I4Cs ទៅឲ្យដល់ប្រជាពលរដ្ឋ មិនមែនរង់ចាំប្រជាពលរដ្ឋមកកាន់ការិយាល័យរដ្ឋបាលដើម្បីសុំព័ត៌មាននោះទេ។ ការប្រជុំពិភាក្សាលើកញ្ចប់ព័ត៌មានI4Cs នឹងត្រូវរៀបចំឡើង។ យុទ្ធនាការបង្កើនការយល់ដឹងនៅតាម

[9] ព័ត៌មានដែលទទួលបាននេះនឹងអនុញ្ញាតឲ្យមានការប្រៀបធៀបជាមួយចំនួនមធ្យមទូទាំងប្រទេស ក៏ដូចជាអនុញ្ញាតឲ្យមានការកំណត់ចំណាត់ថ្នាក់អង្គភាពផ្តល់សេវាផ្សេងៗ។

[10] ទោះបីព័ត៌មានមានចំនួនកើនឡើងសម្រាប់សាធារណៈជន និងតាមបណ្តាញអ៊ិនធឺណែត ភាគច្រើននៃព័ត៌មានទាំងនេះរៀបចំសម្រាប់ប្រើប្រាស់ដោយអ្នកជំនាញបច្ចេកទេសនិងអ្នកអាជីពតាមវិស័យនានានៅថ្នាក់ជាតិ។ដូច្នេះត្រូវផ្តល់នូវភាពងាយស្រួលក្នុងការទទួលព័ត៌មានទៅដល់ប្រជាពលរដ្ឋ។ នៅមានភាពមិនច្បាស់លាស់ចំពោះប្រភពថវិកាគាំទ្រនានា និងការរៀបចំរបាយការណ៍។

សហគមន៍ ការអភិវឌ្ឍសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន និងការបណ្តុះបណ្តាល អ្នកសម្របសម្រួលគណនេយ្យភាពនៅតាមសហគមន៍" នៅគ្រប់ឃុំ នឹងជួយជំរុញឲ្យមានការចាប់អារម្មណ៍ និងការទាមទារចង់បានកញ្ចប់ព័ត៌មានI4Cs។ ការបង្កើនចំណេះដឹងពីថវិកា និងការយល់ដឹងពីការគ្រប់គ្រងចាត់ចែងហិរញ្ញវត្ថុ គឺជាសមាសធាតុដ៏សំខាន់ក្នុងការបង្កើនការយល់ដឹងលើបញ្ហានេះ។ ដូច្នេះចាំបាច់ត្រូវមានការបណ្តុះបណ្តាល និងហ្វឹកហ្វឺន ដើម្បីឲ្យប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការទទួលបានព័ត៌មានសាធារណៈ។ ត្រូវមានការយកចិត្តទុកដាក់ជាពិសេសលើក្រុមគោលដៅជា ស្ត្រីនិងយុវវ័យ ដោយសារក្រុមនេះ គឺជាក្រុមគន្លឹះដែលអាចធ្វើឱ្យមានផ្លាស់ប្តូរជាចម្បងនៅកម្រិតសហគមន៍។

ទាំងរដ្ឋាភិបាលនិងសង្គមស៊ីវិល មានការទទួលខុសត្រូវធ្វើឲ្យមានការផ្លាស់ប្តូរនានា។ រដ្ឋាភិបាល[11] មានតួនាទី៖ (១)ប្រមូលទិន្នន័យ (២) រៀបចំកញ្ចប់ព័ត៌មានI4Cs និង(៣)បិទផ្សាយព័ត៌មានសំខាន់ៗនៅតាមទីកន្លែងមានលក្ខណៈងាយស្រួលមើល។ អង្គការសង្គមស៊ីវិលនឹងជួយរដ្ឋាភិបាលក្នុងការ (៤)ផ្សព្វផ្សាយកញ្ចប់ ព័ត៌មាន I4Cs (នៅថ្នាក់ឃុំនិងភូមិ) (៥)ធ្វើបច្ចុប្បន្នភាពទិន្នន័យកញ្ចប់ព័ត៌មានI4Cs នៅថ្នាក់មូលដ្ឋាន និង(៦) ពង្រឹងការយល់ដឹងរបស់ប្រជាពលរដ្ឋ និងការទាមទារនូវព័ត៌មាន។

សមាសភាគទី១ នេះនឹងត្រូវរៀបចំទៅជា អនុសមាសភាគទី១ក ទី១ខ ទី១គ និងទី១ឃ ដែលអាចសម្រេចបានតាមរយៈលទ្ធផលរំពឹងទុកចំនួន១១ជាបន្តបន្ទាប់ដូចខាងក្រោម៖

## អនុសមាសភាគទី១ក ព័ត៌មានពាក់ព័ន្ធការបំពេញការងារ និងលទ្ធផល

**អនុសមាសភាគនេះធ្វើការប្រមូល ពិនិត្យឡើងវិញ និងរៀបចំព័ត៌មានពាក់ព័ន្ធនឹងគោលនយោបាយ ស្តង់ដារ គោលដៅ ថវិកា និងការបំពេញការងារ ដើម្បីដាក់បញ្ចូលទៅក្នុងកញ្ចប់ព័ត៌មានI4Cs។** ព័ត៌មានដែលត្រូវប្រមូល រួមមានការផ្តល់សេវារបស់រដ្ឋបាលឃុំ ស្រុក សេវាសុខភាព និងអប់រំ។ ព័ត៌មានទាំងនោះ នឹងប្រមូលពីសាលារៀន មណ្ឌលសុខភាព រដ្ឋបាលឃុំ ស្រុក និងបូកសរុបនៅថ្នាក់ស្រុក។ នៅក្នុងដំណាក់កាលដំបូងនេះ ក្រុមរៀបចំតាក់តែង ផ.អ.គ.ស នឹងធ្វើការជាមួយលេខាធិការដ្ឋានគ.ជ.អ.ប និងមន្ទីរជំនាញផ្សេងៗ ដើម្បីពិនិត្យព័ត៌មានដែលមានស្រាប់ និងបន្ថែមព័ត៌មានចាំបាច់មួយចំនួន ព្រមទាំងរៀបចំគោលការណ៍ណែនាំខ្លីៗ ដែលពន្យល់អំពីដំណើរការប្រមូលព័ត៌មាន (ឧទាហរណ៍ នរណាជាអ្នកទទួលខុសត្រូវជាក់លាក់ក្នុងការប្រមូលព័ត៌មាន? តើមន្ត្រីនៅថ្នាក់ស្រុកត្រូវប្រមូលព័ត៌មានសម្រាប់ប្រជាពលរដ្ឋ(I4Cs) ប្រចាំឆ្នាំដែរឬទេ? តើចាំបាច់ត្រូវបង្កើតឲ្យ មានគណៈកម្មការរួមគ្នានៅថ្នាក់ស្រុកដែរឬទេ? សម្រាប់ធ្វើការត្រួតពិនិត្យលើការប្រមូលព័ត៌មាន និងផ្សព្វផ្សាយព័ត៌មានជាសាធារណៈ)។

### លទ្ធផល ១.១ ទិន្នន័យ ត្រូវបានប្រមូល ពិនិត្យ ផ្ទៀតផ្ទាត់ ដើម្បីចងក្រងព័ត៌មានសម្រាប់ប្រជាពលរដ្ឋ(I4Cs)

លទ្ធផលរំពឹងទុកនេះ គឺជាការប្រមូល ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ និងរៀបចំឲ្យបានត្រឹមត្រូវនូវព័ត៌មានពាក់ព័ន្ធទៅនឹងអ្នកផ្តល់សេវា និងព័ត៌មានដទៃទៀតដែលចាំបាច់ សម្រាប់ការរៀបចំកញ្ចប់ព័ត៌មានI4Cs។ ព័ត៌មានសំខាន់ចាំបាច់ ដែលត្រូវមាននៅក្នុងកញ្ចប់ព័ត៌មានI4Cs ត្រូវកំនត់ជាអាទិភាពទៅតាមប្រភេទព័ត៌មាន

[11] ពាក្យ "រដ្ឋាភិបាល" ដែលបានប្រើប្រាស់ក្នុងឯកសារនេះ គឺសំដៅលើសាលារៀន មណ្ឌលសុខភាព ឃុំ សង្កាត់ និង ក្រុង ស្រុក ខណ្ឌ ហើយនាពេលអនាគតអាចមានអង្គភាពផ្តល់សេវាដទៃទៀត (ទាំងមជ្ឈការ និងវិសហមជ្ឈការ)។

នីមួយៗ។ បើទោះបីមានការលំបាកក្នុងការចងក្រងព័ត៌មានខ្លះក៏ដោយ ក៏ព័ត៌មានសំខាន់ៗទាំងនោះភាគច្រើនមានស្រាប់រួចហើយ។ នៅពេលដែលគោលការណ៍ណែនាំបានរៀបចំរួច[12] គេរំពឹងថាការផ្តល់ព័ត៌មានទាំងឡាយនឹងមានលក្ខណៈរលូនជាងមុន។ ស្របពេលជាមួយគ្នានេះ ថ្នាក់ស្រុក ថ្នាក់ឃុំ និងអង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន គួរត្រូវបានលើកទឹកចិត្តឲ្យធ្វើការផ្សព្វផ្សាយនិងចងក្រងព័ត៌មានបន្ថែម ដែលអាចយកទៅប្រើប្រាស់សម្រាប់ជាតម្រូវការ និងជាប្រយោជន៍ដល់ប្រជាពលរដ្ឋនៅមូលដ្ឋានក្នុងពេលបំពេញការងាររបស់ពួកគេ។

### លទ្ធផល ១.២ កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) ត្រូវបានបោះពុម្ព និងផ្សព្វផ្សាយ

ក្រុមប្រឹក្សាឃុំ និងអង្គភាពផ្តល់សេវា ត្រូវរៀបចំបង្ហាញព័ត៌មានទៅតាមទម្រង់កំណត់ណាមួយ ដោយសហការជាមួយអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ ។ ទម្រង់នៃការផ្តល់ព័ត៌មាន និងសេចក្តីណែនាំ នឹងត្រូវរៀបចំ និងប្រើសាកល្បងនៅក្នុងដំណាក់កាលដំបូង។ នៅក្នុងការរៀបចំកញ្ចប់ព័ត៌មានI4Cs ត្រូវគិតពីផលប្រយោជន៍ និង តម្រូវការរបស់ស្ត្រី យុវវ័យ ប្រជាពលរដ្ឋក្រីក្រ និងក្រុមពាក់ព័ន្ធផ្សេងទៀត។ ព័ត៌មានសម្រាប់សាកល្បងត្រូវមាន៖ (១) គោលបំណងនិងក្រុមគោលដៅ (២)មធ្យោបាយផ្តល់ព័ត៌មានឲ្យបានត្រឹមត្រូវ (ដូចជា ការប្រើប្រាស់ខិត្តប័ណ្ណ វិទ្យុ កិច្ចប្រជុំ ក្តារព័ត៌មាន របាយការណ៍ គេហទំព័រ ។ល។) និង(៣) កំណត់ខ្លឹមសារ និងពន្យល់ទិន្នន័យត្រឹមត្រូវ ព្រមទាំងផ្តល់ព័ត៌មានដែលអាចធ្វើការប្រៀបធៀបបាន (ប្រៀបធៀបស្តង់ដារ ជាមួយគោលដៅ និងប្រៀបធៀបការផ្លាស់ប្តូរនានា និងនិន្នាការផ្លាស់ប្តូរទៅតាមពេលវេលា និងការប្រៀបធៀបរវាងឯកតានិមួយ)។

យោងតាមការណែនាំលម្អិតនៅក្នុងសេចក្តីណែនាំ I4Cs អ្នកពាក់ព័ន្ធនានានៅថ្នាក់ឃុំ និងថ្នាក់ស្រុកនឹងទទួលខុសត្រូវបង្កើតមធ្យោបាយផ្សព្វផ្សាយព័ត៌មានដែលមានការព្រមព្រៀងគ្នា ដូចជា ក្តារព័ត៌មាន របាយការណ៍ និងខិត្តប័ណ្ណ ដើម្បីផ្សព្វផ្សាយI4Cs។ សង្គមស៊ីវិល នឹងរៀបចំកិច្ចពិភាក្សានៅថ្នាក់មូលដ្ឋានដើម្បីធ្វើការពិនិត្យឡើងវិញ និងបញ្ជាក់ពីភាពសុក្រឹត្យរបស់ទិន្នន័យដែលបានផ្សព្វផ្សាយ។ សង្គមស៊ីវិលក៏ត្រូវបង្កើតឲ្យមានឯកសារ សម្រាប់ការសិក្សារៀនសូត្របន្ថែម និងជួយលើកកម្ពស់ការយល់ដឹងព្រមទាំងចុះតាមតំបន់គោលដៅ ដើម្បីផ្សព្វផ្សាយព័ត៌មាន (សូមមើលលទ្ធផល ១.៨ ខាងក្រោម)។

## អនុសមាសភាគទី១ខ ការបើកចំហព័ត៌មានថវិកា

### លទ្ធផល ១.៣ ព័ត៌មានអំពីថវិកាត្រូវបានប្រមូល ពិនិត្យឡើងវិញ និងចងក្រង

ការបើកចំហព័ត៌មានថវិកា និងការរៀបចំកញ្ចប់ព័ត៌មានI4Cs គឺជាកិច្ចការដ៏ចម្បងមួយនៃផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម។ ការប្រមូលព័ត៌មានទាក់ទងនឹងថវិកាមានលក្ខណៈខុសគ្នាពីអង្គភាព មួយទៅអង្គភាពមួយទៀត។ ជាទូទៅនៅថ្នាក់ឃុំ និងសាលារៀន មានការយល់ដឹងច្រើនអំពីថវិកានិងចំណាត់ថ្នាក់ថវិកា ដូច្នេះគេអាចធ្វើផែនការប៉ាន់ស្មាន និងគ្រប់គ្រងការចំណាយបាន។ ព័ត៌មានដែលត្រូវបង្ហាញត្រូវមាន

---

[12] ទោះបីជាមានចំនួនទិន្នន័យច្រើនដែលអាចទទួលបានជាសាធារណៈក៏ដោយ ព័ត៌មានភាគច្រើនត្រូវបានរៀបចំ សម្រាប់តែធ្វើការរាយការណ៍ ទៅថ្នាក់ជាតិតែប៉ុណ្ណោះ និងមិនមានភាពងាយស្រួលក្នុងការស្វែងរក និងទទួល បាននៅមូលដ្ឋានទេ។ នៅមានករណីផ្សេងទៀត ជាពិសេស នៅថ្នាក់ មូលដ្ឋានមានព័ត៌មានជាច្រើនដែលមិនមែនសុទ្ធតែមានប្រយោជន៍សម្រាប់ក្រុមប្រឹក្សា និងប្រជាពលរដ្ឋនោះទេ។ ជាទូទៅ ទិន្នន័យមិនត្រូវ បានរៀបចំ និង ប្រមូលផ្តុំនៅថ្នាក់ មូលដ្ឋានទេ រួមជាមួយគ្នានេះ ទម្លាប់ក្នុងការប្រមូលទិន្នន័យហាក់ដូចជាផ្តោតតែនៅថ្នាក់ខេត្ត ប៉ុណ្ណោះ។ ជាលទ្ធផល ការគ្រប់គ្រង និងការប្រមូលទិន្នន័យមិនត្រូវបានធ្វើវិមជ្ឈការឲ្យបានពេញលេញទៅឲ្យថ្នាក់ស្រុកទេ។ ទម្រង់និងការបង្ហាញព័ត៌មានមិនបានបង្កលក្ខណៈឲ្យ មានការប្រៀបធៀបបានទេ។ ដូច្នេះ លទ្ធផល ១.១ នេះមានគោលដៅដើម្បីដោះស្រាយនូវភាពខ្វះខាតនេះ។

បញ្ចូលតួលេខថវិកាបដិភាគរបស់សហគមន៍ ក៏ដូចជាជំនួយថវិកាផ្សេងៗ ដែលសាលារៀនបានទទួល និងគ្រោងនឹងទទួល (ដូចជា ជំនួយគាំទ្រដោយSida និងដៃគូអភិវឌ្ឍន៍នានា)។ ចំណែកឯ ព័ត៌មានថវិការបស់ មណ្ឌលសុខភាពនៅមានលក្ខណៈដាច់ដោយឡែកនិងខ្វះបច្ចុប្បន្នភាព ដែលតម្រូវឲ្យមានការកែលំអជាចាំបាច់។ ក្នុងករណីនេះ ការបិទ ផ្សាយគួរយកទិន្នន័យពីឆ្នាំមុន។

### លទ្ធផល ១.៤ ព័ត៌មានថវិកាដែលមានលក្ខណៈសាមញ្ញត្រូវបានបង្ហាញ និងបិទផ្សាយ

ព័ត៌មានថវិកាដែលមានលក្ខណៈសាមញ្ញ នឹងត្រូវបញ្ចូលនៅក្នុងកញ្ចប់ព័ត៌មានI4Cs ក៏ដូចជាបិទផ្សាយដោយឡែកនៅតាមសាលារៀន មណ្ឌលសុខភាព និងសាលាឃុំ ឬស្រុក ទៅតាមអ្វីដែលមានចែងនៅក្នុងសេចក្តីណែនាំ។ សាលារៀន មណ្ឌលសុខភាព និងសាលាឃុំ ភាគច្រើនបានអនុញ្ញាតឲ្យសហគមន៍មើលពីព័ត៌មានថវិកាបាន។ លទ្ធផល ១.៤ នឹងបង្កើតឲ្យមានជាទម្រង់បែបបទនៃការផ្តល់ព័ត៌មានជាលក្ខណៈសាកល្បងមួយ និងគាំទ្រឲ្យមានការបង្ហាញ និងបិទផ្សាយព័ត៌មានអំពីថវិកាដែលមានលក្ខណៈជាប្រព័ន្ធត្រឹមត្រូវនៅថ្នាក់មូលដ្ឋាន ជាពិសេសនៅថ្នាក់ស្រុក ឃុំ មណ្ឌលសុខភាព និងសាលារៀន។

## អនុសមាសភាគទី១គ ការរៀបចំប្រព័ន្ធ លិខិតបទដ្ឋាន និងការអនុវត្តតាមគោលការណ៍ណែនាំ

អនុសមាសភាគនេះ បង្កើតឲ្យមានជាប្រព័ន្ធ សេចក្តីណែនាំ លិខិតបទដ្ឋាននានា និងការអនុវត្តតាមគោលការណ៍ណែនាំ ដើម្បីពង្រឹងភាពងាយស្រួលក្នុងការទទួលបាននូវព័ត៌មាននានា និងព័ត៌មានថវិកា ព្រមទាំងរៀបចំឲ្យមានជារបៀបក្នុងការត្រួតពិនិត្យតាមដាន។

### លទ្ធផល ១.៥ នីតិវិធីក្នុងការគ្រប់គ្រងទិន្នន័យនៅថ្នាក់ស្រុកត្រូវបានបង្កើត និងអនុវត្ត

ព័ត៌មានផ្សេងៗដែលប្រមូលបាន ដូចរៀបរាប់ខាងលើនឹងត្រូវរៀបចំចងក្រង និងរក្សាទុកនៅថ្នាក់ស្រុក។ ការធ្វើបែបនេះអនុញ្ញាតឲ្យមានការប្រៀបធៀបព័ត៌មាន និងងាយទទួលបានព័ត៌មាន។ រដ្ឋបាលស្រុកនឹងធ្វើការប្រមូលព័ត៌មាន ហើយផ្តល់ព័ត៌មានទាំងនោះទៅឲ្យក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ ដើម្បីអាចធ្វើការវិភាគនិង ប្រើប្រាស់ព័ត៌មានទាំងនោះបាន។ ពាក់ព័ន្ធជាមួយថ្នាក់ឃុំនេះផងដែរ ការប្រមូលទិន្នន័យអេឡិចត្រូនិចដូចជាព័ត៌មានទិន្នន័យអំពីការអនុវត្តគម្រោង (PID) និងព័ត៌មានទិន្នន័យមូលដ្ឋានឃុំ (CDB) បច្ចុប្បន្នបានគ្រប់គ្រងនិងចាត់ចែងនៅថ្នាក់ខេត្តមិនមែននៅថ្នាក់ស្រុកឡើយ។ លទ្ធផល១.៥ នឹងគាំទ្របង្កើតឲ្យមានការបញ្ចូលទិន្នន័យ ការគ្រប់គ្រង និងការថែរក្សាទុកទិន្នន័យនៅថ្នាក់ស្រុក និងជួយឲ្យទទួលបាននូវព័ត៌មានឲ្យកាន់តែរហ័សជាងមុនសម្រាប់ថ្នាក់ឃុំ និងស្រុក។ ជាមួយគ្នានេះដែរ ក៏ត្រូវមានការត្រួតពិនិត្យផ្នែកបច្ចេកទេសទៅលើដំណើរការនៃការប្រមូលទិន្នន័យ និងបន្ទាប់មកត្រូវធ្វើការកែប្រែមួយចំនួនទៅលើនីតិវិធី និងសេចក្តីណែនាំដែលពាក់ព័ន្ធ។ ការកែសម្រួលការគ្រប់គ្រងទិន្នន័យ ត្រូវចាត់ទុកថាជាកិច្ចការដ៏សំខាន់មួយក្នុងការពង្រឹងភាពជាម្ចាស់ និងការប្រើប្រាស់ទិន្នន័យ។ សកម្មភាពដែលត្រូវអនុវត្តផ្សេងទៀតរួមមាន ការបង្កើតឲ្យមានជាយុទ្ធសាស្ត្រក្នុងការ រក្សាទុកព័ត៌មានពិចារណាបង្កើតឲ្យមានជាគេហទំព័រឬប្រព័ន្ធគ្រប់គ្រងព័ត៌មាននៅថ្នាក់ស្រុក[13]។

---

[13] បើទោះបីសកម្មភាពនេះ អាចអនុវត្តបានភាគច្រើនតែនៅក្នុងទីប្រជុំជន ឱកាសក្នុងការសាកល្បងសកម្មភាពទាំងនេះ អាចធ្វើបានដោយការិយាល័យប្រជាពលរដ្ឋទាំង៣៥ និងការិយាល័យព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (CICs) ដែលទើបបង្កើតថ្មីទាំង៦ ដែលបានសាកល្បងនៅក្នុងការិយាល័យ ច្រកចេញចូលតែមួយ។ ព័ត៌មានដែលត្រូវរៀបរាប់ក្នុងសមាសភាគនេះ នឹងត្រូវចែកជូនទៅកាន់ការិយាល័យព័ត៌មានសម្រាប់ប្រជាពលរដ្ឋ(CICs)។

## លទ្ធផល ១.៦ លិខិតបទដ្ឋាន និងសេចក្ដីណែនាំនានាសម្រាប់ការបើកចំហព័ត៌មានថវិកា និងព័ត៌មាននានានៅមូលដ្ឋានត្រូវបានបង្កើត និងអនុវត្ត

លិខិតបទដ្ឋាន និងសេចក្ដីណែនាំនានានឹងត្រូវបង្កើតឡើង ដោយមានចែងពីទំហំការងារ និងខ្លឹមសារនៃព័ត៌មាននានា និងព័ត៌មានថវិកា និងការបើកទូលាយព័ត៌មាននោះជាសាធារណៈ ព្រមទាំងមធ្យោបាយក្នុងការធ្វើឲ្យការទទួលព័ត៌មានមានលក្ខណៈកាន់តែប្រសើរឡើង ។ លទ្ធផល១.៦ នឹងជំរុញឲ្យគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ មណ្ឌលសុខភាព និងសាលារៀន មានកាតព្វកិច្ចផ្លូវច្បាប់ និងមានមធ្យោបាយក្នុងការផ្ដល់ព័ត៌មានទៅឲ្យប្រជាពលរដ្ឋ។ គ.ជ.អ.ប នឹងរៀបចំគោលនយោបាយខ្លីមួយ បញ្ជាក់ពីមធ្យោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ដល់ព័ត៌មានទៅកាន់សាធារណជន។ មន្ត្រីសាធារណៈ នឹងត្រូវទទួលបានការបណ្ដុះបណ្ដាល ក្នុងការអនុវត្តឲ្យមានការបើកចំហព័ត៌មាន (ឧទាហរណ៍ តួនាទីក្នុងការធ្វើឲ្យមានភាពងាយស្រួលក្នុងការទទួល បានព័ត៌មាន ក៏ដូចជាវិធីសាស្ត្រក្នុងការផ្ដល់សេវាជូនអតិថិជនផងដែរ)។

## លទ្ធផល ១.៧ ប្រព័ន្ធត្រួតពិនិត្យ និងការអនុវត្តតាមគោលការណ៍ណែនាំ សម្រាប់ការបើកចំហព័ត៌មានថវិកានៅមូលដ្ឋាន ត្រូវបានបង្កើត និងបានអនុវត្ត

សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវមានប្រកាសស្ដីពីការផ្ដល់ព័ត៌មានដល់ប្រជាពលរដ្ឋ ។ នៅក្នុងប្រកាសនោះ ក្រសួងមហាផ្ទៃត្រូវកំណត់នូវលក្ខខ័ណ្ឌការលើកទឹកចិត្ត និងទណ្ឌកម្មចាំបាច់នានា ដើម្បីជំរុញឲ្យមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តតាម[14]។ ដំណើរការនៃការត្រួតពិនិត្យនេះ[15] ត្រូវបង្កើតឡើង និងធ្វើឲ្យមានលក្ខណៈជាផ្លូវការ (បន្ថែមលើយន្តការត្រួតពិនិត្យនិងផ្ដល់យោបល់របស់សង្គមស៊ីវិល) ។ ឧទាហរណ៍ ត្រូវចាប់ផ្ដើមពីការប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ និងសៀវភៅណែនាំ ហើយដល់ឆ្នាំ ២០១៥ ទើបរៀបចំដំណើរការនោះ ឱ្យទៅជាដំណើរការធ្វើអធិការកិច្ចទៅលើការអនុវត្តតាមគោលការណ៍ណែនាំ ដែលមានលក្ខណៈកាន់តែឯករាជ្យ ជាផ្លូវការ និងលក្ខណៈជាប្រព័ន្ធ (រៀបចំឡើងនៅពេលអនុវត្តជ.អ.៣)។ ការធ្វើអធិការកិច្ចត្រូវវាយតម្លៃលើ៖ (១) តើព័ត៌មានដែលបានផ្ដល់ ស្របតាមគោលការណ៍ណែនាំដែរឬទេ? (២)តើព័ត៌មានដែលបាន ផ្ដល់មានភាពត្រឹមត្រូវដែរឬទេ?[16]។ សកម្មភាពទាំងនោះ មានរួមបញ្ចូល ការរៀបចំតាក់តែង និងការអនុវត្តនីតិវិធីក្នុងការត្រួតពិនិត្យរបស់រដ្ឋបាល និងសង្គមស៊ីវិល ដើម្បីធានាថាព័ត៌មាននិងរបាយការណ៍ចាំបាច់នានា បានផ្ដល់ដោយរដ្ឋបាលឃុំ សេវាសុខភាព សាលារៀន ព្រមទាំងការត្រួតពិនិត្យដោយប្រើប្រាស់ភស្ដុតាងជាក់ស្ដែង ដើម្បីពង្រឹងគោលការណ៍ណែនាំក្នុងការផ្ដល់នូវព័ត៌មាន និងទម្រង់បែបបទក្នុងការធ្វើរបាយការណ៍។ មួយផ្នែក នៃសកម្មភាពត្រួតពិនិត្យ គឺត្រូវមើលថាតើរដ្ឋបាលថ្នាក់ក្រោមជាតិបានប្រមូលចងក្រងទិន្នន័យបានត្រឹមត្រូវដែរឬទេ? កិច្ចការនេះ ចាំបាច់ត្រូវមានការពិភាក្សាបន្ថែមទៀត ថាតើត្រូវចាប់ផ្ដើមដូចម្ដេច ព្រមទាំងពិភាក្សាអំពីរបៀបធ្វើការត្រួតពិនិត្យតាមដាននៅពេលដែលប្រព័ន្ធត្រួតពិនិត្យមិនទាន់បានបង្កើតឡើងនៅឡើយ។

[14] ទោះបីក្រសួងមហាផ្ទៃជាអ្នកទទួលខុសត្រូវចម្បងក៏ដោយ ក៏ក្រសួងនេះអាចផ្ទេរការទទួលខុសត្រូវ (ដូចជាផ្ទេរមុខងារទៅឲ្យថ្នាក់ខេត្ត) ឬអាចធ្វើអធិការកិច្ចរួមគ្នាជាមួយអ្នកចូលរួមផ្នែកឯកជន ឬអង្គការសង្គមស៊ីវិល។

[15] ដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ នឹងលើកយកមកពិភាក្សាក្នុងសមាសភាគទី២។

[16] ជាការសំខាន់ដែលត្រូវបញ្ចូលអង្គការសង្គមស៊ីវិលនៅក្នុងការអនុវត្តតាមការត្រួតពិនិត្យ (និងស្របទៅតាមគោលការណ៍ គណនេយ្យភាពសង្គម)។

### លទ្ធផល ១.៨ ដំណើរការត្រួតពិនិត្យរបស់សង្គមស៊ីវិល ចំពោះការបើកចំហព័ត៌មានស្តីពីថវិកានៅមូលដ្ឋានត្រូវបានបង្កើត និងអនុវត្ត

ការបង្កើតឲ្យមានយន្តការត្រួតពិនិត្យតាមដាន គឺដើម្បីឲ្យគោលការណ៍ណែនាំស្តីពីការបើកចំហព័ត៌មានថវិកា ត្រូវបានអនុវត្តនៅមូលដ្ឋាន មិនត្រឹមតែពឹងផ្អែកលើប្រព័ន្ធរបស់រដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមានការចូលរួមពីបណ្តាអង្គការដៃគូក្នុងការផ្តល់យោបល់ត្រឡប់ជាទៀងទាត់ អំពីវឌ្ឍនភាពដែលសម្រេចបាន។ លទ្ធផល១.៨ នឹងរៀបចំបង្កើតឲ្យមានប្រព័ន្ធត្រួតពិនិត្យ និងការធ្វើសេចក្តីរាយការណ៍ពីបណ្តាអង្គការសង្គមស៊ីវិល លើការអនុវត្តតាមគោលការណ៍នានា សម្រាប់ការផ្សព្វផ្សាយជាសាធារណៈអំពីព័ត៌មាន និងថវិកានៅមូលដ្ឋានរបស់ស្រុក ឃុំ មណ្ឌលសុខភាព ឬ សាលារៀន (អង្គការដៃគូ នឹងបញ្ចូលទៅក្នុងសកម្មភាពរបស់ខ្លួនទាក់ទងនឹងការងារផ្តល់គោលការណ៍ណែនាំ និងការកសាងសមត្ថភាពផងដែរ)។ ព្រមជាមួយគ្នានេះ គ.ជ.អ.ប ត្រូវរៀបចំនិងផ្សព្វផ្សាយពីគោលការណ៍ណែនាំ ដើម្បីជំរុញឲ្យមានការឆ្លើយតបចំពោះការត្រួតពិនិត្យរបស់អង្គការសង្គមស៊ីវិល។ យន្តការត្រួតពិនិត្យតាមដានសម្រាប់ការចូលរួមរបស់ "ភាគីទីបី" នឹងត្រូវបង្កើតឡើងក្នុងដំណាក់កាលដំបូងនៃការអនុវត្ត ផ.អ.គ.ស។

## អនុសមាសភាគទី១យ ការលើកកម្ពស់ការយល់ដឹងនិងការពង្រឹងសមត្ថភាព

**អនុសមាសភាគនេះ មានគោលបំណងជំរុញឲ្យមានតម្រូវការនិងការទាមទារចង់ដឹងពីព័ត៌មានផ្សេងៗ និងព័ត៌មាន ថវិកា ដើម្បីឲ្យតួអង្គទាំងអស់ យល់ដឹងអំពីព័ត៌មានដែលទទួលបាន អំពីសិទ្ធិរបស់ប្រជាពលរដ្ឋ ក៏ដូចជាទីកន្លែង របៀបក្នុងការស្វែងរក និងប្រើប្រាស់ព័ត៌មានទាំងនោះ។** អនុសមាសភាគនេះក៏មានគោលបំណង ក្នុងការកសាងសមត្ថភាពរបស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានឲ្យចេះប្រើប្រាស់ព័ត៌មាននានា និងព័ត៌មានថវិកាប្រកបដោយប្រសិទ្ធភាព។ សមាសភាគនេះមានរៀបចំយុទ្ធនាការលើកកម្ពស់ការយល់ដឹងនៅមូលដ្ឋាន ដែលត្រូវធ្វើស្របគ្នាជាមួយនឹងការផ្សព្វផ្សាយកញ្ចប់ពត៌មានI4Cs នៅថ្នាក់ស្រុក ឃុំ និងភូមិ តាមរយៈការលើកកម្ពស់ការយល់ដឹង ការបង្កើតជំនាញផ្សេងៗ ការផ្សព្វផ្សាយនិងវិភាគព័ត៌មាននានា និងព័ត៌មានថវិកា។ សកម្មភាពទាំងនេះត្រូវផ្តោតជាពិសេសលើស្ត្រី យុវវ័យ និងជនក្រីក្រ ហើយត្រូវធ្វើយ៉ាងណាឲ្យពត៌មានទាំងអស់ បានទៅដល់ក្រុមគោលដៅទាំងនោះ។

### លទ្ធផល១.៩៖ សមត្ថភាពអ្នកសម្របសម្រួលនៅសហគមន៍ត្រូវបានបណ្តុះបណ្តាលអំពីគណនេយ្យភាពសង្គម ព័ត៌មាននានា និងព័ត៌មានថវិកា

អ្នកសម្របសម្រួលគណនេយ្យភាពនៅសហគមន៍ គឺជាតួអង្គដ៏សំខាន់ក្នុងការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពីព័ត៌មាន និងថវិការដ្ឋ។ លទ្ធផល១.៩ បង្ហាញព័ត៌មានជាមូលដ្ឋានស្តីពីក្របខ័ណ្ឌ និងគោលការណ៍នានានៃគណនេយ្យភាពសង្គម ព្រមទាំងផ្តល់ការបណ្តុះបណ្តាល និងផ្តល់យោបល់ដល់អ្នកសម្របសម្រួលគណនេយ្យភាពនៅតាមសហគមន៍ ឲ្យបានដឹងពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន និងការយល់ដឹងពីសារៈសំខាន់នៃព័ត៌មានទាំងនោះ។ អ្នកសម្របសម្រួល នឹងត្រូវរៀនពីរបៀបវិភាគព័ត៌មានដែលមានក្នុងកញ្ចប់ព័ត៌មានI4Cs របៀបចែករំលែកព័ត៌មានទៅកាន់ប្រជាពលរដ្ឋ និងជួយឲ្យប្រជាពលរដ្ឋបានយល់ដឹង និងប្រើប្រាស់ព័ត៌មានទាំងនោះ។ ដូចបានរៀបរាប់ខាងលើ កញ្ចប់ព័ត៌មានI4Cs នឹងមានរួមបញ្ចូលនូវ

ព័ត៌មានថវិកា និងការចំណាយសាធារណៈនានា។ អ្នកសម្របសម្រួល នឹងទទួលបានការបណ្តុះបណ្តាលអំពីថវិកាសាធារណៈ ហើយធ្វើការអប់រំបន្តដល់ប្រជាពលរដ្ឋ សំដៅជួយពួកគាត់អាចទទួលបាននិងប្រើប្រាស់ព័ត៌មានថវិកាមកធ្វើជា មូលដ្ឋានសម្រាប់ពិភាក្សាជាមួយមន្ត្រីមូលដ្ឋានទាក់ទងនឹងបញ្ហាថវិកាសាធារណៈ។ សកម្មភាពទាំងនេះត្រូវផ្តោតការយកចិត្តទុកដាក់ដោយឡែកចំពោះស្ត្រី យុវវ័យ និងសមាជិកផ្សេងៗទៀតរបស់សហគមន៍ដែលមិនសូវទទួលបានឱកាសចូលរួមក្នុងការពិភាក្សាពីបញ្ហាថវិកា និងត្រូវពន្យល់ដល់ពួកគេអំពីសារៈសំខាន់នៃការយល់ដឹងពីព័ត៌មាន និងថវិកានេះ។

## លទ្ធផល ១.១០ សមាជិកក្រុមប្រឹក្សា មន្ត្រីមូលដ្ឋាន និងអ្នកផ្តល់សេវានៅមូលដ្ឋាន នឹងបានទទួលការបណ្តុះបណ្តាលស្តីពីព័ត៌មាននានា និងព័ត៌មានថវិកា

ស្ថាប័ន អង្គភាពរបស់រដ្ឋនៅមូលដ្ឋាន មានតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយ និងជួយឲ្យប្រជាពលរដ្ឋមានការយល់ដឹងពីកញ្ចប់ព័ត៌មានI4Cs និងសារៈសំខាន់នៃតម្លាភាពហិរញ្ញវត្ថុសាធារណៈ។ នៅក្នុងលទ្ធផលនេះ សមាជិកក្រុមប្រឹក្សា មន្ត្រីនានា និងអ្នកផ្តល់សេវានៅមូលដ្ឋាន នឹងទទួលបានការបណ្តុះបណ្តាល និងការគាំទ្រដើម្បីយល់ដឹងអំពីព័ត៌មាននៃការបំពេញការងារចំណូលនិងថវិកា ការចំណាយ និងពីរបៀបគាំទ្រឲ្យប្រជាពលរដ្ឋទូទៅមានការយល់ដឹងពីព័ត៌មាននានា និងព័ត៌មានថវិកា។

## លទ្ធផល ១.១១ ការយល់ដឹងរបស់អង្គការសហគមន៍មូលដ្ឋាន សហគមន៍នានា និងប្រជាពលរដ្ឋទាក់ទងនឹងព័ត៌មាន និងថវិកាត្រូវបានលើកកម្ពស់

ស្ថាប័ន អង្គភាពពាក់ព័ន្ធផ្សេងៗទាំងរបស់រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងឯកជននឹងធ្វើការបែងចែកកញ្ចប់ព័ត៌មានI4Cs និងព័ត៌មានថវិកា។ នៅពេលដែលកញ្ចប់ព័ត៌មាននេះ ត្រូវបានផ្តល់ក្នុងទម្រង់ថ្មីដែលងាយស្រួលក្នុងការស្វែងរក ទទួលបាន និងងាយយល់ (ដូចដែលបានរៀបរាប់នៅក្នុងលទ្ធផល១.២ និង១.៤) អង្គការដៃគូនៅមូលដ្ឋាន អ្នកសម្របសម្រួលគណនេយ្យភាពនៅសហគមន៍ និងសមាជិកក្រុមប្រឹក្សានឹងជួយប្រជាពលរដ្ឋ និងអង្គការសហគមន៍មូលដ្ឋានឲ្យយល់ពីសារប្រយោជន៍ក្នុងការដឹងព័ត៌មានទាក់ទងនឹងការបំពេញការងារ និងព័ត៌មានថវិកា។ ការរៀបចំឲ្យមានសមត្ថភាពយល់ដឹងជាមូលដ្ឋានអំពីថវិកា គឺជាសកម្មភាពចម្បងដែលបានកំនត់ក្នុងលទ្ធផលនេះ។ ក្រុមប្រឹក្សាឃុំ និងអង្គការមិនមែនរដ្ឋាភិបាលនានានៅមូលដ្ឋានដែលធ្វើការជា មួយអ្នកសម្របសម្រួលគណនេយ្យភាពនៅសហគមន៍ ត្រូវរៀបចំយុទ្ធនាការលើកកម្ពស់ការយល់ដឹងការប្រជុំតាមសហគមន៍ ការចេញជាសេចក្តីប្រកាសព័ត៌មាន ផ្តល់កិច្ចសម្ភាសន៍ដល់អ្នកសារព័ត៌មាន ការរៀបចំឲ្យមានការជួបជុំស្តាប់វិទ្យុ និងមើលទូរទស្សន៍ដើម្បីលើកទឹកចិត្តដល់ប្រជាពលរដ្ឋឲ្យចេះធ្វើការឆ្លុះបញ្ចាំង និងពិភាក្សារួមគ្នាអំពីព័ត៌មានដែលមាននៅក្នុងកញ្ចប់ព័ត៌មានI4Cs និងកិច្ចការថវិកា។

**សមិទ្ធិផលក្នុងសមាសភាគនេះ រំពឹងថារដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវានៅមូលដ្ឋាន នឹងចងក្រងកញ្ចប់ព័ត៌មាន បិទផ្សាយព័ត៌មានថវិកានិងការចំណាយនានា ព្រមទាំងកសាងសមត្ថភាពដល់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីប្រើប្រាស់ព័ត៌មានទាំងនោះ (មានដូចជា គោលនយោបាយ ស្តង់ដារ តួលេខគោលដៅ និងការបំពេញការងារ ព័ត៌មានថវិកា និងការចំណាយនានា)។**

- **ផ្នែកផ្គត់ផ្គង់៖** ត្រឹមឆ្នាំ២០១៧ឃុំទាំងអស់នៅក្នុងស្រុកទាំង១២០ ត្រូវបើកចំហព័ត៌មានព័ត៌មានថវិកាទាក់ទងនឹងសាលារៀន សេវាសុខភាព និងសាលាឃុំ សាលាស្រុក។ ព័ត៌មានទាំងនោះរួមមានការបំពេញការងារ ការចំណាយ និងលម្អិតទៅតាមភេទនិងក្រុមប្រជាពលរដ្ឋ។ ត្រឹមចុងឆ្នាំ២០១៤ សេចក្តីព្រាងលិខិតបទដ្ឋាននានាស្តីពីការផ្សព្វផ្សាយជាសាធារណៈត្រូវបានតាក់តែង អនុម័ត និងអនុវត្ត។ ការត្រួតពិនិត្យតាមដាននឹងត្រូវអនុវត្តជាប្រចាំ ដើម្បីធានាសុក្រឹត្យភាពរបស់ទិន្នន័យ និងភាពទៀងទាត់ក្នុងការអនុវត្តការងារ។ ការប្រមូលទិន្នន័យត្រូវធ្វើការកែសម្រួលឲ្យកាន់តែប្រសើរឡើង ហើយថ្នាក់ខេត្ត នឹងធ្វើវិមជ្ឈការការងារកាន់តែច្រើនឡើងឲ្យដល់ថ្នាក់ស្រុក ក្នុងការប្រមូលទិន្នន័យនេះ ។
- **ផ្នែកតម្រូវការ៖** ការងារលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ នឹងត្រូវធ្វើឡើងក្នុងលក្ខណៈជាប្រព័ន្ធ និងមានការពង្រឹងសមត្ថភាពតាមការចាំបាច់។ ការយល់ដឹងអំពីថវិកា នឹងក្លាយជាទុនសម្រាប់ប្រជាពលរដ្ឋក្នុងការទាមទារគណនេយ្យភាពពីរដ្ឋាភិបាល ចំពោះការផ្តល់សេវានៅមូលដ្ឋាន។ ប្រជាពលរដ្ឋ និងតួអង្គមិនមែនរដ្ឋាភិបាល នឹងប្រើប្រាស់ព័ត៌មានទាំងនេះ សម្រាប់ការងារត្រួតពិនិត្យតាមដានដូចបានរៀបរាប់នៅក្នុងសមាសភាគទី២។

**តារាងសង្ខេបអំពីសមាសភាគ១ ការទទួលបាននូវព័ត៌មាន និងការទារថវិកា**

| ផ្នែក | ការរៀបរាប់ |
|---|---|
| គោលបំណង | • លើកកម្ពស់តម្លាភាព ការទទួលបាន និងការទាមទារព័ត៌មានសាធារណៈស្តីពីគោលនយោបាយ ស្តង់ដារ ការងារថវិកា ការចំណាយ គោលដៅ និងការបំពេញការងារ<br>• លើកកម្ពស់សមត្ថភាពយល់ដឹងរបស់ភាគីពាក់ព័ន្ធអំពីថវិកា និងពង្រឹងឲ្យមានការសាកសួរអំពីការងារថវិកា |
| អនុសមាសភាគ និងលទ្ធផលរំពឹងទុក | **១ក ព័ត៌មានពាក់ព័ន្ធការបំពេញការងារ និងលទ្ធផល**<br>**លទ្ធផល១.១** ទិន្នន័យដែលជាធាតុចូលសម្រាប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ)I4Cs) ត្រូវបានប្រមូល ពិនិត្យ ផ្ទៀតផ្ទាត់ និងចងក្រង<br>**លទ្ធផល ១.២** កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs) ត្រូវបានរៀបចំ<br>**១ខ ការបើកចំហព័ត៌មានថវិកា**<br>**លទ្ធផល ១.៣** ព័ត៌មានអំពីថវិកាត្រូវបានប្រមូល ពិនិត្យឡើងវិញ និងចងក្រង<br>**លទ្ធផល ១.៤** ព័ត៌មានថវិកាដែលមានលក្ខណៈសាមញ្ញត្រូវបានបង្ហាញនិងបិទផ្សាយ<br>**១គ ការរៀបចំប្រព័ន្ធ លិខិតបទដ្ឋាន និងការអនុវត្តតាមគោលការណ៍ណែនាំ**<br>**លទ្ធផល ១.៥** នីតិវិធីក្នុងការគ្រប់គ្រងទិន្នន័យនៅថ្នាក់ស្រុកត្រូវបានបង្កើត និងអនុវត្ត<br>**លទ្ធផល ១.៦** លិខិតបទដ្ឋាន និងសេចក្តីណែនាំនានាសម្រាប់ការបើកចំហព័ត៌មាន ថវិកា និងព័ត៌មាននានានៅមូលដ្ឋានត្រូវបានបង្កើត និងអនុវត្ត<br>**លទ្ធផល ១.៧** ប្រព័ន្ធត្រួតពិនិត្យ និងការគោរពអនុវត្តតាម សម្រាប់ការបើកចំហ ព័ត៌មានថវិកានៅមូលដ្ឋានត្រូវបានបង្កើត និងអនុវត្ត<br>**លទ្ធផល ១.៨** ដំណើរការត្រួតពិនិត្យរបស់សង្គមស៊ីវិល ចំពោះការបើកចំហព័ត៌មាន ថវិកានៅ |

មូលដ្ឋានត្រូវបានបង្កើត និងអនុវត្ត

**១ឃ ការលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាព**

**លទ្ធផល ១.៩** សមត្ថភាពអ្នកសម្របសម្រួលនៅសហគមន៍ត្រូវបានបណ្តុះ បណ្តាលអំពីគណនេយ្យភាពសង្គម ព័ត៌មាននានា និងព័ត៌មានថវិកា

**លទ្ធផល ១.១០** ក្រុមប្រឹក្សា មន្ត្រីមូលដ្ឋាន និងអ្នកផ្តល់សេវានៅមូលដ្ឋាន បាន ទទួលការបណ្តុះបណ្តាលស្តីពីព័ត៌មាននានា និងព័ត៌មានថវិកា

**លទ្ធផល ១.១១** ការយល់ដឹងរបស់អង្គការសហគមន៍មូលដ្ឋាន សហគមន៍នានា និង ប្រជាពលរដ្ឋទាក់ទងនឹងព័ត៌មាន និងថវិកាត្រូវបានលើកកម្ពស់

# សមាសភាគទី ២

# ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ

គោលបំណងនៃសមាសភាគទី២ គឺដើម្បីណែនាំឲ្យមានការសម្របសម្រួលការត្រួតពិនិត្យតាមដាន និងការធ្វើ របាយការណ៍ដោយប្រជាពលរដ្ឋ សហគមន៍ ស្ដីពីសកម្មភាពរបស់ឃុំ ស្រុក និងការផ្ដល់សេវាមូលដ្ឋាននានា។ យុទ្ធសាស្ត្រនេះមានគោលបំណងពង្រឹងតួនាទីរបស់ប្រជាពលរដ្ឋ អ្នកប្រើប្រាស់សេវា និងសមាជិកក្រុមប្រឹក្សាឃុំនៅក្នុងការត្រួតពិនិត្យ និងទាមទារគណនេយ្យភាពពីអ្នកផ្ដល់សេវានៅថ្នាក់មូលដ្ឋាន។

ផ.អ.គ.ស មានគោលបំណងផ្ដោតលើការចូលរួមរបស់ប្រជាពលរដ្ឋ តាមរយៈការត្រួតពិនិត្យតាមដាន និងផ្ដល់យោបល់ត្រលប់ទៅលើការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋាន។ កន្លងមក ការចូលរួមរបស់ប្រជាពលរដ្ឋបានធ្វើឡើងតែតាមរយៈដំណើរការកសាងផែនការប៉ុណ្ណោះ។ ដោយសារតែដំណើរការការកសាងផែនការ គឺជាផ្នែកមួយដ៏សំខាន់នៃប្រតិទិនការងាររបស់ឃុំ ផ.អ.គ.ស នឹងជួយបំពេញបន្ថែមទៅលើដំណើរការនេះ នូវសកម្មភាព សំខាន់ៗមួយចំនួន សំដៅលើកកម្ពស់សិទ្ធិអំណាចរបស់ប្រជាពលរដ្ឋ។ យន្តការដែលបានអនុវត្តកន្លងមកមានលក្ខណៈផ្លូវការ និងជាកាតព្វកិច្ចតម្រូវឲ្យមានការចូលរួមរបស់ប្រជាពលរដ្ឋ ប៉ុន្តែជារឿយៗការចូលរួមនោះមិនសូវ ជាសកម្មនោះឡើយ។ ផែនការយុទ្ធសាស្ត្រស្ដីពីគណនេយ្យភាពសង្គម បានផ្ដោតលើសកម្មភាពក្នុងការត្រួតពិនិត្យតាមដាននៅតាមសហគមន៍ ដែលក្នុងនោះប្រជាពលរដ្ឋអាចចូលរួមដោយសេរីនិងដើរតួនាទីយ៉ាងសកម្ម។

យុទ្ធសាស្ត្រនេះ មានគោលបំណងលើកកម្ពស់សិទ្ធិអំណាចរបស់សមាជិកក្រុមប្រឹក្សា និងប្រជាពលរដ្ឋក្នុងការឆ្លុះបញ្ចាំងពីការបំពេញការងារធៀបទៅនឹងស្ដង់ដារនានា និងផ្ដោតលើសកម្មភាពផ្សេងៗដែលអាចអនុវត្ត (ដោយសហគមន៍ ក្រុមប្រឹក្សា អ្នកផ្ដល់សេវា និងអង្គភាពជំនាញ) ដើម្បីឲ្យការបំពេញការងារកាន់តែមានលក្ខណៈ ល្អប្រសើរ។ ការត្រួតពិនិត្យតាមដានលើការបំពេញការងារ នឹងជួយលើកកម្ពស់សិទ្ធិអំណាចរបស់ប្រជាពលរដ្ឋ តាមរយៈការទទួលបានព័ត៌មាន ដែលអាចឲ្យពួកគេចូលរួមចំណែកនៅក្នុងដំណើរការកសាងផែនការ ដែលមានស្រាប់។ ការត្រួតពិនិត្យតាមដានលើការបំពេញការងារ គឺជាកត្តាមួយដ៏សំខាន់ក្នុងដំណើរការលើកកម្ពស់សិទ្ធិ អំណាចដោយសារសកម្មភាពនេះធ្វើឡើងដោយប្រជាជនខ្លួនឯងផ្ទាល់ក្នុងការដោះស្រាយនូវបញ្ហានានាដែលពាក់ព័ន្ធទៅនឹងពួកគេ។ ផ.អ.គ.ស នឹងផ្ដល់ដល់ប្រជាពលរដ្ឋនូវព័ត៌មានដែលមានលក្ខណៈអន្តរវិស័យបាន ច្បាស់លាស់ និងជួយលើកកម្ពស់សិទ្ធិអំណាចរបស់ពួកគេឲ្យដើរតួនាទីសំខាន់ ក្នុងការលើកឡើងជាអនុសាសន៍កែលំអនានា និងចូលរួមក្នុងដំណើរការត្រួតពិនិត្យ វាយតម្លៃស៊ីជម្រៅទៅលើសេវាណាមួយ ដែលពួក គេគិតថាជាសេវាកម្មជាអាទិភាពរបស់ពួកគេ។

**<u>ការបរិយាយពីសមាសភាគ</u>**

ផ្នែកតម្រូវការ ៖ សមាសភាគទី២នេះបង្ហាញនូវដំណើរការសម្របសម្រួលឲ្យមានការចូលរួមក្នុងការត្រួតពិនិត្យតាមដានលើមុខងារ និងសេវាមួយចំនួន។ ដោយមានការគាំទ្រពីអ្នកសម្របសម្រួលគណនេយ្យភាព នៅមូលដ្ឋានដែលបានការបណ្ដុះបណ្ដាល រួមជាមួយនឹងអង្គការដៃគូផ្សេងៗ និងដើម្បីទទួលបានព័ត៌មាន អំពី ស្ដង់ដារ និងសូចនាករនៃការបំពេញការងារ ដូចមាននៅក្នុងសមាសភាពទី១ ក្រុមប្រជាពលរដ្ឋនឹងទី១៖ ធ្វើការ វាយតម្លៃដោយខ្លួន

ឯងទៅលើការបំពេញការងាររបស់អ្នកផ្តល់សេវានៅមូលដ្ឋាន (មណ្ឌលសុខភាព សាលារៀន រដ្ឋបាលឃុំ) និង ទី២៖ ចាត់អាទិភាពនៃបញ្ហាដែលជាកង្វល់ខ្លាំងបំផុតខ្លួន។ ឧបករណ៍សម្រាប់ធ្វើការវាយតម្លៃដោយប្រជាពលរដ្ឋនេះ ហៅថា "**ប័ណ្ណដាក់ពិន្ទុរបស់សហគមន៍**"។ លទ្ធផលទទួលបាន នឹងត្រូវធ្វើការចែករំលែក និងពិភាក្សាជាមួយសមាជិកក្រុមប្រឹក្សាឃុំ អ្នកផ្តល់សេវា និងមន្ត្រីថ្នាក់ស្រុក តាម រយៈកិច្ចប្រជុំដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ហៅថា "**កិច្ចប្រជុំរួមគ្នា**" ។ នៅក្នុងកិច្ចប្រជុំរួមគ្នានេះ អ្នកចូលរួមទាំងអស់ ត្រូវខិតខំ រិះរកដំណោះស្រាយចំពោះបញ្ហាចោទនានា តាមរយៈដំណើរការនៃការធ្វើផែនការសកម្មភាពមួយ ដែលបង្កើតបានជា "**ផែនការសកម្មភាពគណនេយ្យភាពរួមគ្នា**"។ ផែនការសកម្មភាពនេះនឹងកំណត់នូវសកម្មភាពចំនួនបួន ដែលត្រូវធ្វើដោយ៖

(១) សហគមន៍

(២) អ្នកផ្តល់សេវា

(៣) ក្រុមប្រឹក្សាឃុំ និង

(៤) ការិយាល័យសុខាភិបាល និងការិយាល័យអប់រំស្រុក។

ដើម្បីលើកកម្ពស់គណនេយ្យភាព លទ្ធផលនៃការវាយតម្លៃ និងសកម្មភាពនានានឹងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនៅថ្នាក់ស្រុក ព្រមទាំងបង្ហាញនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក។

**ផ្នែកផ្គត់ផ្គង់៖ សមាសភាគនេះ បានកំណត់នូវសកម្មភាពរបស់រដ្ឋាភិបាលក្នុងការបង្កើតឲ្យមានជា នីតិវិធីដើម្បីគាំទ្រដល់សកម្មភាពត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋតាមសហគមន៍(មតិយោបល់ត្រឡប់ លទ្ធផល និងការតាមដាននានា)**។ អង្គភាពនានារបស់រដ្ឋាភិបាល នឹងចូលរួមក្នុងកិច្ចប្រជុំរួមគ្នា ដើម្បីស្តាប់លទ្ធផលនៃការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ ដើម្បីរៀបចំនិងចាត់វិធានការឆ្លើយតបនានា។ រដ្ឋបាល មូលដ្ឋាន ត្រូវធានាឱ្យកិច្ចប្រជុំរួមគ្នានេះប្រព្រឹត្តទៅក្នុងបរិយាកាសអព្យាក្រឹត្យ និងមានអ្នកសម្របសម្រួលដែលមានអព្យាក្រឹត្យភាព ផងដែរ។

**យុទ្ធសាស្ត្រនេះ ផ្តោតលើការពង្រឹងនូវទំនាក់ទំនងការងារ និងការប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានតាមរយៈដំណើរការសម្របសម្រួលនានា**។ យុទ្ធសាស្ត្រនេះព្យាយាមឲ្យមានការផ្លាស់ប្តូរទំនាក់ទំនងរវាងប្រជាពលរដ្ឋ ជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវានានាឲ្យទៅជាទំនាក់ទំនងមួយដែលទទួលបានលទ្ធផលប្រសើរជាងមុន តាមរយៈការចែករំលែកព័ត៌មាន ការយោគយល់ និងការគោរពមុខងារ តួនាទី និងសិទ្ធិគ្នាទៅវិញទៅមក។ យុទ្ធសាស្ត្រនេះសម្រេចបានតាមរយៈ៖

១) ធានាថាគ្រប់ភាគីទាំងអស់ដែលចូលរួមកិច្ចប្រជុំ យល់ដឹងពីបទដ្ឋានស្តង់ដារ និងលទ្ធផលនៃការបំពេញការងារ
២) សមាជិកក្រុមប្រឹក្សា ត្រូវទៅជួបជាមួយប្រជាពលរដ្ឋ (ជាជាងគ្រាន់តែឲ្យប្រជាពលរដ្ឋចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា)
៣) ផ្តល់ការសម្របសម្រួលប្រកបដោយវិជ្ជាជីវៈ
៤) ផ្តល់ការយកចិត្តទុកដាក់លើយេនឌ័រ អាយុ និងស្ថានភាពសេដ្ឋកិច្ច-សង្គម និង
៥) លើកកម្ពស់ការចូលរួម និងការផ្លាស់ប្តូរយោបល់។ រាល់ការត្រួតពិនិត្យ និងសកម្មភាពរួមគ្នានានាត្រូវបានសម្របសម្រួលដោយអ្នកសម្របសម្រួលគណនេយ្យភាពនៅសហគមន៍ ដែលទទួលបានការបណ្តុះបណ្តាល និងគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល (សូមមើលសមាសភាគទី៣)។

**កិច្ចប្រជុំរួមគ្នា ដើម្បីរៀបចំផែនការសកម្មភាពគណនេយ្យភាពរួមគ្នា(ផ.ស.គ.រ)**

ផ.ស.គ.រ នេះ នឹងរៀបរាប់អំពីអ្វី ដែលប្រជាពលរដ្ឋ អ្នកផ្តល់សេវាមូលដ្ឋាន រដ្ឋបាលឃុំ និងការិយាល័យស្រុក ត្រូវធ្វើដើម្បីដោះស្រាយបញ្ហាខ្វះខាត ក្នុងការបំពេញការងារ ដែលរកឃើញដោយសកម្មភាពត្រួតពិនិត្យតាមដាន។ ផ.ស.គ.រ នឹងត្រូវរៀបចំក្នុងកិច្ចប្រជុំរួមគ្នា និងត្រូវមានការត្រួតពិនិត្យតាមដានបន្តក្រោមការណែនាំរបស់គណៈកម្មការរួមមួយ សម្រាប់រៀបចំផ.ស.គ.រ ដែលមានសមាសភាពជាតំណាងនានាមកពីឃុំ និងប្រជាពលរដ្ឋ ។ គណៈកម្មការនេះ នឹងស្នើសុំការយល់ព្រមពីក្រុមប្រឹក្សាឃុំ (ឲ្យមានការឯកភាពលើសកម្មភាពដែលត្រូវអនុវត្តដោយឃុំ) ព្រមទាំងផ្តល់ការគាំទ្រ និងត្រួតពិនិត្យលើការអនុវត្តផ.ស.គ.រ ដោយភាគីពាក់ព័ន្ធទាំងឡាយ។

**តួនាទីរបស់ក្រុមប្រឹក្សាឃុំ**

នៅក្នុងករណីខ្លះ ក្រុមប្រឹក្សាឃុំគឺជាអ្នកផ្តល់សេវា ក៏ប៉ុន្តែនៅក្នុងករណីខ្លះទៀត ក្រុមប្រឹក្សាឃុំគឺជាតំណាងរបស់ប្រជាពលរដ្ឋ និងមានតួនាទីជាអ្នកពិនិត្យមើលពីលើអំពីការផ្តល់សេវាកម្មនៅថ្នាក់មូលដ្ឋាន។ អាស្រ័យហេតុនេះ នៅក្នុងការប្រាស្រ័យទាក់ទងជាមួយថ្នាក់ជាតិ តួនាទីពិនិត្យមើលពីលើរបស់តួអង្គសំខាន់ៗនៅថ្នាក់ឃុំ (ដូចជាសមាជិកក្រុមប្រឹក្សាឃុំ ស្មៀន និងមេភូមិ) ត្រូវបានពង្រឹង។ សមាជិកក្រុមប្រឹក្សាឃុំនឹងក្លាយជាស្ពានសម្រាប់ការប្រាស្រ័យទាក់ទង រវាងប្រជាពលរដ្ឋ ជាមួយអង្គភាពផ្តល់សេវាកម្មនានារបស់រដ្ឋបាល ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ។

**ការសម្របសម្រួលក្នុងការអនុវត្ត**

ការអនុវត្តសមាសភាគទីពីរនេះ ត្រូវនាំមុខជាបឋមដោយប្រជាពលរដ្ឋនិងសហគមន៍ដែលធ្វើការជាមួយអ្នកសម្របសម្រួលគណនេយ្យភាពនៅសហគមន៍ដែលបានបណ្តុះបណ្តាល និងហ្វឹកហ្វឺនណែនាំពីអង្គការមិនមែនរដ្ឋាភិបាលនានា។ មានការរំពឹងទុកថា ក្នុងស្រុកនីមួយៗយ៉ាងហោចណាស់មានចំនួនប្រជាពលរដ្ឋចំនួន៨០០នាក់ (ដែលក្នុងនោះ៤០០នាក់ជាស្ត្រី) បានមកចូលរួមដោយផ្ទាល់ នៅក្នុងការត្រួតពិនិត្យតាមដានប្រចាំឆ្នាំ ទៅលើបញ្ហានៃការផ្តល់សេវារបស់អង្គភាពជំនាញនានា។

សមាសភាគទី២ នេះនឹងត្រូវរៀបចំទៅជា អនុសមាសភាគទី២ក ទី២ខ ទី២គ និងទី២ឃ ដែលអាចសម្រេចបានតាមរយៈលទ្ធផលរំពឹងទុកចំនួន១០ជាបន្តបន្ទាប់ដូចខាងក្រោម។

## អនុសមាសភាគ ទី២ក ការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ

### ដំណើរការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋនៅថ្នាក់ភូមិ

កិច្ចដំណើរការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ នឹងធ្វើឡើងនៅតាមភូមិនីមួយៗ (ឬប្រមូលផ្តុំភូមិមួយចំនួន)។ សមាជិកសហគមន៍នឹងដាក់ពិន្ទុដោយខ្លួនឯង និងចាត់អាទិភាពតាមវិស័យឬបញ្ហានានា ក៏ដូចជាការពិភាក្សា និងផ្ទៀងផ្ទាត់ទិន្នន័យ ព័ត៌មានដែលមានស្រាប់ទៅតាមវិស័យ។ អង្គការមិនមែនរដ្ឋាភិបាល នៅមូលដ្ឋាន នឹងធ្វើការហ្វឹកហ្វឺនដល់អ្នកសម្របសម្រួលគណនេយ្យភាពនៅសហគមន៍ និងអង្គការសហគមន៍ មូលដ្ឋាននានា។ រដ្ឋបាលមូលដ្ឋាន នឹងចូលរួមពេញលេញក្នុងសកម្មភាពត្រួតពិនិត្យតាមដាន។ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូរបស់ខ្លួន នឹងស្នើឡើងអំពីទីកន្លែងដែលត្រូវធ្វើការត្រួតពិនិត្យតាមដាន ស្របតាមគោលការណ៍ណែនាំ ព្រមទាំងសម្របសម្រួលចងក្រងក្រុមស្ត្រី យុវវ័យ និងគ្រួសារក្រីក្រដើម្បីចូលរួមក្នុងការជួបជុំនានា។

**គោលការណែនាំសម្រាប់បំពេញប័ណ្ណដាក់ពិន្ទុរបស់សហគមន៍** លើការផ្តល់សេវារបស់វិស័យនានា នឹងត្រូវរៀបចំជាសៀវភៅណែនាំ។ នៅក្នុងដំណាក់កាលរៀបចំ សៀវភៅណែនាំមួយ នឹងត្រូវតាក់តែងឡើងសម្រាប់ណែនាំពីរបៀបបំពេញប័ណ្ណដាក់ពិន្ទុ។ រាល់ឧបករណ៍ទាំងឡាយ នឹងត្រូវធ្វើការសាកល្បងនៅមូលដ្ឋាន ដើម្បីប្រមូលមតិយោបល់នានា និងធ្វើការកែសម្រួលឲ្យកាន់តែប្រសើរ។ ផ្នែកខាងក្រោមនឹងបង្ហាញអំពីលទ្ធផល នៃសមាសភាគនេះ។

### លទ្ធផល ២.១ ការដាក់ពិន្ទុលើការផ្តល់សេវាតាមវិស័យនានានៅសហគមន៍ត្រូវអនុវត្តប្រចាំឆ្នាំនៅក្នុងស្រុកគោលដៅនីមួយៗ

ប័ណ្ណដាក់ពិន្ទុចំពោះការផ្តល់សេវាតាមវិស័យនានានៅសហគមន៍ នឹងត្រូវអនុវត្តប្រចាំឆ្នាំនៅក្នុងស្រុកទាំងអស់ដែលបានកំណត់នៅក្នុងផែនការ។ នៅក្នុងស្រុកនីមួយៗមានការរំពឹងទុកថានឹងមានការចូលរួមពីប្រជាជនប្រហែល៨០០នាក់ (ក្នុងនោះ យ៉ាងហោចណាស់៥០%គឺជាស្ត្រី) មកចូលរួមក្នុងសិក្ខាសាលា[17] ។ ប័ណ្ណដាក់ពិន្ទុរាប់បញ្ចូលទាំងសាលារៀន មណ្ឌលសុខភាព រដ្ឋបាលឃុំ ស្រុក[18] និងសេវាផ្សេងៗទៀត ព្រមទាំងបញ្ហាអភិវឌ្ឍន៍ទាំងឡាយទៀតដែលជាអាទិភាពរបស់សហគមន៍។ ក្នុងស្រុកនីមួយៗ គេរំពឹងថាដៃគូអង្គការមិនមែនរដ្ឋាភិបាល នៅមូលដ្ឋានមួយ នឹងជួយគាំទ្រដល់អង្គការសហគមន៍មូលដ្ឋាន ផ្តល់ការបណ្តុះបណ្តាល និងផ្តល់យោបល់ណែនាំ ដល់អ្នកសម្របសម្រួលគណនេយ្យភាពនៅសហគមន៍ ដើម្បីដឹកនាំដំណើរការបំពេញតម្លៃលេខនៅក្នុងប័ណ្ណដាក់ពិន្ទុនោះ។ ប័ណ្ណដាក់ពិន្ទុ នឹងផ្តល់ឱ្យឃុំនីមួយៗ ទៅតាមចំនួនកំណត់នៅក្នុងផែនការ។ លទ្ធផលនៃការបំពេញប័ណ្ណដាក់ពិន្ទុ នឹងត្រូវបិទផ្សាយនៅតាម សាលាឃុំ សាលារៀន មណ្ឌលសុខភាព សម្រាប់ប្រជាពលរដ្ឋមើល។

---

[17] ទោះបីជាមានចំនួនទិន្នន័យច្រើនដែលអាចទទួលបានជាសាធារណៈក៏ដោយ ក៏ព័ត៌មានភាគច្រើន បានរៀបចំសម្រាប់តែធ្វើរបាយការណ៍ទៅ ថ្នាក់ជាតិតែប៉ុណ្ណោះ និងមិនមានភាពងាយស្រួលក្នុងការស្វែងរក និងទទួលបាននៅមូលដ្ឋានទេ។ នៅមានករណីផ្សេងទៀត ជាពិសេស នៅថ្នាក់មូលដ្ឋាន មានព័ត៌មានជាច្រើនដែលមិនមែនសុទ្ធតែមានប្រយោជន៍សម្រាប់ក្រុមប្រឹក្សា និងប្រជាពលរដ្ឋនោះទេ។ ជាទូទៅទិន្នន័យមិនបានរៀបចំ និងប្រមូលផ្តុំនៅថ្នាក់មូលដ្ឋានទេ រួមជាមួយគ្នានេះ ទម្លាប់ក្នុងការប្រមូលទិន្នន័យហាក់ដូចជាផ្តោតតែនៅថ្នាក់ខេត្តប៉ុណ្ណោះ។ ការគ្រប់គ្រងនិងការប្រមូលទិន្នន័យមិនទាន់បានធ្វើវិមជ្ឈការឲ្យបានពេញលេញទៅឲ្យថ្នាក់ស្រុកនៅឡើយ។ ទម្រង់និងការបង្ហាញព័ត៌មានមិនបានបង្កលក្ខណៈឲ្យមានការប្រៀបធៀបបានទេ។ដូច្នេះលទ្ធផល ១.១ នេះមានគោលដៅដើម្បីដោះស្រាយនូវភាពខ្វះខាតនេះ។

[18] នៅក្នុងដំណាក់កាលដំបូង ប័ណ្ណដាក់ពិន្ទុយ៉ាងហោចណាស់ត្រូវរួមបញ្ចូល សកម្មភាពរបស់ឃុំ មណ្ឌលសុខភាព និងសាលារៀន ដែលសុទ្ធសឹងជា កត្តាចម្បង។ សកម្មភាពអាទិភាពផ្សេងទៀតដែលសម្រេចដោយសហគមន៍ក៏អាចបន្ថែមពីលើសកម្មភាពខាងលើដែរ។ រដ្ឋបាលថ្នាក់ស្រុកត្រូវបានរំពឹងថា នឹងចាប់ផ្តើមអនុវត្តបន្តិចម្តងៗ អាស្រ័យទៅតាមការផ្ទេរហិរញ្ញវត្ថុតាមរយៈមូលនិធិស្រុក។

ដើម្បីគាំទ្រដល់ដំណើរការដាក់ពិន្ទុក្នុងប័ណ្ណ ត្រូវធ្វើការពង្រឹងសមត្ថភាព និងលើកកម្ពស់ការយល់ដឹង ។ សកម្មភាពទាំងនេះ មានរៀបរាប់នៅក្នុងសមាសភាគទី៣។

### លទ្ធផល ២.២ ផ្អែកតាមតម្រូវការរបស់សហគមន៍ បង្កើតឲ្យមានការត្រួតពិនិត្យតាមដានស៊ីជម្រៅ ដោយប្រជាពលរដ្ឋ ចំពោះសេវាកម្មមូលដ្ឋាននិងបញ្ហាជាក់លាក់មួយចំនួន

នៅពេលដែលបានបំពេញប័ណ្ណដាក់ពិន្ទុលើការផ្តល់សេវារបស់វិស័យនានា ដោយសហគមន៍រួចមក ត្រូវ បន្តការគាំទ្រដល់សហគមន៍ ឱ្យអាចធ្វើការវាយតម្លៃស៊ីជម្រៅ ទៅលើបញ្ហានិងសេវាកម្មទាំងឡាយណាដែលបានបង្ហាញនៅក្នុងប័ណ្ណដាក់ពិន្ទុថា ត្រូវមានការយកចិត្តទុកដាក់កាន់តែខ្លាំង។ ការត្រួតពិនិត្យតាមដានស៊ីជម្រៅ អាចធ្វើឡើងតាមទម្រង់ផ្សេងៗ អាស្រ័យទៅតាមបញ្ហា និងសមត្ថភាពរបស់ដៃគូអង្គការមិនមែន រដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន និងសមត្ថភាពអ្នកសម្របសម្រួល។ ឧទាហរណ៍ ប័ណ្ណដាក់ពិន្ទុបានលើកឡើងអំពីបញ្ហាមួយទាក់ទងទៅនឹងគុណភាពនៃសេវាសុខភាព ជាពិសេសបុគ្គលិកមណ្ឌលសុខភាព ដែលសហគមន៍ អាចស្នើឲ្យមានការត្រួតពិនិត្យដោយប្រជាពលរដ្ឋ ទៅលើការមិនមកធ្វើការរបស់បុគ្គលិកមណ្ឌលសុខភាពនោះ។ ប្រសិនបើបញ្ហាត្រូវបានរកឃើញទាក់ទងទៅនឹងការចាត់ចែងហិរញ្ញវត្ថុ នោះនឹងអាចមានការស្នើសុំឲ្យមានការធ្វើសវនកម្មសង្គម។ លទ្ធផលរកឃើញនឹងត្រូវបញ្ចូលទៅក្នុងកិច្ចប្រជុំរួមគ្នា និងសម្រាប់បញ្ចូលក្នុងផែនការផ.ស.គ.រ។ ចំពោះលទ្ធផលរកឃើញទាំងឡាយណាដែលពាក់ព័ន្ធក៏ត្រូវបញ្ចូលទៅក្នុងកញ្ចប់ព័ត៌មានI4Csសម្រាប់ឆ្នាំបន្ទាប់ទៀតផងដែរ។

## អនុសមាសភាគទី២ខ កិច្ចប្រជុំរួមគ្នា និងផែនការសកម្មភាពរួមគ្នា

នៅពេលបញ្ចប់កិច្ចការបំពេញប័ណ្ណដាក់ពិន្ទុ ជំហានបន្ទាប់គឺត្រូវរៀបចំកិច្ចប្រជុំរួមគ្នា ដើម្បីចែករំលែកលទ្ធផលរកឃើញជាមួយអ្នកពាក់ព័ន្ធនានានៅមូលដ្ឋាន (ដូចជា ប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សា មន្ត្រីស្រុក ឃុំ និងភូមិដែលបានជ្រើសរើស អ្នកគ្រប់គ្រងមណ្ឌលសុខភាព នាយកសាលា) ដើម្បីឯកភាពទៅលើវិធានការនានាដែលត្រូវដោះស្រាយចំពោះបញ្ហាទាំងនោះ។ ដំណើរការសម្រាប់កិច្ចប្រជុំរួមនេះ ហើយដែលនឹងត្រូវបញ្ចូលទៅក្នុងសៀវភៅណែនាំ រួមមានទិដ្ឋភាពសំខាន់ៗ ដូចខាងក្រោម៖

- ក្រុមប្រឹក្សា មន្ត្រីការិយាល័យអប់រំ និងការិយាល័យសុខាភិបាលស្រុក អ្នកផ្តល់សេវា ត្រូវចុះជួបប្រជាពលរដ្ឋ ជាជាងហៅប្រជាពលរដ្ឋឲ្យមកចូលរួមប្រជុំនៅការិយាល័យរបស់រដ្ឋ
- ការបង្ហាញអំពីលទ្ធផលត្រួតពិនិត្យរបស់ប្រជាពលរដ្ឋត្រូវបង្ហាញដោយប្រជាពលរដ្ឋ និងតំណាងអង្គការសហគមន៍មូលដ្ឋាន
- ស្ថាប័ន អង្គភាពរបស់រដ្ឋាភិបាលនៅមូលដ្ឋាន ត្រូវស្តាប់ និងឆ្លើយតបទៅកាន់ប្រជាពលរដ្ឋ
- ប្រជាពលរដ្ឋ នឹងពិភាក្សាពីកញ្ចប់ព័ត៌មានI4Cs ទាំងព័ត៌មានលើការបំពេញការងារ និងការងារថវិកា ក៏ដូចជាលទ្ធផលទទួលបានពីការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ
- លទ្ធផលនៃការវាយតម្លៃខ្លួនឯងរបស់អ្នកផ្តល់សេវា និងអនុសាសន៍នានាសម្រាប់ចាត់វិធានការកែលំអ
- កិច្ចប្រជុំរួមគ្នា ត្រូវកំណត់ពេលម៉ោងដើម្បីឲ្យលទ្ធផលនៃការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ បានទទួលយកដោយឃុំ ស្រុក និងបញ្ចូលក្នុងកម្មវិធីវិនិយោគប្រចាំឆ្នាំ។

- កិច្ចប្រជុំនេះ មានលក្ខណៈស្ថាបនា ដោយមានអ្នកជំនាញធ្វើការសម្របសម្រួលការពិភាក្សារវាងស្ថាប័នអង្គភាពរបស់រដ្ឋាភិបាល និងប្រជាពលរដ្ឋ។

**លទ្ធផលសំខាន់ៗនៃកិច្ចប្រជុំ នឹងបង្កើតបានផែនការសកម្មភាពគណនេយ្យភាពរួមគ្នា (ផ.ស.គ.រ)។** សមាសធាតុសំខាន់នៃផែនការផ.ស.គ.រ នឹងត្រូវបានយល់ព្រមនៅក្នុងកិច្ចប្រជុំ និងត្រូវត្រួតពិនិត្យតាមដានបន្តដោយគណៈកម្មការ ផ.ស.គ.រ ដែលដឹកនាំដោយ ក្រុមប្រឹក្សាឃុំ និងសមាសភាពផ្សេងៗទៀតដែលមានតំណាងមកពីសហគមន៍ ឃុំ សាលារៀន និងមណ្ឌលសុខភាព ក៏ដូចជាតំណាងមកពីរដ្ឋបាលស្រុក និងការិយាល័យជំនាញនានា។

១) សកម្មភាពរបស់**សហគមន៍**ដែលអាចធ្វើបានដោយខ្លួនឯង (ឧទាហរណ៍ ការសម្អាតបរិវេណមណ្ឌលសុខភាព ការតាមដានចំនួនម៉ោងបំពេញការងាររបស់បុគ្គលិកមណ្ឌលសុខភាព)
២) វិធានការដែល**អ្នកផ្តល់សេវា**នានា ត្រូវប្រកាន់យកដោយមានការកែប្រែថវិកាតិចតួច (ទាហរណ៍ សាលារៀន នាយកសាលាចាត់វិធានការលើការបង្រៀនរបស់គ្រូ បុគ្គលិកសុខាភិបាលប្រព្រឹត្តចំពោះអ្នកជម្ងឺដោយការគោរព និងការកែលំអអនាម័យ)
៣) សកម្មភាពរបស់**ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាស្រុក**។ សកម្មភាពទាំងនេះអាចធ្វើឡើងក្នុងរូបភាពពីរះ
    - ក) ជាអ្នកផ្តល់សេវា៖ ឃុំអាចចាត់វិធានការលើសេវាដែលខ្លួនផ្តល់ដល់ប្រជាពលរដ្ឋ (ដូចជាត្រូវធានាថា ត្រូវមានទម្រង់បែបបទចុះបញ្ជីអត្រានុកូលដ្ឋាន ដំណើរការកសាងផែនការឲ្យបានទូលំទូលាយ)
    - ខ) ជាអ្នកត្រួតពិនិត្យមើលះ ត្រូវទទួលខុសត្រូវក្នុងការកាត់បន្ថយភាពក្រីក្រ និងដោះស្រាយបញ្ហាផ្សេងៗនៅមូលដ្ឋាន។ គេរំពឹងថា ក្រុមប្រឹក្សាឃុំអាចធ្វើឲ្យមានការប្រែប្រួលការផ្តល់សេវានានា (សាលារៀន និងមណ្ឌលសុខាភាព) ឬស្នើសុំការគាំទ្រពីការិយាល័យស្រុក
៤) សកម្មភាពដែលត្រូវធ្វើដោយ**ការិយាល័យជំនាញថ្នាក់ស្រុក**។ ត្រូវមានសកម្មភាពគាំទ្រពីអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ (ឧទាហរណ៍ដូចជា ការស្នើសុំគ្រូបន្ថែម ស្នើសុំឱសថបន្ថែមសម្រាប់មណ្ឌលសុខភាព ការស្នើសុំផ្តល់វ៉ាក់សាំងផ្សេងៗ ជាដើម)។

គណៈកម្មាធិការនានានៅថ្នាក់មូលដ្ឋានត្រូវចូលរួមដើម្បីធានាថា សកម្មភាពដែលបានលើកឡើងនៅក្នុងផែនការផ.ស.គ.រ ត្រូវបានអនុវត្ត (ដូចជាក្រុមទ្រទ្រង់សុខភាពភូមិ[19] គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព គណៈកម្មាធិការទ្រទ្រង់សាលា និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ស្រុក[20]។ បទពិសោធន៍បង្ហាញថា ត្រូវមានការយកចិត្តទុកដាក់ និងមានផែនការសម្រាប់តាមដាន។ សកម្មភាពផ្តួចផ្តើម ពីមុនមួយចំនួនការត្រួតពិនិត្យដោយប្រជាពលរដ្ឋ ត្រូវបានអនុវត្តដោយជោគជ័យ ប៉ុន្តែការអនុវត្តផែនការដើម្បីកែលំអគឺនៅមានកម្រិតនៅឡើយ។ ជាការសំខាន់ណាស់ដែលការប្រាស្រ័យទាក់ទង និងឆ្លើយឆ្លងទៅវិញទៅមករវាងប្រជា

[19] ជាការសំខាន់ក្នុងការបង្កើតឲ្យមានការផ្សារភ្ជាប់រវាងការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម និងគោលនយោបាយរបស់ក្រសួងសុខាភិបាលស្តីពីការចូលរួមរបស់សហគមន៍។ គោលនយោបាយនេះអាចមានសារៈសំខាន់ក្នុងការផ្តល់ការណែនាំបុគ្គលិករបស់ក្រសួងសុខាភិបាល និងអ្នកផ្តល់សេវានានាទាក់ទងនឹងការចែករំលែកព័ត៌មាន ការបិទផ្សាយជាសាធារណៈនូវឯកសារសំខាន់ៗនានា ការចូលរួមរបស់បុគ្គលិកសុខាភិបាលក្នុងដំណើរការប័ណ្ណដាក់ពិន្ទុ និងការប្រជុំរួមគ្នា ការចូលរួមក្នុងការអនុវត្តផែនការសកម្មភាពរួម។ល។

[20] គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ចូលរួមដើម្បីជួយឲ្យសកម្មភាពនានាត្រូវបានយកចិត្តទុកដាក់លើការងារយុវវ័យ។

ពលរដ្ឋដែលជាអ្នកទទួលសេវា អ្នកផ្តល់សេវា និងអាជ្ញាធរមូលដ្ឋាន មិនត្រូវកម្រិតត្រឹមតែក្នុងកិច្ចប្រជុំរួមគ្នាទេ ប៉ុន្តែត្រូវមានការគាំទ្ររបស់គណៈកម្មាធិការត្រួតពិនិត្យតាមដានផែនការផ.ស.គ.រ បន្ថែមទៀត ។

គណៈកម្មាធិការត្រួតពិនិត្យផែនការសកម្មភាព (ផ.ស.គ.រ) ត្រូវធានាថាលទ្ធផលបានមកពីប័ណ្ណដាក់ពិន្ទុ និងលទ្ធផលរបស់ផ.ស.គ.រ ត្រូវបានដាក់បញ្ចូលនៅក្នុងផែនការវិនិយោគឃុំ ហើយចំពោះការរកឃើញ ណាខ្លះដែលពាក់ព័ន្ធ ត្រូវយកទៅបង្ហាញនៅក្នុងសមាហរណកម្មថ្នាក់ស្រុក។

លទ្ធផលខាងក្រោមត្រូវមានចាំបាច់សម្រាប់អនុសមាសភាគនេះ។

**លទ្ធផល ២.៣ កិច្ចប្រជុំរួមគ្នាត្រូវបានដំណើរការ ហើយផ.ស.គ.រ ត្រូវបានរៀបចំ**

បន្ទាប់ពីបញ្ចប់ការបំពេញប័ណ្ណដាក់ពិន្ទុលើសេវាវិស័យនានា អង្គការមិនមែនរដ្ឋាភិបាលធ្វើការងារ ជាមួយអង្គការសហគមន៍ជាដៃគូនៅមូលដ្ឋាន រួមជាមួយនឹងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ធ្វើការរៀបចំប្រមូលលទ្ធផលដែលបានមកពីប័ណ្ណដាក់ពិន្ទុ(កម្រិតភូមិ) និងបង្ហាញលទ្ធផលតាមទម្រង់ដែលសាមញ្ញ និងងាយស្រួលក្នុងការប្រើប្រាស់។ លទ្ធផលទាំងនេះនឹងត្រូវបង្ហាញក្នុងកិច្ចប្រជុំប្រចាំឆ្នាំ (ដែលធ្វើឡើងក្នុងភូមិណាមួយ) នៅមុនពេលវដ្តនៃការធ្វើផែនការឃុំ។ ដើម្បីឲ្យដំណើរការនេះមានប្រសិទ្ធភាព ទាមទារឲ្យមានការចងក្រងប្រជាពលរដ្ឋ និងខិតខំប្រឹងប្រែងកសាងសមត្ថភាពជាច្រើន (សូមមើលសមាសភាគទី៣)។ រាល់សកម្មភាពទាំងអស់ ត្រូវព្យាយាមឲ្យមានចំនួនប្រកបដោយសមធម៌រវាងស្ត្រី និងយុវវ័យ ព្រមទាំងបញ្ចូលបញ្ហាយុវវ័យ និងក្រុមអាយុផ្សេងៗនៅក្នុងនោះផងដែរ។

កិច្ចប្រជុំរួមគ្នាសម្រេចបានជាផែនការសកម្មភាព ផ.ស.គ.រ។ ផែនការនេះនេះរៀបរាប់ពីអ្វីខ្លះ ដែលសហគមន៍ និងអ្នកពាក់ព័ន្ធនានានៅមូលដ្ឋានអាចធ្វើបាន និងអ្វីដែលនឹងត្រូវធ្វើ ដើម្បីលើកកម្ពស់គុណភាព និងភាពងាយស្រួលទទួលបានសេវាសាធារណៈ។ ផែនការសកម្មភាព ផ.ស.គ.រ ជាលទ្ធផលនៃការប្តេជ្ញាចិត្តរបស់ប្រជាពលរដ្ឋ និងស្ថាប័ន អង្គភាពរបស់រដ្ឋ ក្នុងការដាក់ចេញវិធានការជាក់លាក់ដើម្បីសម្រេចបាននូវលទ្ធផលជាវិជ្ជមាន។ អង្គការដទៃទៀត ត្រូវយល់ព្រមទទួលយកផែនការសកម្មភាព ផ.ស.គ.រ ដើម្បីអនុវត្ត។ ទម្រង់បែបបទនៃផែនការ ផ.ស.គ.រ នឹងត្រូវសាកល្បង និងបញ្ចូលទៅក្នុងសៀវភៅណែនាំ ប៉ុន្តែផែនការនេះត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយដែលមានសកម្មភាពសំខាន់៤គឺ៖

១) សកម្មភាពរបស់សហគមន៍ដែលអាចធ្វើបានដោយខ្លួនឯង (ឧទាហរណ៍ ការសម្អាតបរិវេណមណ្ឌលសុខភាព ការតាមដានចំនួនម៉ោងបំពេញការងាររបស់បុគ្គលិកមណ្ឌលសុខភាព)

២) វិធានការដែលអ្នកផ្តល់សេវានានាត្រូវប្រកាន់យក ដោយមានការកែប្រែថវិកាតិចតួច (ឧទាហរណ៍ សាលារៀន នាយកសាលាចាត់វិធានការលើការបង្រៀនរបស់គ្រូ បុគ្គលិកសុខាភិបាលប្រព្រឹត្តចំពោះអ្នកជម្ងឺដោយការគោរព និងការកែលំអរអនាម័យ

៣) សកម្មភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាស្រុក។ សកម្មភាពទាំងនេះអាចធ្វើឡើងក្នុងរូបភាពពីរ៖

ក) ជាអ្នកផ្តល់សេវា៖ ឃុំអាចចាត់វិធានការលើសេវាដែលខ្លួនផ្តល់ដល់ប្រជាពលរដ្ឋ (ដូចជាត្រូវធានាថាត្រូវមានទម្រង់បែបបទចុះបញ្ជីអត្រានុកូលដ្ឋាន ដំណើរការកសាងផែនការឲ្យបានទូលំទូលាយ)

៣) ជាអ្នកត្រួតពិនិត្យមើលៈ ត្រូវទទួលខុសត្រូវក្នុងការកាត់បន្ថយភាពក្រីក្រ និងដោះស្រាយបញ្ហាផ្សេងៗនៅមូលដ្ឋាន។ គេរំពឹងថាក្រុមប្រឹក្សាឃុំអាចធ្វើឲ្យមានការប្រែប្រួលនូវសេវានានា (សាលារៀន និងមណ្ឌលសុខាភាព) ឬស្នើសុំការគាំទ្រពីការិយាល័យស្រុក

៤) សកម្មភាពដែលត្រូវធ្វើដោយ**ការិយាល័យជំនាញថ្នាក់ស្រុក**។ ត្រូវមានការគាំទ្រពីអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ (ឧទាហរណ៍ ការស្នើសុំគ្រូបន្ថែម ការស្នើសុំឱសថបន្ថែមសម្រាប់មណ្ឌលសុខភាព និងការស្នើផ្តល់វ៉ាក់សាំងផ្សេងៗ ជាដើម)។

**លទ្ធផល ២.៤ ផែនការសកម្មភាព ផ.ស.គ.រ ត្រូវបានផ្សព្វផ្សាយ និងអនុវត្ត**

នៅពេលព្រមព្រៀងគ្នារួចហើយ សកម្មភាពទាំងឡាយដែលមានក្នុងផែនការ ផ.ស.គ.រ នឹងត្រូវអនុវត្តដោយប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សាលារៀន និងមណ្ឌលសុខភាព រួមទាំងមន្ត្រីជំនាញតាមស្រុកដែលពាក់ព័ន្ធ។ ដំបូងអ្នកសម្របសម្រួលគណនេយ្យភាពតាមសហគមន៍ និងអង្គការសហគន៍មូលដ្ឋានជាដៃគូ នឹងធ្វើការជាមួយសហគមន៍ដើម្បីផ្តល់ព័ត៌មានដល់ពួកគេអំពីខ្លឹមសារនៃផែនការផ.ស.គ.រ និងសារៈសំខាន់ក្នុងការចូលរួមវាយតម្លៃការអនុវត្ត។ បន្ទាប់មក ត្រូវផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋឲ្យកាន់តែទូលាយអំពីដំណើរការនេះ អ្នកសម្របសម្រួលគណនេយ្យភាពសង្គមតាមមូលដ្ឋាន និងអង្គការសហគមន៍មូលដ្ឋាន រួមជាមួយក្រុមប្រឹក្សាឃុំ និងអង្គការដៃគូ នឹងបង្ហាញលទ្ធផលនៃប័ណ្ណដាក់ពិន្ទុរបស់ប្រជាពលរដ្ឋ និងផែនការផ.ស.គ.រនៅមូលដ្ឋាន រួមទាំងការផ្សព្វផ្សាយព័ត៌មាននៅថ្នាក់ស្រុក (ដូចជា ការផ្តល់ដល់សារព័ត៌មានការសម្ភាសន៍ផ្សេងៗ)។

**លទ្ធផល ២.៥ គណៈកម្មការតាមដាន ត្រូវបានបង្កើតដើម្បីត្រួតពិនិត្យការអនុវត្ត"ផ.ស.គ.រ"**

ការអនុវត្តសកម្មភាពនៅក្នុងផែនការ **ផ.ស.គ.រ** នឹងត្រូវត្រួតពិនិត្យដោយ "គណៈកម្មការតាមដាន" រួមគ្នាមួយដែលរៀបចំ និងដឹកនាំកិច្ចប្រជុំដោយក្រុមប្រឹក្សាឃុំ ព្រមទាំងមានតំណាងមកពីភាគីសំខាន់ៗដែលពាក់ព័ន្ធផ្សេងៗ។ ទស្សនកិច្ចសិក្សា និងកិច្ចប្រជុំ នឹងត្រូវរៀបចំតាមជាក់ស្តែង (អាស្រ័យលើសកម្មភាពដែលបានឯកភាព សមាជិកគណៈកម្មការតាមដានផែនការ **ផ.ស.គ.រ** នឹងផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ និងអង្គការសហគមន៍អំពីការអនុវត្តអនុសាសន៍របស់ពួកគាត់)។ សកម្មភាពទាំងឡាយណាដែលតម្រូវឲ្យមានការប្រើប្រាស់ថវិកា ត្រូវមានការពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគឃុំ ឬថវិកាសាលារៀន ថវិកាមណ្ឌលសុខភាព និងក្នុងកម្មវិធីរបស់ការិយាល័យស្រុក។ ផែនការ**ផ.ស.គ.រ** នឹងត្រូវយកទៅបង្ហាញនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ដើម្បីទាក់ទាញការគាំទ្រពីភ្នាក់ងារមិនមែនរដ្ឋាភិបាល[21]។

---

[21] សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ក៏ជាវេទិកាមួយដែលអាចឲ្យសហគមន៍អាចស្វែងរកការគាំទ្រចំពោះការបំពេញប័ណ្ណដាក់ពិន្ទុដែលមាន លក្ខណៈស៊ីជម្រៅ ។

## អនុសមាសភាគទី២គ ការរៀបចំលិខិតបទដ្ឋាននានាដើម្បីគាំទ្រការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងការពិនិត្យមើលពីលើរបស់សមាជិកក្រុមប្រឹក្សា

ដោយសារតែសមាជិកក្រុមប្រឹក្សាឃុំកើតឡើងដោយការបោះឆ្នោត និងជាតំណាងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ពួកគេមានតួនាទីជាអ្នកដឹកនាំដ៏សំខាន់នៅក្នុងសកម្មភាពគណនេយ្យភាពសង្គមនៅមូលដ្ឋាន។ សកម្មភាពគណនេយ្យភាពសង្គមត្រូវបានអនុវត្តសាកល្បងទូទាំងប្រទេសកម្ពុជា ហើយតាមរយៈបទពិសោធន៍នៃការអនុវត្តបានបង្ហាញថា នៅពេលសមាជិកក្រុមប្រឹក្សាឃុំមានទំនុកចិត្តក្នុងការធ្វើអន្តរាគមន៍ និងធ្វើឲ្យមានការប្រែប្រួល នោះប្រសិទ្ធភាពនឹងទទួលបានច្រើន។ សមាសភាពនេះ ផ្តល់ការគាំទ្រដើម្បីរៀបចំតួនាទី និងពង្រឹងសមត្ថភាពក្នុងការ ត្រួតពិនិត្យតាមដាន។

**ទំនាក់ទំនងរវាងគណនេយ្យភាពផ្នែកសង្គម និងផ្នែកនយោបាយមានសារៈសំខាន់ណាស់។** ក្នុងនាមជាអ្នកតំណាងដែលកើតឡើងដោយការបោះឆ្នោត សមាជិកក្រុមប្រឹក្សាឃុំមានតួនាទីត្រួតពិនិត្យមើលការងារក្នុងឃុំរបស់ខ្លួន ហើយផ្អែកតាមអាណត្តិការងារដែលខ្លួនមាន សមាជិកក្រុមប្រឹក្សាឃុំ អាចត្រួតពិនិត្យរាល់បញ្ហាផ្តល់សេវានានាដែលប៉ះពាល់ដល់សហគមន៍។ សកម្មភាពគណនេយ្យភាពសង្គម ត្រូវបំពេញឲ្យគ្នាទៅវិញទៅមក ដើម្បីឲ្យប្រព័ន្ធទាំងមូលកាន់តែមានគណនេយ្យភាព។ ទោះបីជាសេវាទាំងនេះ បានផ្តល់តាមរយៈ ក្រសួងជំនាញ ក៏ដោយ ក៏ឃុំត្រូវដើរតួនាទីយ៉ាងសំខាន់ ក្នុងនាមខ្លួនជាអ្នកតំណាងដែលជ្រើសតាំងតាមរយៈការបោះឆ្នោត ហើយដែលត្រូវមានអាណត្តិការងារកាត់បន្ថយភាពក្រីក្រ និងរៀបចំកិច្ចអភិវឌ្ឍសេដ្ឋកិច្ច[22]របស់ខ្លួន។

### លទ្ធផល២.៦ ប្រកាស និងសេចក្តីណែនាំស្តីពីតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ ត្រូវបានតាក់តែង អនុម័ត និងអនុវត្ត

ជាការសំខាន់ណាស់ដែលសកម្មភាពគណនេយ្យភាពសង្គម (ដូចជា កិច្ចប្រជុំរួមគ្នា) ក្លាយជានីតិវិធីធម្មតារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មណ្ឌលសុខភាព និងសាលារៀន។ ដូច្នេះត្រូវរៀបចំជាប្រកាសដើម្បីឲ្យ រដ្ឋបាលមូលដ្ឋាន និងអ្នកផ្តល់សេវានានា ផ្តល់ការគាំទ្រនិងចូលរួមដោយសកម្មនៅក្នុងដំណើរការនេះ ព្រមទាំង ទទួលបានការណែនាំ (ការបណ្តុះបណ្តាល) អំពីរបៀបអនុវត្តការងារនោះ។ សេចក្តីណែនាំ និងនីតិវិធីនឹងត្រូវបញ្ចូលទៅក្នុងសៀវភៅណែនាំ។

### លទ្ធផល២.៧ ក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តិសម្រាប់ការត្រួតពិនិត្យរបស់ឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌលើការផ្តល់សេវាមូលដ្ឋាន ត្រូវបានកែសម្រួល

លិខិតបទដ្ឋានគតិយុត្ត (ប្រកាស) នឹងត្រូវរៀបចំនិងបញ្ជាក់នូវមុខងារនិងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាស្រុក ក្នុងការត្រួតពិនិត្យមើលលើការផ្តល់សេវានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន [23] ព្រមទាំងតួនាទី

---

[22] នៅថ្នាក់ស្រុក ទោះបីនីតិវិធីក្នុងការអនុវត្តមិនទាន់បង្កើតឡើងនៅឡើយ តែតួនាទីក្នុងការត្រួតពិនិត្យ និងមើលពីលើអំពីការផ្តល់សេវារបស់រដ្ឋត្រូវប្រគល់ឲ្យគណៈអភិបាលស្រុកដែលដើរតួតំណាងថ្នាក់ជាតិ។ ការិយាល័យអន្តរវិស័យស្រុកទទួលខុសត្រូវក្នុងការសម្របសម្រួលរវាងក្រសួងជំនាញ និងគម្រោង អភិវឌ្ឍន៍ ក៏ដូចជាជួយដោះស្រាយបញ្ហាផ្សេងៗ ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ មាត្រា១៥៤នៃច្បាប់រៀបចំអង្គការចែងថា "អភិបាលមានតួនាទីជាតំណាងក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីណែនាំសម្របសម្រួល តម្រង់ទិសមន្ទីរអង្គភាពខ្សែបណ្តោយរបស់ក្រសួងស្ថាប័ននិងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ អភិបាលត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការងារសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់និងសិទ្ធិមនុស្ស ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុង តួនាទីជាតំណាងរាជរដ្ឋាភិបាល ក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល អភិបាលត្រូវមាន គណនេយ្យភាពចំពោះ រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃនិងក្រសួងស្ថាប័ននានា។

[23] ទោះបីឃុំមានអាណត្តិរបស់ខ្លួនក៏ដោយ ត្រូវមានការបញ្ជាក់ឲ្យបានច្បាស់លាស់ដើម្បីជួយឲ្យឃុំអាចចូលរួមក្នុងដំណើការគណនេយ្យភាពសង្គម។

ប្រជាពលរដ្ឋនៅក្នុងការដំណើរការត្រួតពិនិត្យ[24] ។ នៅក្នុងដំណើរការនេះ គេរំពឹងថា គ.ជ.អ.ប នឹងជួលទីប្រឹក្សាជំនាញ ដើម្បីរៀបចំសេចក្តីព្រាងប្រកាសមុននឹងអនុវត្ត។

## អនុសមាសភាគទី២យ ការលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាព

សកម្មភាពលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាពនៅថ្នាក់ស្រុក មានក្នុងសមាសភាគទី២។

### លទ្ធផល ២.៨ កម្មវិធីបណ្តុះបណ្តាល ការផ្តល់យោបល់ណែនាំ និងការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ត្រូវបានអនុវត្ត

លទ្ធផលនេះ អង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋានជាដៃគូ នឹងធ្វើការបណ្តុះបណ្តាលអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។ ការបណ្តុះបណ្តាលអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ មានរយៈពេល ១០ខែ និងមានវគ្គបណ្តុះបណ្តាលចំនួន៤ ដែលក្នុងមួយវគ្គៗមានចំនួន៦ថ្ងៃ។ វគ្គបណ្តុះបណ្តាល ទាំងនោះមានបញ្ចូលទាំងរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ (ដូចជា ការអនុវត្តសកម្មភាពកម្មវិធីផ្សេងៗ រួមមាន ការយល់ដឹងពីកញ្ចប់ព័ត៌មានI4Cs ការបំពេញប័ណ្ណដាក់ពិន្ទុចំពោះផ្តល់សេវារបស់វិស័យនានា ការសម្របសម្រួលកិច្ចប្រជុំរួមគ្នា...។ល។)។ អ្នកសម្របសម្រួលសហគមន៍ នឹងត្រូវរៀនសូត្រពីរបៀបក្នុងការជួយប្រជាពលរដ្ឋឲ្យទទួលបាននូវពត័មានសំខាន់ៗ និងរៀនពីរបៀបសម្របសម្រួលការអនុវត្តគណនេយ្យភាពសង្គម ការសម្របសម្រួលប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋ និងរដ្ឋបាលមូលដ្ឋាន ព្រមទាំងអ្នកផ្តល់សេវានានា។ នៅចុងបញ្ចប់នៃការអនុវត្តកម្មវិធី នៅស្រុកគោលដៅនីមួយៗ[25] នឹងមានអ្នកសម្របសម្រួលដែលទទួលការ បណ្តុះបណ្តាលត្រឹមត្រូវចំនួនពី៣៥នាក់ទៅ៤០នាក់ ដែលអាចផ្តល់ការគាំទ្រជាប្រចាំចំពោះសកម្មភាពការងារ គណនេយ្យភាពសង្គម[26]។

### លទ្ធផល ២.៩ ការលើកកម្ពស់ការយល់ដឹងអំពីការងារត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ និងការរៀបចំ ផ.ស.គ.រ សម្រាប់អង្គការសហគមន៍មូលដ្ឋាន សហគមន៍និងប្រជាពលរដ្ឋ

តួនាទីចម្បងរបស់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ គឺត្រូវជួយសមាជិកសហគមន៍ឲ្យបានចូលរួមក្នុងដំណើរការគណនេយ្យភាពសង្គម។ តួនាទីនេះរួមមានសកម្មភាពមួយចំនួនក្នុងការលើកកម្ពស់ការយល់ដឹង និងការកសាងសមត្ថភាពដល់ប្រជាពលរដ្ឋ និងអង្គការសហគមន៍មូលដ្ឋាន ដូចជាណែនាំ និងសម្របសម្រួលឲ្យមានការចូលរួមដោយសកម្មនៅក្នុងដំណើរការត្រួតពិនិត្យ និងគណនេយ្យភាពសង្គម។ សកម្មភាពនេះត្រូវពាក់ព័ន្ធជាមួយនឹងការចែករំលែកពត័មាននៅថ្នាក់មូលដ្ឋាន (រួមទាំងការយល់ដឹងពីសិទ្ធិ) ការពិភាក្សាដើម្បី ជួយសមាជិកសហគមន៍ឲ្យបានយល់ដឹងពីគោលការណ៍ និងការអនុវត្តគណនេយ្យភាពសង្គម ការបំពេញប័ណ្ណដាក់ពិន្ទុរបស់សហគមន៍ និងការគាំទ្រសម្រាប់ការប្រជុំរួមគ្នា ។ សកម្មភាពទាំងនេះ ត្រូវធ្វើឡើងជាប្រចាំរយៈពេលពេញមួយឆ្នាំ។

---

[24] នៅពេលដែលប្រកាសត្រូវបានរៀបចំរួចរាល់ សៀវភៅណែនាំក្នុងការអនុវត្ត និងប្រព័ន្ធដែលមានស្រាប់នឹងអាចធ្វើការកែសម្រួលប្រសិនចាំបាច់។

[25] តាមរយៈបទពិសោធន៍ទាំងឡាយបានបង្ហាញថា ការបណ្តុះបណ្តាលរួមគ្នារវាងអង្គភាពរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលមានអត្ថប្រយោជន៍ច្រើន ដោយសារតែ វិធីនេះអាចជួយឱ្យពួកគេបានលើកកម្ពស់ការយល់ដឹង និងកសាងទំនុកចិត្ត ព្រមទាំងពង្រឹងទំនាក់ទំនងការងារទៅវិញទៅមក។ ក្នុងនោះផងដែរការបណ្តុះបណ្តាល នឹងផ្តោតលើការពង្រឹងនូវសម្លេងរួមគ្នា និងផ្តោតទៅលើក្រុមស្ត្រី យុវវ័យ និងក្រុមភាគតិចផ្សេងទៀត។

[26] ក្នុងសមាសភាគទី៣ ដៃគូដែលមានជំនាញ នឹងផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្គោលដែលជាបុគ្គលិកមកពី អង្គការមិនមែនរដ្ឋាភិបាល ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដែលមានតួនាទីផ្តល់ការបណ្តុះបណ្តាលបន្តទៅឲ្យអ្នកសម្របសម្រួលគណនេយ្យភាពនៅសហគមន៍ ។

**លទ្ធផល ២.១០ ការបណ្តុះបណ្តាល អំពីការរៀបចំផ.ស.គ.រ ការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងមុខងារត្រួតពិនិត្យមើលពីលើ នឹងរៀបចំធ្វើឡើងសម្រាប់មន្ត្រីមូលដ្ឋាន និងអ្នកផ្តល់សេវាមូលដ្ឋាន**

សកម្មភាពគណនេយ្យភាពសង្គម បានផ្តល់ឱកាសពង្រឹងសមត្ថភាពដល់បុគ្គល និងស្ថាប័ននានានៅថ្នាក់ឃុំ និងស្រុក ដែលជាអ្នកត្រួតពិនិត្យលើការផ្តល់សេវា។ លទ្ធផលនេះ គឺការផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ មូលដ្ឋាន (រួមមាន សមាជិកក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីសំខាន់ៗ) និងបុគ្គលិកដែលជាអ្នកផ្តល់សេវា។ ម្យ៉ាងទៀត វគ្គបណ្តុះបណ្តាលគណនេយ្យភាពសង្គមនៅមូលដ្ឋាន នឹងផ្តល់ចំពោះអង្គភាពរដ្ឋាភិបាល ផងនិងមិនមែនរដ្ឋាភិបាលផង ដើម្បីឲ្យមានការយល់គ្នា និងពង្រឹងនូវទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធសំខាន់ៗ ទាំងឡាយ។

**សមិទ្ធិផលនៅក្នុងសមាសភាគទី២ មានដូចជា៖ ប្រជាពលរដ្ឋ នឹងចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការ ត្រួតពិនិត្យការបំពេញការងារ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវានៅមូលដ្ឋាន ដោយសហការជាមួយស្ថាប័ននិងអង្គភាពរបស់រដ្ឋាភិបាល ក្នុងការរៀបចំផែនការសកម្មភាពដែលនឹងនាំទៅរកការអនុម័ត និងអនុវត្តសកម្មភាពដែលមានក្នុងផែនការសកម្មភាព និងថវិកា។** សមាសភាគនេះនឹងប្រើប្រាស់ប័ណ្ណដាក់ពិន្ទុ របស់សហគមន៍ ដើម្បីត្រួតពិនិត្យនិងធ្វើរបាយការណ៍ អំពីសេវាមូលដ្ឋាន និងការបំពេញការងាររបស់រដ្ឋាភិបាល។ កិច្ចប្រជុំរួមគ្នារវាងប្រជាពលរដ្ឋ (សង្គមស៊ីវិល) និងរដ្ឋបាលមូលដ្ឋាន ត្រូវរៀបចំឡើងដើម្បីបង្ហាញអំពីលទ្ធផល ដែលបានរកឃើញ និងដាក់ចេញជាវិធានការដោះស្រាយនានា ដោយដាក់បញ្ចូលទៅក្នុងផ.ស.គ.រ។ មានការបណ្តុះបណ្តាល ការប្រឹក្សាយោបល់ និងការអភិវឌ្ឍសមត្ថភាព ដែលត្រូវផ្តល់ឲ្យអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដែលធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលដៃគូនៅមូលដ្ឋាន ដើម្បីលើកកម្ពស់ការយល់ដឹង និងសមត្ថភាពរបស់អ្នកពាក់ព័ន្ធនៅមូលដ្ឋាន។ មន្ត្រីរដ្ឋបាលស្រុក នឹងទទួលបានការបណ្តុះបណ្តាល សម្រាប់ធ្វើការបណ្តុះបណ្តាលបន្ត ដល់បុគ្គលិករដ្ឋបាលថ្នាក់ឃុំ។ មុខងាររបស់ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ ត្រូវបានពង្រឹងក្នុងផ្នែកត្រួត ពិនិត្យការផ្តល់សេវាកម្មនៅមូលដ្ឋាន។

**តារាងសង្ខេបសមាសភាគទី២ ការត្រួតពិនិត្យដោយប្រជាពលរដ្ឋ**

| ផ្នែក | ការរៀបរាប់ |
|---|---|
| គោលបំណង | បង្កើតឲ្យមានការត្រួតពិនិត្យនិងរាយការណ៍ ដោយប្រជាពលរដ្ឋនិងអ្នកប្រើប្រាស់សេវា ចំពោះ ការបំពេញមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាកម្មនានានៅមូលដ្ឋាន។ |
| អនុសមាសភាគ | **២ក. ការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ**<br>**លទ្ធផល២.១** ការដាក់ពិន្ទុលើការផ្តល់សេវាតាមវិស័យនានានៅសហគមន៍ត្រូវអនុវត្តប្រចាំឆ្នាំនៅក្នុងស្រុកគោលដៅនីមួយៗ<br>**លទ្ធផល ២.២** ផ្អែកតាមតម្រូវការរបស់សហគមន៍ បង្កើតឲ្យមានការត្រួតពិនិត្យ តាមដាន ស៊ីជម្រៅដោយប្រជាពលរដ្ឋ ចំពោះសេវាកម្មមូលដ្ឋាន និងបញ្ហាជាក់លាក់មួយចំនួន<br>**២ខ. កិច្ចប្រជុំរួមគ្នា និងផែនការសកម្មភាពរួមគ្នា**<br>**លទ្ធផល ២.៣** កិច្ចប្រជុំរួមគ្នាត្រូវបានដំណើរការ ហើយផរ.គ.ស. ត្រូវបានរៀបចំ<br>**លទ្ធផល ២.៤** ផែនការសកម្មភាព ផ.ស.គ.រ ត្រូវបានផ្សព្វផ្សាយ និងអនុវត្ត |

លទ្ធផល ២.៥ គណៈកម្មការតាមដានត្រូវបានបង្កើតដើម្បីត្រួតពិនិត្យការអនុវត្ត "ផ.ស.គ.រ"

**២គ. ការរៀបចំលិខិតបទដ្ឋាននានាដើម្បីគាំទ្រការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងការពិនិត្យមើលពីលើរបស់សមាជិកក្រុមប្រឹក្សា**

**លទ្ធផល២.៦** ប្រកាសនិងសេចក្តីណែនាំស្តីពីតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ ត្រូវបានតាក់តែង អនុម័ត និងអនុវត្ត

**លទ្ធផល២.៧** ក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តិសម្រាប់ការត្រួតពិនិត្យរបស់ឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ លើការផ្តល់សេវាមូលដ្ឋាន ត្រូវបានកែសម្រួល

**២ឃ. ការលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាព**

**លទ្ធផល ២.៨** កម្មវិធីបណ្តុះបណ្តាល ការផ្តល់យោបល់ណែនាំ និងការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ ជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ត្រូវបានអនុវត្ត

**លទ្ធផល ២.៩** ការលើកកម្ពស់ការយល់ដឹងអំពីការងារត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ និងការរៀបចំ ផរ សម្រាប់អង្គការសហគមន៍មូលដ្ឋាន សហគមន៍និងប្រជា.គ.ស. ពលរដ្ឋ

**លទ្ធផល ២.១០** ការបណ្តុះបណ្តាល អំពីការរៀបចំផរ ការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និង.គ.ស. មុខងារត្រួតពិនិត្យមើលពីលើនឹងរៀបចំធ្វើឡើងសម្រាប់មន្ត្រីមូលដ្ឋាន និងអ្នកផ្តល់សេវាមូលដ្ឋាន

# សមាសភាគទី៣

# ការសម្របសម្រួល និងការពង្រឹងសមត្ថភាព

សមាសភាគនេះមានគោលបំណងកំណត់នឹងជំរុញឱ្យមានការចូលរួម ពីស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនានា ព្រមទាំងបណ្តុះបណ្តាលជំនាញសម្របសម្រួលដំណើរការចូលរួម និងគណនេយ្យភាពសង្គម។ សមាសភាគនេះ រៀបរាប់ពីសកម្មភាពនានាដែលបានកំនត់នៅក្នុងសមាសភាគទី១ និងទី២ និងពីរបៀបដែលសកម្មភាពទាំងនេះត្រូវបានគាំទ្រដោយមានការចូលរួមពីថ្នាក់មូលដ្ឋាន និងមានការសម្របសម្រួលពីអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងកំណត់អំពីវិធីសាស្ត្រក្នុងការកសាងសមត្ថភាព ដូចដែលបានរំពឹងទុកនៅក្នុងដំណើរការគណនេយ្យភាពសង្គមរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល។

**គណនេយ្យភាពសង្គមទាមទារឲ្យមានការតាំងចិត្ត និងសមត្ថភាពពីសំណាក់ស្ថាប័នរដ្ឋ សង្គមស៊ីវិល និងឯកជនដើម្បីមានទំនាក់ទំនងជាមួយគ្នា តាមរយៈភាពជាដៃគូគណនេយ្យភាពថ្មី។** ជាប្រការសំខាន់ ដែលអង្គភាពរបស់រដ្ឋ និងអ្នកផ្តល់សេវានានាត្រូវយល់ដឹង និងទទួលយកនូវអ្វីដែលជាតួនាទីរបស់ខ្លួនក្នុងការឆ្លើយតប និងមានគណនេយ្យភាពទៅកាន់ប្រជាពលរដ្ឋទៅតាមអាណត្តិការងាររបស់ខ្លួនដែលត្រូវបំពេញ។ ចំណែក ប្រជាពលរដ្ឋវិញត្រូវយល់ថាពួកគេមានសិទ្ធិ និងតួនាទីដឹងឮអំពីកិច្ចការនៅមូលដ្ឋាន ចូលរួមនៅក្នុងកិច្ចការសាធារណៈ ហើយរំពឹងថានឹងទាមទារឲ្យមានគណនេយ្យភាពពីមន្ត្រីសាធារណៈ។

**គណនេយ្យភាពសង្គម មានគោលបំណងក្នុងការពង្រឹងការយល់ដឹង ការជឿទុកចិត្ត និងការចូលរួមប្រកបដោយការស្តាបនារវាងស្ថាប័នរដ្ឋ សង្គមស៊ីវិល និងឯកជន។** មធ្យោបាយពង្រឹងគណនេយ្យភាពសង្គមមានគោលបំណងបង្កើតឲ្យមានទំនាក់ទំនងការងារប្រកបដោយលទ្ធផលរវាងប្រជាពលរដ្ឋ និងស្ថាប័នរដ្ឋ ដោយផ្អែកលើគោលការណ៍នៃការគោរពគ្នាទៅវិញទៅមក ។ ការសហការគ្នាពិតប្រាកដ មានន័យថាជាការស្វែងរកកិច្ចសហការគ្នា ជាជាងការប្រឈមមុខដាក់គ្នា។ គេត្រូវទទួលស្គាល់នូវតួនាទីស្របច្បាប់របស់ប្រជាពលរដ្ឋ និងសង្គមស៊ីវិលក្នុងការចោទជាសំណួរ និងផ្តល់យោបល់ទៅលើសកម្មភាព និងការសម្រេចចិត្តរបស់មន្ត្រី សាធារណៈ និងអ្នកផ្តល់សេវានានា។ គោលបំណងសំខាន់មួយទៀត គឺត្រូវលើកកម្ពស់ការចូលរួមរបស់ក្រុមប្រជាពល រដ្ឋនានាដោយគិតអំពី ភេទ អាយុ ស្ថានភាពជីវភាព ព្រោះថាជារឿយៗ ពួកគាត់មិនសូវបានចូលរួមក្នុងដំណើរការសម្រេចចិត្ត និងអភិបាលកិច្ចឡើយ (ដូចជា ស្ត្រី យុវវ័យ និងក្រុមប្រជាពលរដ្ឋក្រីក្រ)។

**គណនេយ្យភាពសង្គមពាក់ព័ន្ធនឹងការបង្កើតឲ្យមានមធ្យោបាយ និងយន្តការដែលមានការសម្របសម្រួលសម្រាប់ការចូលរួមប្រកបដោយន័យស្ថាបនារវាងស្ថាប័នរដ្ឋ សង្គមស៊ីវិល និងឯកជន ។** ដើម្បីឲ្យការចូលរួមប្រកបដោយប្រសិទ្ធភាព ទីកន្លែង(សម្រាប់រៀបចំព្រឹត្តិការណ៍ និងកិច្ចប្រជុំនានា) ត្រូវមាន "*សុវត្ថិភាព*" និងទូលាយ។ អ្នកចូលរួមទាំងអស់ (ទាំងរដ្ឋាភិបាលនិងសង្គមស៊ីវិល) ត្រូវទទួលបាននូវព័ត៌មានដែលពាក់ព័ន្ធ ព្រមទាំងមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមខ្លួនដោះស្រាយ។ អ្នកសម្របសម្រួលដែលបានទទួលការបណ្តុះបណ្តាល មានតួនាទីសំខាន់ក្នុងការៈ

- ជួយរៀបចំឲ្យមានអ្នកចូលរួម សម្របសម្រួលឲ្យមានការចូលរួមពីតំណាងរបស់ក្រុមប្រជាពលរដ្ឋផ្សេងៗ (ដូចជា ស្ត្រី យុវវ័យ និងប្រជាពលរដ្ឋក្រីក្រ)

- លើកកម្ពស់ឲ្យមានការចូលរួម និងបញ្ចេញមតិយោបល់ ប្រកបដោយសមធម៌ និងសកម្ម (នៃតំណាងក្រុមប្រជាពលរដ្ឋផ្សេងៗ)នៅក្នុងពេលប្រជុំ
- គ្រប់គ្រង សម្របសម្រួលការខ្វែងមតិយោបល់គ្នា ឬភាពប្រទាំងប្រទើសផ្សេងៗដែលអាចកើតមាន
- ផ្តល់យោបល់ដល់ក្រុមនានាដែលចូលរួមឲ្យទទួលបាននូវលទ្ធផលល្អប្រសើរ
- ធានាឲ្យមានការការតាមដានប្រកបដោយប្រសិទ្ធភាព។

សមាសភាគទី៣ មានគោលដៅពង្រឹងគណនេយ្យភាពសង្គមដោយណែនាំ និងអប់រំឲ្យមានវប្បធម៌ថ្មីមួយក្នុងការចូលរួមដោយស្ថាបនា រវាងប្រជាពលរដ្ឋ និងអាជ្ញាធរ ហើយត្រូវឲ្យមានការចូលរួមពីបុគ្គលនិងអង្គការដែលមានជំនាញ អាចសម្របសម្រួលដំណើរការដូចបានលើកឡើងក្នុងសមាសភាគទី១ និងទី២។ ក្នុងនោះរួមមាន៖ (១) ការបណ្តុះបណ្តាល និងផ្តល់យោបល់ណែនាំដល់អ្នកសម្របសម្រួលនៅសហគមន៍ (២) ការគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ និងការខិតខំប្រឹងប្រែងពង្រឹងសមត្ថភាពដែលបានកំណត់ (៣) ជួយដល់អ្នកនៅមូលដ្ឋានទាំងអស់ (សមាជិកសហគមន៍ សហគមន៍មូលដ្ឋាន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវា) ឲ្យទទួលបាននូវចំណេះដឹងជាក់ស្តែងមានសមត្ថភាពនិងជំនាញចាំបាច់នានា សម្រាប់ការអនុវត្តគណនេយ្យភាពសង្គម និងធ្វើយ៉ាងណាឲ្យមានទំនាក់ទំនងក្នុងន័យស្ថាបនា និងប្រកបដោយប្រសិទ្ធភាព។

**<u>ការរៀបរាប់ពីសមាសភាគ</u>**

**ផ្នែកតម្រូវការ៖** សមាសភាគនេះ បង្ហាញអំពីតម្រូវការធនធានមនុស្សដែលចាំបាច់ក្នុងការធ្វើឲ្យប្រសើរឡើងនូវការប្រាស្រ័យទាក់ទងរវាងស្ថាប័នរដ្ឋ សង្គមស៊ីវិល និងឯកជននៅថ្នាក់មូលដ្ឋាន។ ក្រៅពីនេះ ត្រូវផ្តោតលើការកសាងសមត្ថភាព ជំនាញរបស់ប្រជាពលរដ្ឋ (ស្ត្រីនិងបុរស) និងអង្គការសង្គមស៊ីវិល (អង្គការសហគមន៍មូលដ្ឋាន និងដៃគូអង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន) ដើម្បីចូលរួមប្រកបដោយន័យស្ថាបនាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវានានា លើដំណើរការទាំងបី នៃការងារគណនេយ្យភាពសង្គមគឺ ព័ត៌មាន ថវិកា និងការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ។

**ផ្តល់ការបណ្តុះបណ្តាល និងផ្តល់ការហ្វឹកហ្វឺនដល់ក្រុមអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍** (ដែលមកពីស្ថាប័នរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល) ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម និងការប្រជុំរួមគ្នាប្រកបដោយប្រសិទ្ធភាព។ សកម្មភាពដែលស្ថិតនៅក្នុងសមាសភាគទី៣ក៏ត្រូវកសាងសមត្ថភាពដល់អង្គការសហគមន៍មូលដ្ឋានជាដៃគូមួយចំនួន និងគាំទ្រសកម្មភាពអប់រំជាសាធារណៈដែលទាក់ទងនឹងគណនេយ្យភាព ដោយផ្តោតលើប្រជាពលរដ្ឋ និងសមាជិកអង្គការសហគមន៍មូលដ្ឋាន (ផ្តោតជាសំខាន់លើស្ត្រី និងយុវវ័យ)។

**ផ្នែកផ្គត់ផ្គង់៖ ចាំបាច់ត្រូវមានការប្រាស្រ័យទាក់ទងគ្នា រវាងប្រជាពលរដ្ឋ និងរដ្ឋបាលតាមរយៈការ ផ្តល់ការគាំទ្រឲ្យបានសមស្របចំពោះស្ថាប័ននិងអង្គភាពរបស់រដ្ឋ ដើម្បីអាចទ្រទ្រង់និងផ្តល់ការគាំទ្របច្ចេកទេសដល់ការអនុវត្តការងារគណនេយ្យភាពសង្គម។** កិច្ចការសំខាន់នៃសកម្មភាពអភិវឌ្ឍន៍នានានៅមូលដ្ឋាន គឺការអភិវឌ្ឍជំនាញដែលធ្វើឲ្យមានការសន្ទនា និងការសហការប្រកបដោយប្រសិទ្ធភាពតួអង្គទាំងពីរ។ មន្ត្រីរដ្ឋបាល ថ្នាក់ក្រោមជាតិ រំពឹងថានឹងបានអភិវឌ្ឍសមត្ថភាពប្រកបដោយប្រសិទ្ធភាព អំពីរបៀបជម្រុញលើកកម្ពស់ការងារគណនេយ្យភាពសង្គម ជាមួយប្រជាពលរដ្ឋ អង្គការសហគមន៍នៅមូលដ្ឋាននិងអង្គការមិនមែនរដ្ឋាភិបាល។

តាមរយៈការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធនានានៅមូលដ្ឋានអំពីគណនេយ្យភាពសង្គម និងជំនាញសម្របសម្រួល សមាសភាគទី៣ មានគោលបំណងមិនត្រឹមតែគាំទ្រការចូលរួមអនុវត្តនៅក្នុងពេលចាប់ផ្តើមប្រកបដោយន័យស្ថាបនាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកសាងសមត្ថភាព និងជំនាញចាំបាច់ដើម្បីឲ្យការចូលរួមនោះ មាននិរន្តរភាព។ អ្នកសម្របសម្រួលគណនេយ្យភាពសហគន៍ និងអង្គការសហគមន៍មូលដ្ឋាន នឹងទទួលបានការបណ្តុះបណ្តាល ក្នុងការផ្តួចផ្តើម និងអនុវត្តគណនេយ្យភាពសង្គម ព្រមទាំងសម្របសម្រួល និងសម្រុះសម្រួលការសន្ទនា ការសហការ និងពិភាក្សាគ្នាក្នុងចំណោមស្ថាប័ន អង្គភាពរបស់រដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល។

មានការរំពឹងទុកថា នឹងមានអ្នកសម្របសម្រួលដែលសកម្ម មកពីសហគមន៍មូលដ្ឋាន តែខ្លះទៀតអាចជាសមាជិកនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ដែលទាំងនោះគឺជាបេក្ខភាពដ៏សមស្រប ក្នុងការបំពេញតួនាទីជាអ្នកជំរុញការងារគណនេយ្យភាពសង្គម។ ការបណ្តុះបណ្តាលនិងការពង្រឹងសមត្ថភាពនៅថ្នាក់មូលដ្ឋាន នឹងត្រូវធ្វើឡើងរួមគ្នា (ទាំងស្ថាប័ននិងអង្គភាពរបស់រដ្ឋ និងអង្គការសង្គមស៊ីវិល)។ បទពិសោធន៍ បានបង្ហាញថា ការបណ្តុះបណ្តាលរួមគ្នា នឹងធ្វើឲ្យទាំងស្ថាប័ននិងអង្គភាពរបស់រដ្ឋ និងអង្គការសង្គមស៊ីវិល កាន់តែមានភាពស្និទ្ធស្នាលជឿជាក់គ្នាទៅវិញទៅមក និងមានកិច្ចសហការកាន់តែខ្លាំងឡើង។ ការធ្វើបែបនេះ គឺមានសារៈសំខាន់ដើម្បីឲ្យការចូលរួមក្នុងន័យស្ថាបនាមាននិរន្តរភាពតទៅ និងជួយដោះស្រាយជម្លោះ និងបញ្ហាពិបាកនានាដែលអាចកើតមាន។

**ដើម្បីបង្កើតឲ្យមានការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពរវាងស្ថាប័ន និងអង្គភាពរបស់រដ្ឋាភិបាលជាមួយប្រជាពលរដ្ឋ ចាំបាច់ត្រូវមានការរៀបចំក្រុមប្រជាពលរដ្ឋឲ្យបានល្អ។** ការសម្របសម្រួលដោយអង្គការ សហគមន៍មូលដ្ឋាន គឺជាយន្តការដ៏សំខាន់និងជាមធ្យោបាយដ៏ល្អសម្រាប់ការជួបជុំរបស់ប្រជាពលរដ្ឋ និងការបញ្ចេញមតិ ព្រមទាំងការធ្វើសកម្មភាពរួមគ្នា។ បើទោះជាការជួបជុំប្រជាពលរដ្ឋនៅមូលដ្ឋានក្នុងប្រទេសកម្ពុជានៅមានកម្រិតទាបក៏ដោយ ប៉ុន្តែកន្លែងណាដែលមានការបង្កើតអង្គការសហគមន៍មូលដ្ឋាន គឺអង្គការទាំងនោះ តែងទទួលបានជោគជ័យក្នុងការលើកកម្ពស់នូវសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋ។ ការធ្វើបែបនេះមាន សារៈសំខាន់ណាស់នៅ ក្នុងបរិបទនៃប្រទេសកម្ពុជា ដែលជាទូទៅបុគ្គលម្នាក់ៗមានការរួញរាក្នុងការបញ្ចេញមតិ។ ផ្អែកតាមហេតុផលទាំងនេះ កម្មវិធីនេះ នឹងកសាងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាននៅក្នុងស្រុកគោលដៅ និង គាំទ្រចំពោះអង្គការសហគមន៍ទាំងនោះ ឲ្យដើរតួនាទីស្នូលក្នុងការលើកកម្ពស់គណនេយ្យភាពសង្គមនៅក្នុងសហគមន៍របស់ពួកគេ។ ការរៀបចំសម្រាប់ការអនុវត្ត មានបញ្ជាក់នៅក្នុងផ្នែកទី៣នៃឯកសារនេះ។

សមាសភាគទី៣ នេះនឹងត្រូវរៀបចំទៅជា អនុសមាសភាគទី៣ក និងទី៣ខ ដែលនឹងអាចសម្រេចបានតាមរយៈលទ្ធផលរំពឹងទុកចំនួន៨ជាបន្តបន្ទាប់ដូចខាងក្រោម។

## អនុសមាសភាគទី៣ក ការសម្របសម្រួល

### លទ្ធផល ៣.១ អង្គការមិនមែនរដ្ឋាភិបាលជាដៃគូនៅមូលដ្ឋានដែលគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពនៅមូលដ្ឋានត្រូវបានជ្រើសរើស និងចុះកិច្ចសន្យា

អង្គការដៃគូនៅមូលដ្ឋាន នឹងដើរតួនាទីសំខាន់នៅក្នុងការសម្របសម្រួល ការបណ្តុះបណ្តាល ហ្វឹកហ្វឺន ណែនាំ និងធ្វើការជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងអង្គការសហគមន៍មូលដ្ឋានជាដៃគូ។ តួនាទីរបស់

ពួកគេគឺត្រូវផ្តល់ចំនេះដឹងជំនាញ និងការគាំទ្រដល់អ្នកពាក់ព័ន្ធនានានៅមូលដ្ឋាន ដើម្បី អនុវត្តសកម្មភាពគណនេយ្យភាពសង្គមឲ្យបានជោគជ័យ។ អង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន នឹងចាត់តាំងអ្នកសម្របសម្រួលដែលមានជំនាញ និងអ្នកបណ្តុះបណ្តាល តាមរយៈអនុសារណៈនៃការឯកភាពយល់រួមជាមួយនឹងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងសហគមន៍មូលដ្ឋាន ដើម្បីកសាងសមត្ថភាពរបស់ពួកគេឲ្យចេះណែនាំ និងសម្របសម្រួលសកម្មភាពគណនេយ្យភាពសង្គមនៅមូលដ្ឋាន។ អង្គការមិនមែនរដ្ឋាភិបាលដៃគូនៅមូលដ្ឋាន ត្រូវអនុវត្តតាមសៀវភៅណែនាំឲ្យបានត្រឹមត្រូវ។ អង្គការមិនមែនរដ្ឋាភិបាល នឹងពង្រឹងសមត្ថភាពតាមមធ្យោបាយផ្សេងៗ អាស្រ័យទៅតាមសមត្ថភាពនិងបរិបទ។ ទំហំការងារក្នុងស្រុកនីមួយៗ តម្រូវឲ្យមានគ្រូបង្គោលឬអ្នកផ្តល់យោបល់ចំនួនបីនាក់ ដែលត្រូវធ្វើការពេញម៉ោងរួមជាមួយនឹងមន្ត្រីរដ្ឋបាលគ្រប់គ្រង។ គេរំពឹងថាអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ (ទាំងជាតិនិងអន្តរជាតិ) នឹងជ្រើសរើសអង្គការ ដៃគូក្នុងមូលដ្ឋាន តាមរយៈការទំនាក់ទំនងជាមួយដៃគូដែលមានស្រាប់ ឬតាមរយៈការវាយតម្លៃស្នាដៃអនុវត្តក្នុងស្រុកគោលដៅ។ អង្គការមិនមែនរដ្ឋាភិបាលជាដៃគូអនុវត្ត ត្រូវទទួលខុសត្រូវក្នុងការផ្តល់យោបល់គាំទ្រការអភិវឌ្ឍសមត្ថភាព និងធានាឲ្យមានគុណភាពសកម្មភាពដែលអនុវត្តដោយអង្គការដៃគូនៅមូលដ្ឋាន។

## លទ្ធផល ៣.២ ដៃគូអង្គការសហគមន៍មូលដ្ឋានជាយុទ្ធសាស្ត្រ (ដោយផ្តោតលើ អ្នកតំណាងជាស្ត្រី និងយុវវ័យ) ត្រូវបានជ្រើសរើស

ដើម្បីរៀបចំសហគមន៍ឲ្យមានប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋាន សម្រាប់ការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម ត្រូវកំណត់អង្គការសហគមន៍មូលដ្ឋានណាដែលមានចំណាប់អារម្មណ៍ជាមួយនឹងគណនេយ្យភាពសង្គម។ អង្គការសហគមន៍មូលដ្ឋាននោះត្រូវបំពេញតួនាទី ជាអ្នកអនុវត្តគម្រោង និងជាអ្នកទទួលផល។ ដៃគូអង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋាន ត្រូវជ្រើសរើសនិងចុះកិច្ចព្រមព្រៀងជាដៃគូ ជាមួយអង្គការសហគមន៍មូលដ្ឋានចំនួន ពី១០ទៅ២០អង្គការសហគមន៍នៅក្នុងស្រុកគោលដៅនីមួយៗ។ ដោយសារតែអង្គការសហគមន៍ មូលដ្ឋាននោះ ត្រូវដើរតួនាទីសំខាន់ជាភ្នាក់ងារដែលត្រូវធ្វើឱ្យមានការផ្លាស់ប្តូរ ហេតុនេះ ត្រូវផ្តល់អាទិភាពក្នុងការជ្រើសរើស អង្គការសហគមន៍មូលដ្ឋានណាដែលមានតំណាងស្ត្រី យុវវ័យ និងប្រជាពលរដ្ឋក្រីក្រ ភាគច្រើន។ ក្នុងអំឡុងពេលនៃការអនុវត្ត អង្គការសហគមន៍មូលដ្ឋានដៃគូ ត្រូវចូលរួមក្នុងការអភិវឌ្ឍន៍សមត្ថភាព និងសកម្មភាពរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ ។

## លទ្ធផល ៣.៣ អ្នកសម្របសម្រួលគណនេយ្យភាពនៅសហគមន៍ (ដោយផ្តោតលើស្ត្រី និងយុវវ័យ) ត្រូវបានជ្រើសរើស និងចងក្រងជាក្រុម

ចំណុចសំខាន់របស់កម្មវិធី គឺការបង្កើតឲ្យមានក្រុមអ្នកសម្របសម្រួលគណនេយ្យភាពនៅ សហគមន៍ដែលទទួលការបណ្តុះបណ្តាលនៅក្នុងស្រុកគោលដៅនីមួយៗ (មានចំនួនបួននាក់ក្នុងមួយឃុំ)។ ត្រូវមានអ្នកសម្របសម្រួលជាស្ត្រីចំនួន៥០% យ៉ាងតិច និងអ្នកសម្របសម្រួលដែលមានអាយុក្រោម៣៥ឆ្នាំ ត្រូវមានចំនួន ២៥% យ៉ាងតិច។ សៀវភៅណែនាំ នឹងមានរៀបរាប់ពីមធ្យោបាយក្នុងការសម្រេចបានគោលដៅខាងលើនេះ។ បន្ទាប់ពីបានជ្រើសរើស អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នឹងជួយឲ្យអង្គការសហគមន៍មូលដ្ឋានជាដៃគូនៅចូលរួមជាប្រចាំនៅក្នុងសកម្មភាពនៃកម្មវិធី ហើយជួយជំរុញដល់ការអភិវឌ្ឍសមត្ថភាពនិងជួយពង្រឹង

ដល់អង្គការសហគមន៍មូលដ្ឋាន។ ពួកគេនឹងផ្ទេរចំណេះដឹងនិងជំនាញទៅកាន់សមាជិកអង្គការសហគមន៍មូលដ្ឋានផ្សេងទៀត។

ដោយមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលជាដៃគូនៅមូលដ្ឋាន អ្នកសម្របសម្រួលគណនេយ្យភាពនៅសហគមន៍នឹងបង្កើតនិងអនុវត្តសកម្មភាពមួយចំនួនសម្រាប់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងសមាជិកសហគមន៍ មូលដ្ឋាន ដោយផ្តល់ជាដំណឹងដល់ពួកគេ ជួយសម្របសម្រួល និងពង្រឹងសមត្ថភាពពួកគេ ដើម្បីអនុវត្តការងារគណនេយ្យភាពសង្គម និងឲ្យពួកគេចូលរួមប្រកបដោយន័យស្ថាបនាជាមួយរដ្ឋបាលមូលដ្ឋាន និងអ្នកផ្តល់សេវា។ សកម្មភាពនៃការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ ត្រូវផ្តោតជាពិសេសចំពោះការចូលរួមរបស់ស្ត្រី យុវវ័យ និងប្រជាពលរដ្ឋក្រីក្រ ដែលចាត់ទុកថាជាក្រុមគោលដៅនាំឱ្យមានការផ្លាស់ប្តូរនានា។ ក្រុមនេះ នឹងផ្តោតទៅលើបញ្ហាដែលទាក់ទងនឹងព័ត៌មាន (សិទ្ធិ ថវិកា និងស្តង់ដារ) ភាពជាប្រជាពលរដ្ឋដ៏សកម្ម ការចូលរួមក្នុងន័យស្ថាបនារបស់ប្រជាពលរដ្ឋ ជាមួយរដ្ឋបាលមូលដ្ឋាននៅក្នុងការងារគណនេយ្យភាពសង្គម ដូចដែលបានរៀបរាប់នៅក្នុងសមាសភាគទី១និង២ខាងលើ។ ការអភិវឌ្ឍសមត្ថភាពអ្នកសម្របសម្រួល គណនេយ្យភាពសង្គម ដែលត្រូវធ្វើឡើងក្នុងរយៈពេល១០ខែ តាមរយៈការបណ្តុះបណ្តាលនិងការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ ដែលធ្វើឲ្យអ្នកសម្របសម្រួលគណនេយ្យសង្គមនានា អាចទទួលបានចំណេះដឹងដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ស៊ីជម្រៅ និងអាចអនុវត្តបាន។ កម្មវិធីនេះ មានគោលបំណងផ្តល់ការ បណ្តុះបណ្តាលអ្នកសម្របសម្រួល ចំនួនពី៣៥នាក់ទៅ៤០នាក់នៅក្នុងស្រុកគោលដៅនីមួយៗ។ ប្រការនេះ នឹងបង្កើតឲ្យមានបណ្តាញជាច្រើន ទាំងអ្នកជំរុញលើកទឹកចិត្ត ទាំងអ្នកអនុវត្តដែលមានសមត្ថភាព នៅថ្នាក់មូលដ្ឋាន ទាំងខាងសង្គមស៊ីវិល ទាំងក្រុមប្រឹក្សាឃុំ ហើយពួកគេត្រូវបានផ្តល់សិទ្ធិអំណាចដើម្បីផ្តួចផ្តើម និងធ្វើឲ្យមាននិរន្តរភាពក្នុងការអនុវត្តគណនេយ្យភាពសង្គមនៅក្នុងសហគមន៍របស់ខ្លួន។ បេក្ខជនដែលបានបញ្ចប់ វគ្គបណ្តុះបណ្តាលដោយជោគជ័យ នឹងទទួលបានលិខិតបញ្ជាក់អ្នកសម្របសម្រួលគណនេយ្យភាពសង្គម។

### លទ្ធផល ៣.៤ សហគមន៍អនុវត្ត ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការគាំទ្រជាប្រចាំ ដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍

ផ.អ.គ.ស នឹងប្រើប្រាស់ទិន្នន័យ ប្រព័ន្ធព័ត៌មានសង្គម និងទម្រង់ផ្សេងៗទៀតនៃការប្រាស្រ័យទាក់ទង ដើម្បីគាំទ្រដល់អ្នកសម្របសម្រួល និងសហគមន៍មូលដ្ឋានជាដៃគូផ្សេងៗ។ ការប្រើប្រាស់នេះរួមបញ្ចូលនូវការបង្កើតឲ្យមានទិន្នន័យថ្នាក់ជាតិមួយ ដែលមានព័ត៌មានទាក់ទងនឹងអ្នកសម្របសម្រួលគណនេយ្យភាពសង្គម (ដើម្បីលើកកម្ពស់បណ្តាញទំនាក់ទំនងនិងទីផ្សារជំនាញនានា) ការបង្កើតក្រុមបណ្តាញទំនាក់ទំនងសង្គម សម្រាប់អ្នកសម្របសម្រួលគណនេយ្យភាពសង្គម ដើម្បីលើកកម្ពស់ការពិភាក្សា ការចែករំលែកព័ត៌មាន និងធ្វើការផ្សព្វផ្សាយព័ត៌មានថ្មីៗ ចែកលិខិតអញ្ជើញឲ្យចូលរួមក្នុងព្រឹត្តិការណ៍រៀនសូត្រតាមរយៈទំព័របណ្តាញទំនាក់ទំនងសង្គម។ អង្គការសង្គមស៊ីវិលនឹងពឹងផ្អែកលើអ្នកពាក់ព័ន្ធនានាដែលបានតែងតាំង និងធនធានដែលមានដើម្បីឱ្យទទួលខុសត្រូវចំពោះការងារនេះ។

## អនុសមាសភាគ៣ខ ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន និងពង្រឹងសមត្ថភាព

មានការរំពឹងទុកថា ដៃគូជំនាញបណ្តុះបណ្តាល នឹងដើរតួនាទីជាអ្នកគាំទ្រដល់ដៃគូអនុវត្ត ទាំងស្ថាប័ន និងអង្គភាពរបស់រដ្ឋ ទាំងសង្គមស៊ីវិលនិងឯកជន។ ដៃគូផ្តល់ការបណ្តុះបណ្តាលទាំងនោះ នឹងរៀបចំកម្មវិធីសម្រាប់កសាងសមត្ថភាព និងវិធីសាស្រ្តរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ ព្រមទាំងបណ្តុះបណ្តាលគ្រូបង្គោលរបស់ដៃគូអនុវត្តទាំងអស់ ក៏ដូចជាគ្រូបង្គោលជាមន្ត្រីរដ្ឋាភិបាល។ ប្រការនេះ តម្រូវឱ្យមានដៃគូតែមួយសម្រាប់ផ្តល់ការបណ្តុះបណ្តាល ទាំងចំពោះអង្គភាពរបស់រដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល គឺមានអត្ថប្រយោជន៍ច្រើន ដោយសារតែ មានប្រធានបទច្រើនដែលត្រួតគ្នា (ឧទាហរណ៍ដូចជា ការផ្តល់ការណែនាំទូទៅ ខ្លឹមសារកញ្ចប់ព័ត៌មាន4Cs គោលការណ៍នៃការបើកទូលាយព័ត៌មាននិងកិច្ចប្រជុំរួមគ្នាជាដើម)។ ក្នុងនោះ ដៃគូផ្តល់ការបណ្តុះបណ្តាលត្រូវ៖

- រៀបចំឲ្យមានកម្មវិធីបណ្តុះបណ្តាល សម្ភារៈបណ្តុះបណ្តាល និងវិធីសាស្រ្តនានា
- បណ្តុះបណ្តាលគ្រូបង្គោលទាំងអង្គភាពរបស់រដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល
- ផ្តល់ការគាំទ្រ ការណែនាំជាបន្តបន្ទាប់ ព្រមទាំងជំនួយបច្ចេកទេសដែលត្រូវការ។

### លទ្ធផល ៣.៥ ដៃគូជំនាញបណ្តុះបណ្តាលស្តីពីគណនេយ្យភាពសង្គមត្រូវបានជ្រើសរើស

សកម្មភាពសំខាន់ៗសម្រាប់លទ្ធផលនេះរួមមាន៖ (១) រៀបចំលក្ខខ័ណ្ឌការងារសម្រាប់ដៃគូដែលត្រូវផ្តល់ការបណ្តុះបណ្តាល (២) ជ្រើសរើសដៃគូដែលផ្តល់ការបណ្តុះបណ្តាលតាមរយៈការប្រកួតប្រជែងនិង(៣)ផ្តល់ការណែនាំតម្រង់ទិស និងគាំទ្រដល់ដៃគូផ្តល់ការបណ្តុះបណ្តាលដើម្បីឲ្យបានយល់ពីកម្មវិធី។ សម្រាប់ផ្នែកតម្រូវការ ដៃគូជំនាញក្នុងការបណ្តុះបណ្តាល នឹងផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្គោល គឺត្រូវផ្តល់ចំពោះបេក្ខជនដែល បានជ្រើសរើសពីអង្គការជាដៃគូនៅមូលដ្ឋាន ហើយដែលនឹងត្រូវបណ្តុះបណ្តាល និងណែនាំ បន្តដល់អ្នកសម្របសម្រួលគណនេយ្យភាពនៅសហគមន៍។ បុគ្គលិកដែលចាត់តាំងមកពីអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ នឹងត្រូវចូលរួមចំណែកផងដែរនៅក្នុងការបណ្តុះបណ្តាលដល់គ្រូបង្គោល។ ដៃគូជំនាញនោះនឹងផ្តល់ការបណ្តុះបណ្តាលរំលឹកឡើងវិញ និងការគាំទ្រជាប្រចាំព្រមទាំងធ្វើការងារ ជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលជាអ្នកអនុវត្តដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងនូវកម្មវិធីបណ្តុះបណ្តាល និងយុទ្ធសាស្រ្តក្នុងការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ក្នុងកំឡុងពេល៣ឆ្នាំដំបូងនៃកម្មវិធី។ សម្រាប់ផ្នែកផ្គត់ផ្គង់ ដៃគូជំនាញបណ្តុះបណ្តាល នឹងសម្របសម្រួលជាមួយ គ.ជ.អ.ប ដើម្បីផ្តល់ការបណ្តុះបណ្តាលចំពោះមន្ត្រីនៅថ្នាក់ស្រុក (រួមទាំងមន្ត្រី សុខាភិបាល និងអប់រំ) និងបន្តការគាំទ្រកសាងសមត្ថភាពឱ្យបានគ្រប់គ្រាន់ផងដែរ។

### លទ្ធផល ៣.៦ កម្មវិធីបណ្តុះបណ្តាល សម្ភារៈ និងវិធីសាស្រ្ត ត្រូវបានបង្កើតឡើង សម្រាប់ទាំងផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់

ដៃគូជំនាញបណ្តុះបណ្តាល នឹងរៀបចំនូវសម្ភារៈបណ្តុះបណ្តាលទាំងអស់ ដើម្បីអនុវត្តសកម្មភាពកសាងសមត្ថភាព និងធ្វើការបណ្តុះបណ្តាល។ រយៈពេល និងប្រធានបទសម្រាប់ការបណ្តុះបណ្តាលក្នុងដំណាក់កាល ដំបូង (ដែលមានគោលបំណងផ្តោតលើថវិកាជាសំខាន់) កំពុងតែរៀបចំបង្កើតឡើងដោយក្រុមរៀបចំផ.អ.គ.ស។ កម្មវិធីបណ្តុះបណ្តាលនេះ នឹងត្រូវ៖

- ផ្អែកលើ គោលការណ៍នៃការសិក្សាសម្រាប់មនុស្សពេញវ័យ និងការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ និងសកម្ម (ដោយបញ្ចូលវដ្តនៃព័ត៌មាន ការឆ្លុះបញ្ចាំង និងសកម្មភាពនានា)

- ធ្វើការសាកល្បងមុននឹងដាក់ឲ្យអនុវត្ត
- បង្កើតឡើងតាមរយៈដំណើរការនៃការចូលរួម មានលំហាត់អនុវត្ត មានមធ្យោបាយផ្សេងៗទៀត ដើម្បីវាយតម្លៃលើការរៀនសូត្រ
- កំណត់ពីតម្រូវការផ្សេងៗរបស់ស្ត្រី យុវវ័យ និងក្រុមប្រជាពលរដ្ឋផ្សេងៗទៀត។

ដៃគូជំនាញនឹងធ្វើការយ៉ាងជិតស្និទ្ធិជាមួយ គ.ជ.អ.ប ដើម្បីជួយរៀបចំកម្មវិធី និងសម្ភារៈសិក្សាសម្រាប់ការបណ្តុះបណ្តាលឲ្យបានសមស្រប សម្រាប់ស្ថាប័ន អង្គភាពរបស់រដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន (ថ្នាក់ស្រុក និងឃុំ)។ នៅក្នុងកម្មវិធីដែលផ្តោតលើការរៀនសូត្រ (ដូចមានក្នុងសមាសភាគទី៤) សម្ភារៈបណ្តុះបណ្តាល នឹងត្រូវយកមកពិនិត្យមើលនិងកែសម្រួលឡើងវិញជារៀងរាល់ឆ្នាំ ទៅតាមការចាំបាច់។

### លទ្ធផល ៣.៧ ការពង្រឹងសមត្ថភាពដល់ដៃគូអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ និងមូលដ្ឋាន ឱ្យក្លាយជាគ្រូបង្គោល

លទ្ធផលនេះ មានគោលបំណងកសាងសមត្ថភាពអង្គការមិនមែនរដ្ឋាភិបាលជាដៃគូអនុវត្តនៅថ្នាក់ជាតិ និងមូលដ្ឋាន តាមរយៈការប្រើប្រាស់វិធីសាស្រ្តបណ្តុះបណ្តាលគ្រូបង្គោល ។ យន្តការមួយចំនួនទៀត ក៏ត្រូវបានប្រើប្រាស់ដែរ ដើម្បីឲ្យអង្គការមិនមែនរដ្ឋាភិបាលជាដៃគូអនុវត្តនៅថ្នាក់មូលដ្ឋានមានសមត្ថភាព មានការគាំទ្រ និងមានជំនួយបច្ចេកទេសដែលពួកគេត្រូវការ ដើម្បីបំពេញតួនាទីប្រកបដោយជោគជ័យនិងមានប្រសិទ្ធ ភាព។ នៅក្នុងដំណាក់កាលនៃការចាប់ផ្តើមនៃកម្មវិធី បុគ្គលិកពាក់ព័ន្ធនានាដែលមកពីអង្គការមិនមែនរដ្ឋាភិបាលជាដៃគូនៅមូលដ្ឋានទាំងអស់ នឹងចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោល ដើម្បីឲ្យពួកគេទទួលបានចំណេះដឹង និងជំនាញដែលត្រូវការដើម្បីយកទៅបណ្តុះបណ្តាលបន្តដល់អ្នកសម្របសម្រួលគណនេយ្យភាពនៅថ្នាក់មូលដ្ឋាន។ ការបណ្តុះបណ្តាលគ្រូបង្គោល នឹងធ្វើឡើងនៅថ្នាក់ជាតិ និងមានរយៈពេលសរុបចំនួន២០ថ្ងៃ។ សកម្មភាពអភិវឌ្ឍ សមត្ថភាព និងការអនុវត្តនានានឹងត្រូវផ្តល់ក្នុងអំឡុងពេលនៃកម្មវិធី ដោយអនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋានបន្តពង្រឹងចំណេះដឹង ជំនាញ និងសមត្ថភាពបន្ថែមទៀត។

អង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន នឹងទទួលបាននូវគោលការណ៍ណែនាំទាក់ទងទៅនឹងការបណ្តុះបណ្តាលដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ (ដែលបានរៀបចំដោយដៃគូជំនាញបណ្តុះបណ្តាល) ព្រមទាំងទទួលបានព័ត៌មានដែលមានសារៈសំខាន់ និងការណែនាំអំពីវិធីសាស្រ្តដែលត្រូវការ ដើម្បីឲ្យពួកគេអាចផ្តល់នូវវិធីសាស្រ្តផ្សេងៗក្នុងការបណ្តុះបណ្តាល និងការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ដល់អ្នកសម្របសម្រួលគណនេយ្យភាពនៅសហគមន៍។ ទោះបីយ៉ាងណាក៏ដោយ បុគ្គលិកដែលផ្តល់ការបណ្តុះបណ្តាលមកពីអង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិនិងមូលដ្ឋាន ត្រូវបានលើកទឹកចិត្តឲ្យធ្វើការសម្របសម្រួល និងកែសម្រួលសម្ភារៈបណ្តុះបណ្តាលឲ្យបានសមស្រប ព្រមទាំងបន្តរួមចំណែកធ្វើឲ្យប្រសើរឡើងនូវសៀវភៅ បណ្តុះបណ្តាលស្តីពីក្របខ័ណ្ឌគណនេយ្យភាពសង្គម។

ក្រៅពីការបណ្តុះបណ្តាលគ្រូបង្គោល និងការផ្តល់ធនធានសម្រាប់ការបណ្តុះបណ្តាលដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ អង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន ក៏ត្រូវទទួលបានការផ្តល់យោបល់ជាប្រចាំ ការគាំទ្រផ្នែកប្រតិបត្តិការ និងជំនួយផ្នែកបច្ចេកទេសទៅតាមតម្រូវការ។ ជំនួយគាំទ្របច្ចេកទេស នឹងត្រូវផ្តល់ជាប្រចាំស្របតាមតម្រូវការ របស់អង្គការមិនមែនរដ្ឋាភិបាលដែលជាដៃគូនៅថ្នាក់ជាតិ (ដោយមានការជួយគាំទ្រពីដៃគូជំនាញក្នុងការបណ្តុះបណ្តាលតាមតម្រូវការ)។ ដូចបានរៀបរាប់ខាងក្រោម (នៅក្នុងសមាសភាគទី៤) កម្មវិធីនឹង

ទទួលបានអត្ថប្រយោជន៍ពីសេវារបស់ដៃគូជំនាញក្នុងការបណ្តុះបណ្តាល។ ការគាំទ្រក្នុងការសិក្សា និងសេវាសម្រាប់ភាពជាដៃគូរបស់អង្គការមិនមែនរដ្ឋាភិបាល រួមទាំងការរៀបចំឲ្យមានសេចក្តីសង្ខេបទាក់ទងនឹងដំណើរប្រតិបត្តិការ និងមេរៀនបទពិសោធន៍ដែលទទួលបាន ក៏ដូចជាសកម្មភាពក្នុងការរៀនសូត្រ និងការចែករំលែកនានានៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ នឹងរៀបរាប់ក្នុងផ្នែកខាងក្រោម។

**លទ្ធផល ៣.៨ ការបណ្តុះបណ្តាលមន្ត្រីថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក ឱ្យក្លាយជាគ្រូបង្គោល**

ដៃគូជំនាញបណ្តុះបណ្តាល នឹងទទួលខុសត្រូវក្នុងការរៀបចំកម្មវិធីកសាងសមត្ថភាពដល់អង្គភាពនានារបស់រដ្ឋាភិបាល និងធ្វើការបណ្តុះបណ្តាល គ្រូបង្គោល ដល់មន្ត្រីដែលពាក់ព័ន្ធរហូតដល់ថ្នាក់ស្រុក (រួមទាំងមន្ត្រីនិងបុគ្គលិកសុខាភិបាល និងអប់រំ មកពីថ្នាក់ខេត្ត ស្រុក)។ ដើម្បីអនុវត្តការងារនេះ ដៃគូជំនាញ បណ្តុះបណ្តាលនឹងធ្វើការសហការជិតស្និទ្ធិជាមួយគ.ជ.អ.ប ក្នុងការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្គោលមួយចំនួនរបស់គ.ជ.អ.ប។ ការបណ្តុះបណ្តាលគ្រូបង្គោល នឹងធ្វើនៅថ្នាក់ជាតិ និងមានរយៈពេលសរុបចំនួន១០ថ្ងៃ។ ការបណ្តុះបណ្តាលនេះនឹងបំពេញបន្ថែមលើកម្មវិធីបណ្តុះបណ្តាលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលផ្តល់ ដោយគ.ជ.អ.ប។

**សមិទ្ធផលនៃសមាសភាគទី៣ស្តីពីការសម្របសម្រួលនិងការពង្រឹងសមត្ថភាព** គឺការបង្កើតឲ្យមានការប្រាស្រ័យទាក់ទង និងការចូលរួមប្រកបដោយប្រសិទ្ធភាពរវាងប្រជាពលរដ្ឋនិងសមាជិកក្រុមប្រឹក្សាឃុំ។ នៅក្នុងសមាសភាគនេះ នឹងបង្កើតឲ្យមានក្រុមអ្នកសម្របសម្រួលជំនាញ និងតំណាងអង្គការសហគមន៍មូលដ្ឋាននៅតាមសហគមន៍ ព្រមទាំងបានអភិវឌ្ឍសមត្ថភាពរបស់អង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋានឲ្យចេះធ្វើការហ្វឹកហ្វឺនណែនាំ និងបង្រៀនពួកគេ ក៏ដូចជាអភិវឌ្ឍជំនាញដល់អង្គភាពរបស់រដ្ឋាភិបាលនៅថ្នាក់មូលដ្ឋានក្នុងការសម្របសម្រួលឲ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាព។ ដើម្បីសម្រេចបានកិច្ចការនេះបាន ត្រូវរៀបចំចងក្រងសម្ភារៈបណ្តុះបណ្តាល ការបណ្តុះបណ្តាលគ្រូបង្គោល ព្រមទាំងមានកម្មវិធីបណ្តុះបណ្តាលផ្ទាល់ និងការរៀនសូត្រតាម រយៈការអនុវត្តដោយផ្ទាល់ជាប្រចាំ។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ នឹងទទួលបានការគាំទ្រដោយការអនុវត្តសកម្មភាពនានា។ លទ្ធផលនេះ នឹងផ្តោតលើសេចក្តីត្រូវការក្នុងការចូលរួមជាលក្ខណៈប្រព័ន្ធរបស់ស្ត្រី និងយុវវ័យ ដោយត្រូវយកចិត្តទុកដាក់ចំពោះស្ត្រី និងយុវវ័យ ក្នុងការចូលរួមដោយពេញលេញ។

**តារាងសង្ខេបសមាសភាគទី៣ ការសម្របសម្រួល និងការពង្រឹងសមត្ថភាព**

| ផ្នែក | ការរៀបរាប់ |
|---|---|
| គោលបំណង | បង្កើតឲ្យមានក្រុម មានជំនាញក្នុងការសម្របសម្រួលឲ្យមានការចូល រួមពីតួអង្គរដ្ឋ និងមិនមែនរដ្ឋនៅក្នុងដំណើរការគណនេយ្យភាពសង្គមប្រកបដោយលក្ខណៈស្ថាបនា និងទទួលបានលទ្ធផលប្រសើរ។<br>ធ្វើការអភិវឌ្ឍសមត្ថភាពរបស់តួអង្គរដ្ឋ និងមិនមែនរដ្ឋដែលគាំទ្រសកម្មភាពនៅ ថ្នាក់មូលដ្ឋាន ដើម្បីចូលរួមនៅក្នុងដំណើរការក្របខណ្ឌគណនេយ្យភាពសង្គម។ |
| អនុសមាសភាគ | ៣ក. ការសម្របសម្រួល<br>លទ្ធផល ៣.១ អង្គការមិនមែនរដ្ឋាភិបាលជាដៃគូនៅមូលដ្ឋាន ដែលគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពនៅមូលដ្ឋាន ត្រូវបានជ្រើសរើស និងចុះកិច្ចសន្យា<br>លទ្ធផល ៣.២ ដៃគូអង្គការសហគមន៍មូលដ្ឋានជាយុទ្ធសាស្ត្រ ដោយផ្តោតលើ អ្នកតំណាង) |

ត្រូវបានជ្រើសរើស (ជាស្រ្តី និងយុវវ័យ

**លទ្ធផល ៣.៣** ដោយផ្តោតលើស្រ្តី និង) សម្របសម្រួលគណនេយ្យភាពនៅសហគមន៍អ្នកត្រូវបានជ្រើសរើស និងចងក្រងជាក្រុម (យុវវ័យ

**លទ្ធផល ៣.៤** សហគមន៍អនុវត្ត ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការគាំទ្រជាប្រចាំ ដល់អ្នកសម្របសម្រួល គណនេយ្យភាពសហគមន៍

**៣ខ. ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន និងកសាងសមត្ថភាព**[27]

**លទ្ធផល ៣.៥** ដៃគូជំនាញបណ្តុះបណ្តាលស្តីពីគណនេយ្យភាពសង្គមត្រូវបានជ្រើសរើស

**លទ្ធផល ៣.៦** កម្មវិធីបណ្តុះបណ្តាល សម្ភារៈ និងវិធីសាស្រ្ត ត្រូវបានបង្កើតឡើង សម្រាប់ទាំងផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់

**លទ្ធផល ៣.៧** ការពង្រឹងសមត្ថភាពដល់ដៃគូអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ និងមូលដ្ឋាន ឱ្យក្លាយជាគ្រូបង្គោល

**លទ្ធផល ៣.៨** ការបណ្តុះបណ្តាលមន្រ្តីថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក ឱ្យក្លាយជាគ្រូបង្គោល

[27] សមាសភាគទី៣ខ រួមបញ្ចូលការបណ្តុះបណ្តាលតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ស្រុក (សម្រាប់ទាំងភាគីរដ្ឋនិងអង្គការនានា)។ សមាសភាពទី១ និងទី២ រួមមានលទ្ធផលសំខាន់ៗមួយចំនួនសម្រាប់ការលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាពអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អង្គការសហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋ និងការបណ្តុះបណ្តាលដល់ភ្នាក់ងារឃុំ និងអ្នកផ្តល់សេវានានា។

# សមាសភាគទី ៤

# ការប្រមូលមេរៀនបទពិសោធន៍ និងការត្រួតពិនិត្យតាមដាន

សមាសភាគទី៤ ផ្តល់អាទិភាពលើការប្រមូលមេរៀនបទពិសោធន៍ ក្នុងការអនុវត្តកិច្ចការសំខាន់ទាំងបី នៃសកម្មភាពគណនេយ្យភាពសង្គម (ព័ត៌មាន ថវិកា និងការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ)។ ដើម្បីលើកកម្ពស់ការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម ផ.អ.គ.ស នឹងបញ្ចូលកិច្ចការសំខាន់មួយ គឺការប្រមូលមេរៀនបទពិសោធន៍ និងព្យាយាមបង្កើតឲ្យមានទម្លាប់នៃការសិក្សារៀនសូត្រអំពីបទពិសោធន៍របស់អ្នកពាក់ព័ន្ធនានា។ គោលបំណងនៃសមាសភាគនេះ គឺដើម្បីឲ្យមេរៀនបទពិសោធន៍ជាក់ស្តែងដែលទទួលបាន បានបញ្ចូលទៅក្នុងការអនុវត្តកម្មវិធី។ ការសម្រេចបាននូវគោលបំណងនេះ មិនមែនជាការងាយស្រួលឡើយ។ មេរៀនបទពិសោធន៍ថ្មីៗ បានបង្ហាញអំពីឧបសគ្គជាច្រើន នៅក្នុងការរៀនសូត្រអំពីដំណើរការអភិវឌ្ឍនានា មិនមែនតែការងារគណនេយ្យភាពសង្គមប៉ុណ្ណោះទេ។ ដើម្បីដោះស្រាយឧបសគ្គទាំងនេះ ការបង្កើតទម្លាប់ក្នុងការសិក្សារៀនសូត្រ គឺជាគោលបំណងជាចម្បងនៃសមាសភាគនេះ។

ក្រៅអំពីបញ្ហាប្រឈម ការងារចម្បងរបស់ ផ.អ.គ.ស គឺត្រូវធ្វើយ៉ាងណាឲ្យមានការយល់ដឹងនៅមូលដ្ឋានអំពីកិច្ចការណាខ្លះដែលអនុវត្តបាន ឬអនុវត្តមិនបាន ត្រូវមានការចែករំលែកនូវមេរៀន បទពិសោធន៍ដែលទទួលបានឲ្យបានទូលំទូលាយ និងផ្តល់មតិយោបល់ លើការកែសម្រួលគោលនយោបាយ ។ ការផ្តោតជាចម្បងក្នុងការសិក្សារៀនសូត្រនេះ គឺសម្រាប់អ្នកពាក់ព័ន្ធនានានៅមូលដ្ឋាន រួមមាន អង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងមន្ត្រីសាធារណៈនៅមូលដ្ឋាន ដែលត្រូវធ្វើការរួមគ្នាក្នុងការអនុវត្តដំណើរការនៃការផ្តល់ព័ត៌មាន ថវិកា និងការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ។ អ្នកពាក់ព័ន្ធទាំងនេះ នឹងត្រូវធ្វើការពន្យល់ពីគោលការណ៍ណែនាំ ការសាកល្បងនានា ព្រមទាំងការផ្តួចផ្តើមនានាពាក់ព័ន្ធទៅនឹងគោលគំនិត ខ្លឹមសារដំណើរការ និងការរៀបចំស្ថាប័នជាដើម។ សមាសភាគនេះ នឹង៖

១) ផ្តួចផ្តើមសកម្មភាពនានាទៅតាមស្ថានភាពនៅមូលដ្ឋាន និងនៅក្នុងសហគមន៍ជាក់លាក់ណាមួយដែលអាចចែករំលែក និងយកទៅអនុវត្តបាននៅកន្លែងដទៃទៀត

២) អនុញ្ញាតឲ្យអ្នកពាក់ព័ន្ធនានាអាចបញ្ចេញមតិដោយសេរី លើកិច្ចការអ្វីខ្លះដែលពួកគេយល់ថាអាចអនុវត្តបាន ឬមិនបាន

៣) ធានាថាគោលនយោបាយ និងគោលការណ៍ណែនាំនានារបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងតម្លាភាព និងគណនេយ្យភាព មានការឆ្លើយតបចំពោះបញ្ហា និងអាចអនុវត្តបានដោយជោគជ័យ។

ដើម្បីឲ្យកិច្ចការនេះត្រូវបានលើកកម្ពស់ និងអនុវត្តទាំងស្រុង ផ.អ.គ.ស ត្រូវមានការចូលរួមពីដៃគូជំនាញពាក់ព័ន្ធការរៀនសូត្របទពិសោធន៍នានា។ ដៃគូជំនាញឯករាជ្យផ្នែកមេរៀនបទពិសោធន៍ នឹងបង្កើតឲ្យមានវេទិកាសម្រាប់សិក្សារៀនសូត្រ និងត្រួតពិនិត្យពីថ្នាក់មូលដ្ឋានដល់នៅថ្នាក់ជាតិ ដូចបានរៀបរាប់នៅក្នុងលទ្ធផលខាងក្រោម។ ដៃគូជំនាញនេះ នឹងបង្កើតជាវេទិការួមមួយ ដើម្បីទទួលបានមតិឆ្លុះបញ្ចាំងនិងយោបល់ត្រឡប់ចំពោះគោលនយោបាយ និងការអនុវត្តជាក់ស្តែងទាំងស្ថាប័ន អង្គភាពរបស់រដ្ឋាភិបាល និងសង្គមស៊ីវិល។

សមាសភាគទី៤ នេះ នឹងត្រូវរៀបចំទៅជា អនុសមាសភាគទី៤ក និងទី៤ខ ដែលអាចរំពឹងថានឹងសម្រេចបានតាមរយៈលទ្ធផលរំពឹងទុកចំនួន០៨ជាបន្តបន្ទាប់ដូចខាងក្រោម។

## សមាសភាគ ៤ក ការប្រមូលមេរៀនបទពិសោធន៍ និងការផ្តល់យោបល់ត្រឡប់

### លទ្ធផល ៤.១ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ក្នុងការប្រមូលមេរៀនបទពិសោធន៍ ដែលមានលក្ខណៈច្នៃប្រឌិតត្រូវបានបង្កើតឡើង

ទម្លាប់នៃការសិក្សារៀនសូត្រ នឹងត្រូវបំពាក់បំប៉នបន្ថែមតាមរយៈយន្តការដែលមានការច្នៃប្រឌិត និងមានរបៀបរបបជាក់លាក់។ ឧបករណ៍និងដំណើរការនានា នឹងត្រូវបង្កើតសម្រាប់ការធ្វើសេចក្តីរាយការណ៍ពីមូលដ្ឋាន ចំណែកឯវេទិកា នឹងត្រូវរៀបចំឡើង ដើម្បីជំរុញឲ្យមានការជជែកពិភាក្សាដេញដោល និងសន្ទនាតាមគោលការណ៍បើកទូលាយ សម្រាប់ការសិក្សារៀនសូត្រ។ យុទ្ធសាស្ត្រនិងផែនការសកម្មភាពលម្អិត សម្រាប់សកម្មភាពសិក្សារៀនសូត្រ ការស្រាវជ្រាវ និងត្រួតពិនិត្យតាមដាន ដែលជាគោលការណ៍ណែនាំក្នុងការសិក្សារៀនសូត្រ នឹងត្រូវរៀបចំឡើង ក្នុងអំឡុងពេលនៃការរៀបចំតាក់តែងកម្មវិធី និងនៅពេលចាប់ផ្តើមអនុវត្ត។ យុទ្ធសាស្ត្រនេះនឹងបញ្ចូលនូវលទ្ធផលជាច្រើនដែលត្រូវរៀបរាប់នៅផ្នែកខាងក្រោម។

### លទ្ធផល ៤.២ ឧបករណ៍ និងឯកសារណែនាំនានាត្រូវបានរៀបចំ និងផ្សព្វផ្សាយ

ដើម្បីឲ្យមានការផ្តោតខ្លាំងទៅលើ "ការសិក្សាតាមរយៈការអនុវត្តផ្ទាល់" អ្នកពាក់ព័ន្ធនានានៅមូលដ្ឋានត្រូវបានលើកទឹកចិត្ត និងគាំទ្រឲ្យមានការចូលរួមនៅក្នុងដំណើរការជាប្រចាំនៃការឆ្លុះបញ្ចាំង និងការអនុវត្តនានា។ គេរំពឹងថា ការសិក្សារៀនសូត្រ នឹងត្រូវគាំទ្រ សម្របសម្រួលដោយដៃគូអនុវត្ត តាមរយៈការសហការជាមួយនឹងដៃគូដទៃទៀតនៅមូលដ្ឋាន។ ការសិក្សារៀនសូត្រ គឺជាគោលបំណងសំខាន់ នៅក្នុងសំណើនានាសម្រាប់ការផ្តល់មូលនិធិគាំទ្រ ដែលត្រូវរៀបចំដោយដៃគូអនុវត្តនានា។ ការអនុវត្តបែបនេះត្រូវផ្អែកលើឯកសារណែនាំទាំងឡាយដែលបង្កើតឡើងដោយដៃគូជំនាញក្នុងការសិក្សារៀនសូត្រ។

### លទ្ធផល ៤.៣ វេទិកាសិក្សារៀនសូត្រ និងការផ្តល់យោបល់ត្រឡប់ត្រូវបានរៀបចំជាទៀតទាត់

មានការរំពឹងទុកថា វេទិកាសម្រាប់ការផ្លាស់ប្តូរ ការជជែកពិភាក្សា និងការសន្ទនានានា នឹងត្រូវរៀបចំឡើងពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិ ដើម្បីផ្តល់ជាវេទិកាចូលរួមយោបល់ដោយសេរីអំពីអ្វីដែលអ្នកចូលរួមបានសិក្សារៀនសូត្រ។ កិច្ចការនេះ ពាក់ព័ន្ធជាមួយការផ្តល់សិទ្ធិ និងការចូលរួមពីអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ នៅក្នុងដំណើរការឆ្លុះបញ្ចាំង និងការសម្របសម្រួលនានា រវាងអង្គការដៃគូនៅមូលដ្ឋាន។ ដៃគូអនុវត្តនានានៅថ្នាក់ជាតិ នឹងសម្របសម្រួលនូវដំណើរការ និងការផ្លាស់ប្តូរយោបល់លើប្រធានបទនានា ក្នុងការចែករំលែកបទពិសោធន៍។ ដៃគូសម្រាប់ការសិក្សារៀនសូត្រ នឹងជំរុញរៀបចំឲ្យមានវេទិកាពីរដងក្នុងមួយឆ្នាំ (រួមមានស្ថាប័ន អង្គភាពរដ្ឋ និងអង្គការសង្គមស៊ីវិលសំខាន់ៗ ក៏ដូចជាអ្នកពាក់ព័ន្ធការងារស្រាវជ្រាវនានា) ដើម្បីធ្វើការពិភាក្សា និងសម្រេចលើមេរៀនដែលទទួលបាន។

### លទ្ធផល ៤.៤ ការផ្តល់យោបល់ត្រឡប់ និងដំណើរការពិនិត្យកែសម្រួលគោលនយបាយ ដើម្បីលើកកម្ពស់ការអនុវត្ត ផ.អ.គ.ស ត្រូវបានបង្កើត

ទន្ទឹមនឹងការរំពឹងទុកថា ដៃគូអនុវត្តនៅមូលដ្ឋានអាចមានភាពបត់បែនក្នុងការប្រើប្រាស់ឧបករណ៍នានាស្របតាមបរិបទនៅក្នុងមូលដ្ឋានរបស់ខ្លួន គេក៏រំពឹងថានៅក្នុងដំណើរការនៃការអនុវត្ត នឹងទទួលបាននូវមេរៀន

ជាច្រើន ដែលអាចជួយដល់ដៃគូទាំងអស់នៅក្នុងការអនុវត្ត ផ.អ.គ.ស។ មេរៀនបទពិសោធន៍ដែលទទួលបាន នឹងត្រូវចងក្រងជាឯកសារទៅតាម៖

១) មេរៀនបទពិសោធន៍ ដែលអាចលើកកម្ពស់ការអនុវត្តនូវដំណើរការនានាដែលមានស្រាប់ (មេរៀនទាំងនេះនឹងត្រូវផ្សព្វផ្សាយតាមរយៈការធ្វើបច្ចុប្បន្នភាព និងកែសម្រួលឯកសារណែនាំនានា)

២) មេរៀនទាំងឡាយណា ដែលប៉ះពាល់ ឬធ្វើឲ្យមានការផ្លាស់ប្តូរគោលនយោបាយ និងដំណើរការនានាដែលបង្កើតឡើងរហូតមកទល់បច្ចុប្បន្ននេះ។

មេរៀនទាំងឡាយ ដែលប៉ះពាល់ដល់ការផ្លាស់ប្តូរគោលនយោបាយនឹងត្រូវចងក្រង និងផ្សព្វផ្សាយ ព្រមទាំងធ្វើការកែសម្រួលនូវគោលការណ៍ ឬនីតិវិធីដែលមានស្រាប់។ ដំណើរការនៃការកែសម្រួល និងការផ្តល់មតិយោបល់ត្រឡប់ នឹងជួយដល់ការអនុវត្តផ.អ.គ.ស ក្នុងដំណើរការសិក្សារៀនសូត្រ ក៏ដូចជា អាចសម្របទៅតាមការចាំបាច់ដើម្បីធ្វើឲ្យលទ្ធផលប្រសើរឡើងជាបន្តបន្ទាប់។

**លទ្ធផល ៤.៥ ការសិក្សាជាក់លាក់ត្រូវបានរៀបចំដោយដៃគូជំនាញលើការសិក្សារៀនសូត្រ ដើម្បីគាំទ្រដល់ការអភិវឌ្ឍគោលនយោបាយ និងការអនុវត្ត ផ.អ.គ.ស**

*របៀបអនុវត្តផ.អ.គ.ស នៅតំបន់ទីប្រជុំជន៖* នៅក្នុងដំណាក់កាលដំបូង ការអនុវត្តផ.អ.គ.សនឹងផ្តោតលើការអនុវត្តនៅតាមស្រុកនៅជនបទ ប៉ុន្តែស្របពេលជាមួយគ្នានេះដែរ ដំណើរការនៃការបង្កើតឲ្យមានរបៀបអនុវត្ត ផ.អ.គ.ស នៅតំបន់ទីប្រជុំជននឹងត្រូវរៀបចំដោយដៃគូជំនាញអនុវត្តការសិក្សារៀនសូត្រ។ គេរំពឹងថាស្របពេលដែលរបៀបអនុវត្តទាំងនោះធ្វើឡើងដើម្បីទទួលបាននូវលទ្ធផលដូចគ្នា និងផ្អែកលើបទពិសោធន៍នៃការអនុវត្ត ផ.អ.គ.សនៅទីជនបទ របៀបអនុវត្តទាំងនោះនឹងសម្របតាមបរិបទផ្សេងៗទៅតាមស្ថាប័នអង្គភាព និងសហគមន៍តាមទីប្រជុំជន (មានន័យថា សេវាសម្រាប់ទីប្រជុំជន និងបញ្ហាជាអាទិភាពរបស់សហគមន៍ជនបទការ ត្រូវអនុវត្តសេវានិងមានធនធានផ្សេងៗគ្នា ប្រជាពលរដ្ឋក៏ត្រូវការព័ត៌មានផ្សេងៗគ្នា ហើយដំណើរការសម្រាប់ការចូលរួមក៏ខុសៗគ្នាផងដែរ)។ នៅឆ្នាំ២០១៥ ដៃគូជំនាញអនុវត្តការសិក្សារៀនសូត្រនឹងធ្វើការសិក្សា រៀបចំសិក្ខាសាលា និងរៀបចំឯកសារសម្រាប់អនុវត្តផ.អ.គ.ស នៅទីប្រជុំជន។ រហូតដល់ចុងឆ្នាំ២០១៥ ឧបករណ៍និងដំណើរការទាំងឡាយសម្រាប់តំបន់ទីប្រជុំជន នឹងអាចបង្កើតឡើងក្នុងគោលបំណង ពង្រីកសកម្មភាពទៅដល់សង្កាត់ និងក្រុងក្នុងឆ្នាំ២០១៦-២០១៧។

*ឱកាសក្នុងការធ្វើឲ្យគណនេយ្យភាពសង្គមមានភាពប្រសើរឡើងតាមរយៈយន្តការបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគម៍។* តាមរយៈបទពិសោធន៍ពីប្រទេសនានាបានបង្ហាញថា យន្តការដើម្បីឲ្យមានការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើឲ្យការផ្តល់សេវា និងការវិភាជន៍ធនធានកាន់តែប្រសើរឡើង អាចពង្រឹងបានតាមរយៈ ការប្រើប្រាស់យន្តការបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគម៍។ ប៉ុន្តែមកទល់នឹងពេលនេះ ប្រទេសកម្ពុជាមិនទាន់បានប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគម៍ ដើម្បីលើកកម្ពស់ការទទួលបាននូវព័ត៌មាន ការដោះស្រាយបណ្តឹងតវ៉ានានា ឬប្រព័ន្ធគណនេយ្យភាពណាមួយនៅឡើយ។ ការប្រើប្រាស់បច្ចេកវិទ្យាទូរស័ព្ទនៅក្នុងប្រទេសកម្ពុជា និងការបង្កើនតំបន់គ្របដណ្តប់សេវាច្រើនឡើងៗ នឹងផ្តល់ជាមធ្យោបាយដើម្បីសាកល្បងមើលថាតើប្រជាពលរដ្ឋកម្ពុជាប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគម៍បានកម្រិតណា។ នៅក្នុងកម្មវិធីដែលផ្តោតទៅលើការសិក្សារៀនសូត្របទពិសោធន៍ នឹងធ្វើការស្រាវជ្រាវ និងសាកល្បងនូវជម្រើសក្នុងការប្រើប្រាស់នូវមធ្យោបាយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគម៍ ព្រមទាំងកំណត់អ្នកដែលទទួលជោគជ័យទាំងពីខាងស្ថាប័ន

អង្គភាពរបស់រដ្ឋ និងសង្គមស៊ីវិលក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរ និងធ្វើការពិចារណាពីអាទិភាពសម្រាប់សាកល្បង នៅក្នុងបរិបទនៃការអនុវត្ត ផ.អ.គ.ស។

*និរន្តរភាពនៃការរៀបចំស្ថាប័នសម្របសម្រួលសកម្មភាពក្នុងការអនុវត្តផ.អ.គ.ស* ការលើកកម្ពស់និរន្តរភាពនៃដំណើរការសម្របសម្រួលគណនេយ្យភាពសង្គម គឺជាចំនុចសំខាន់ក្នុងការផ្តួចផ្តើមអនុវត្តគណនេយ្យភាពសង្គមទូទាំងប្រទេស។ នៅពេលចាប់ផ្តើមដំបូងនៃកម្មវិធី យុទ្ធសាស្ត្រក្នុងការសម្របសម្រួលនិងការសាកល្បងរៀបចំសម្របសម្រួលត្រូវបានអនុវត្ត។ ការងារនេះ នឹងការបង្ហាញនូវជម្រើសនានា និងលក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការវាយតម្លៃ (ដែលត្រូវធ្វើឡើងដោយដៃគូជំនាញក្នុងការរៀនសូត្របទពិសោធន៍ និងការត្រួតពិនិត្យតាមដាន)។ ក្នុងចំណោមជម្រើសផ្សេងៗទៀត ការិយាល័យប្រជាពលរដ្ឋ ឬតំណាងប្រជាពលរដ្ឋ ត្រូវបានចាត់ទុកជាកន្លែងមួយដែលធ្វើការសម្របសម្រួលសកម្មភាពគណនេយ្យភាពសង្គមនៅថ្នាក់ស្រុក[28]។

## សមាសភាគ ៤ខ ការត្រួតពិនិត្យតាមដាន និងលទ្ធផល

### លទ្ធផល ៤.៦ ការត្រួតពិនិត្យតាមដានលើលទ្ធផលត្រូវបានរៀបចំឡើងស្របតាមក្របខ័ណ្ឌការងារដែលបានព្រមព្រៀង

វិធីសាស្ត្រនេះ នឹងយកចិត្តទុកដាក់ទៅលើលទ្ធផលនានា ព្រមទាំងមានការទទួលស្គាល់ថាការផ្លាស់ប្តូរប្រែប្រួលនូវសមិទ្ធិផលនៃការងារនេះត្រូវទាមទារនូវពេលវេលាច្រើន។ ដើម្បីសម្រេចលទ្ធផលនេះរបាយការណ៍ នៅឆ្នាំទីមួយនឹងផ្តោតទៅលើលទ្ធផលជាក់លាក់មួយចំនួន ដែលពាក់ព័ន្ធនឹងព័ត៌មាន ថវិកា និងការត្រួតពិនិត្យ តាមដានរបស់ប្រជាពលរដ្ឋ។ ក្របខ័ណ្ឌលទ្ធផលនៅក្នុងផ្នែកទី៧ រួមមានសូចនាការសមិទ្ធិផលរបស់គម្រោង ក៏ដូចជាលទ្ធផលដែលទទួលបានភ្លាមៗ (លទ្ធផលសំខាន់ៗចំនុចដៅ សូចនាករ និងថវិកា)។ លទ្ធផលដែលទទួលបានភ្លាមៗនឹងត្រូវបង្ហាញនៅក្នុងសមាសភាគនីមួយៗនៃសមាសភាគទាំងបី។ ទិន្នន័យនិងរបាយការណ៍ អនុវត្ត នឹងត្រូវរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាល ដែលជួយសម្របសម្រួលអនុវត្តផ្នែកតម្រូវការនិងគ.ជ.អ.ប ដែលអនុវត្តការងារលើផ្នែកផ្គត់ផ្គង់។ ដៃគូជំនាញពាក់ព័ន្ធការសិក្សារៀនសូត្រ នឹងចងក្រងនូវព័ត៌មានទាំងនេះឲ្យបានគ្រប់ជ្រុងជ្រោយទៅក្នុងរបាយការណ៍រួមគ្នាប្រចាំត្រីមាសនិងប្រចាំឆមាស។ របាយការណ៍ទាំងនេះមានបញ្ចូលនូវការពិនិត្យមើលឡើងវិញ និងការវាយតម្លៃរបស់ដៃគូជំនាញពាក់ព័ន្ធការសិក្សាបទពិសោធន៍លើបញ្ហា ឧបសគ្គ និងអនុសាសន៍នានា។ ការត្រួតពិនិត្យមើលឡើងវិញនេះអាចនឹងធ្វើឡើងដោយផ្តោតលើប្រធានបទជាក់លាក់ ឬក៏ប្រើប្រាស់នូវវិធីសាស្ត្រករណីសិក្សា (ឧទាហរណ៍ ការចងក្រងសហគមន៍) ជាជាងផ្តោតលើទិដ្ឋភាពទូទៅនៃការអនុវត្ត។ របាយការណ៍ទាំងនោះនឹងអាចរកបានជាសាធារណៈ និងយកមកធ្វើការពិភាក្សាក្នុងកិច្ចប្រជុំត្រីមាស ដែលធ្វើឡើងដើម្បីត្រួតពិនិត្យលើការអនុវត្ត ដឹកនាំដោយដៃគូជំនាញពាក់ព័ន្ធសិក្សារៀនសូត្របទពិសោធន៍ និងមានអ្នកចូលរួមទាំងផ្នែកតម្រូវការនិងផ្នែកផ្គត់ផ្គង់។

[28] បច្ចុប្បន្ននេះ មុខងារនេះបានបង្កើតឡើងនៅក្នុងក្រុងចំនួន ៣៥ និងបានសាកល្បងនៅក្នុងស្រុក១។ ការិយាល័យប្រជាពលរដ្ឋបង្កើតឡើងក្នុង គោលបំណងដើម្បីផ្តល់ការណែនាំ និងផ្តល់ការគោរព និងមិនចំណុះបុគ្គលណាមួយឡើយ។ ការិយាល័យប្រជាពលរដ្ឋកើតឡើងដោយកាបោះឆ្នោតរបស់គណៈកម្មការនៅមូលដ្ឋានដែលមានសមាសភាពមកពីសមាជិកក្រុមប្រឹក្សាស្រុក រួមជាមួយនឹងតំណាងមកពីខាងអាជីវករ៣រូប និងតំណាងពីសង្គមស៊ីវិល៣ រូបទៀតដើម្បីធានានូវភាពស្របច្បាប់និងឯករាជ្យភាព។ មុខងារបច្ចុប្បន្នរបស់ការិយាល័យប្រជាពលរដ្ឋគឺទទួលដោះស្រាយនូវការប្តឹងផ្តល់របស់ប្រជាពលរដ្ឋ និងត្រួតពិនិត្យមើលដំណើរការប្រព្រឹត្តទៅរបស់ការិយាល័យច្រកចេញចូលតែមួយ។ ប្រសិនបើយន្តការនេះត្រូវបានយកទៅអនុវត្ត នៅតំបន់ជនបទក្នុងដំណាក់កាលបន្ទាប់នៃការអនុវត្តផអ៣ គេត្រូវពិចារណាលើការបង្កើតឲ្យមានការិយាល័យប្រជាពលរដ្ឋដែលជាតួនាទីមួយដ៏សំខាន់។

## លទ្ធផល ៤.៧ ការវាយតម្លៃលើផលប៉ះពាល់ត្រូវបានអនុវត្ត

ការវាយតម្លៃលើផលប៉ះពាល់ ត្រូវធ្វើឡើងដោយការប្រៀបធៀបនូវសូចនាករនៃសមិទ្ធិផលទទួលបាន រវាងទិន្នន័យដើមគ្រា ជាមួយទិន្នន័យបណ្តាឆ្នាំក្រោយពេលអនុវត្តកម្មវិធី និងប្រៀបធៀបរវាងក្រុមដែលមិនបានអនុវត្តសកម្មភាពជាមួយក្រុមអនុវត្តសកម្មភាព [29] ។ សូចនាករមួយចំនួនទៀត ក៏នឹងត្រូវយកមកធ្វើការប្រៀបធៀបដែរដូចជា៖

១) សូចនាករកញ្ចប់ព័ត៌មាន I4Cs (អត្រាអ្នកចុះឈ្មោះចូលរៀន អត្រាទទួលបានវ៉ាក់សាំង ។ល។)
២) សូចនាករប័ណ្ណដាក់ពិន្ទុនៅសហគមន៍ (ដែលប្រើសម្រាប់វាស់ស្ទង់ពីការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវានានា)
៣) សូចនាករស្តីពីការយល់ដឹងរបស់ប្រជាពលរដ្ឋ ការលើកកម្ពស់សិទ្ធិអំណាច និងការវាយតម្លៃពីការឆ្លើយតបនានាដែលប្រមូលបានពីការធ្វើការអង្កេតលើប្រជាពលរដ្ឋ[30]។

## លទ្ធផល ៤.៨ ដំណើរការចងក្រងជាឯកសារ និងសវនកម្មត្រូវបានរៀបចំអនុវត្ត

ដំណើរការនានាដូចជា ការបណ្តុះបណ្តាល ការសម្របសម្រួល ការទទួលយកអនុសាសន៍របស់ ប្រជាពលរដ្ឋ ការបញ្ច្រាបយុវវ័យ ការផ្តួចផ្តើមផ្សេងៗ និងនិរន្តរភាព នឹងត្រូវវាយតម្លៃតាមរយៈសវនកម្មលើដំណើរការអនុវត្ត។ ការត្រួតពិនិត្យមើលឡើងវិញលើគោលនយោបាយក្នុងមួយឆមាសម្តង ផ្តល់ឱកាសក្នុងការពិ ភាក្សាអំពីមេរៀនបទពិសោធន៍ដែលទទួលបាន។ មេរៀនបទពិសោធន៍ដែលទទួលបាន នឹងផ្តោតទៅលើកម្រិតនៃការផ្លាស់ប្តូរប្រែប្រួល ដែលដំណើរការអនុវត្តបានធ្វើឲ្យមានផលប៉ះពាល់ដល់លទ្ធផលនានា។ ការសម្រេចចុងក្រោយនៃសវនកម្មលើដំណើរការអនុវត្ត នឹងធ្វើឡើងនៅពេលដែលយុទ្ធសាស្ត្រស្តីពីការប្រមូល ចងក្រងបទពិសោធន៍ និងស្រាវជ្រាវត្រូវបានបញ្ចប់។ ការធ្វើសវនកម្មលើដំណើរការរួមមាន ប្រសិទ្ធភាពនៃការបណ្តុះបណ្តាលនិងដំណើរការ និងវិធីសាស្ត្រផ្សេងៗក្នុងការបណ្តុះបណ្តាលដែលមានប្រសិទ្ធភាពខ្ពស់ ការរៀបចំផ្សេងៗក្នុងការសម្របសម្រួលវិធីសាស្ត្រប៉ះពាល់លើការអនុវត្ត អត្រាទទួលយកអនុសាសន៍របស់ប្រជាពលរដ្ឋនៅមានកម្រិត ការបញ្ច្រាបយេនឌ័រប្រសិទ្ធភាពមានប្រសិទ្ធភាពកម្រិតណា បញ្ហាយេនឌ័រត្រូវបានដោះស្រាយដោយជោគជ័យកម្រិតណា ការផ្តួចផ្តើមសកម្មភាពនៅមូលដ្ឋានទទួលបានលទ្ធផលកម្រិតណា ហើយតើការសម្រេចចិត្តនានាប៉ះពាល់លើនិរន្តរភាពកម្មវិធីកម្រិតណា។ គេរំពឹងថា ភាគច្រើននៃការសិក្សាទាំងនេះ នឹងត្រូវចុះកិច្ចសន្យាបន្តពីដៃគូជំនាញពាក់ព័ន្ធការសិក្សារៀនសូត្របទពិសោធន៍ទៅឲ្យទីប្រឹក្សាជំនាញ និងអ្នកស្រាវជ្រាវផ្សេងៗទៀត។

**សមិទ្ធិផលនានាក្នុងសមាសភាគ** ដែលពាក់ព័ន្ធការប្រមូលមេរៀនបទពិសោធន៍និងការត្រួតពិនិត្យតាមដាន នឹងប្រឹងប្រែងបង្កើតទម្លាប់នៃការសិក្សារៀនសូត្របទពិសោធន៍ក្នុងចំណោមអ្នកពាក់ព័ន្ធនានា ហើយខិតខំធ្វើឲ្យមេរៀនបទពិសោធន៍ដែលទទួលបានជាក់ស្តែង ត្រូវបានដាក់បញ្ចូលក្នុងគោលនយោបាយ និងដំណើរការអនុវត្ត។ ភ្នាក់ងារអនុវត្តនានា នឹងមានទំនោរក្នុងការប្រើប្រាស់វិធីសាស្ត្រផ្ទាល់ខ្លួន និងផ្តោតការយកចិត្តទុកដាក់ពិសេសតែ

---

[29] ការប្រើប្រាស់វិធីសាស្ត្រDD ដើម្បីឲ្យស្របទៅតាមបរិបទនីមួយៗ ។ វិធីសាស្ត្រDD កាន់តែមានការប្រើប្រាស់ច្រើនឡើងនៅក្នុងវិស័យសេដ្ឋកិច្ច អភិវឌ្ឍ។ សម្រាប់ព័ត៌មានបន្ថែមអាចចូលទៅក្នុងគេហទំព័រ http://www.poertyactionlab.org/។ គេទំនងជាលើកយកបច្ចេកទេសដែលប្រើប្រាស់សម្រាប់សិក្សាពីទំនាក់ទំនងខុសប្លែកគ្នា រវាងក្រុមដែលមិនទាន់បានអនុវត្តសកម្មភាព និងក្រុមដែលបានអនុវត្តសកម្មភាព ដោយសារតែការងាររបស់ឃុំទំនងជាមិនបានធ្វើឡើងដោយព្រាវៗឡើយ។

[30] ដើម្បីធ្វើការអង្កេតនេះ ចាំបាច់ត្រូវយកចិត្តដាក់ឲ្យបានច្រើនលើការវាស់វែងពីចំណេះដឹង ជាជាងសួរសំនួរនាំមុខដូចជា "តើអ្នកបានដឹងអំពីលុយរបស់សាលាដែរឬទេ?"។

នៅក្នុងបរិបទនៃក្របខ័ណ្ឌ ដែលមាននៅក្នុង ផ.អ.គ.ស (ឧទាហរណ៍៖ ផលប៉ះពាល់លើស្ត្រី ឬយុវវ័យ)។ ស្រប ពេលជាមួយគ្នានោះ សមាសភាគនេះបង្កើតឲ្យមានគោលបំណងដោយឡែកៗ ការសិក្សារៀនសូត្របទ ពិសោធន៍អំពីអ្វីដែលអនុវត្តបាន និងអនុវត្តមិនបាន ព្រមទាំងធ្វើឲ្យមេរៀនបទពិសោធន៍នៅមូលដ្ឋាន ត្រូវបាន យល់ដឹង និងមានការចែករំលែកទូទាំងប្រទេស។ សមាសភាគដែលពាក់ព័ន្ធការរៀនសូត្របទពិសោធន៍នឹងត្រូវ៖

១) ធានាថាការផ្តួចផ្តើមច្នៃប្រឌិតដែលប្រើតាមស្ថានភាពនៅមូលដ្ឋាន និងតាមសហគមន៍ជាក់លាក់ ហើយអាចយកទៅអនុវត្តនៅកន្លែងផ្សេងៗទៀត

២) ធានាថាគោលនយោបាយ និងគោលការណ៍ណែនាំនានារបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងតម្លាភាព និងគណនេយ្យភាពមានការឆ្លើយតបទៅនឹងបញ្ហា និងទទួលបានជោគជ័យ។

**តារាងសង្ខេប សមាសភាគទី៤ ការសម្របសម្រួល និងការពង្រឹងសមត្ថភាព**

| ផ្នែក | ការរៀបរាប់ |
|---|---|
| គោលបំណង | បង្កើតឲ្យមានវប្បធ៌មក្នុងការសិក្សារៀនសូត្រក្នុងចំណោមតួអង្គទាំងអស់។<br>ធានាឲ្យមានការរៀនសូត្រដោយផ្អែកលើភាពជាក់ស្តែង និងដាក់បញ្ចូលទៅក្នុងគោលនយោបាយ និងការអនុវត្ត។<br>លើកកម្ពស់ការយល់ដឹង និងវាស់ស្ទង់ពីលទ្ធផល។ |
| អនុសមាសភាគ | **៤ក. ការប្រមូលមេរៀនបទពិសោធន៍ និងការផ្តល់យោបល់ត្រឡប់** |
| លទ្ធផល | លទ្ធផល៤.១ យុទ្ធសាស្ត្រ និងផែនការសកម្មភាពក្នុងការប្រមូលមេរៀនបទពិសោធន៍ ដែលមានលក្ខណៈច្នៃប្រឌិតត្រូវបានបង្កើតឡើង<br>លទ្ធផល ៤.២ ឧបករណ៍ និងឯកសារណែនាំនានាត្រូវបានរៀបចំ និងផ្សព្វផ្សាយ<br>លទ្ធផល ៤.៣ វេទិកាសិក្សារៀនសូត្រ និងការផ្តល់យោបល់ត្រឡប់ត្រូវបានរៀបចំជាទៀតទាត់<br>លទ្ធផល ៤.៤ ការផ្តល់យោបល់ត្រឡប់ និងដំណើរការពិនិត្យកែសម្រួលគោលនយបាយ ដើម្បីលើកកម្ពស់ការអនុវត្ត ផស .គ.អ. ត្រូវបានបង្កើត<br>លទ្ធផល ៤.៥ ការសិក្សាជាក់លាក់ត្រូវបានរៀបចំដោយដៃគូជំនាញលើការសិក្សារៀនសូត្រ ដើម្បីគាំទ្រដល់ការអភិវឌ្ឍគោលនយោបាយ និងការអនុវត្ត ផស.គ.អ.<br>**៤ខ. ការត្រួតពិនិត្យតាមដាន និងលទ្ធផល**<br>លទ្ធផល ៤.៦ ការត្រួតពិនិត្យតាមដានលើលទ្ធផលត្រូវបានរៀបចំឡើងស្របតាមក្របខ័ណ្ឌការងារដែលបានព្រមព្រៀង<br>លទ្ធផល ៤.៧ ការវាយតម្លៃលើផលប៉ះពាល់ ត្រូវបានអនុវត្ត<br>លទ្ធផល ៤.៨ ដំណើរការចងក្រងជាឯកសារនិងសវនកម្មត្រូវបានរៀបចំអនុវត្ត |

# ផ្នែកទី៣ ការរៀបចំស្ថាប័ន

## ៣.១. ការរៀបចំស្ថាប័នទូទៅ

**ការរៀបចំស្ថាប័ននឹងធ្វើឡើងដើម្បីអនុវត្តការងារនៅក្នុងដំណើរការ និងរចនាសម្ព័ន្ធដែលមានស្រាប់។** ដោយសារតែ ផ.អ.គ.ស គឺជាសកម្មភាពនៃកម្មវិធីទូទាំងប្រទេសដែលមានភាពជាក់លាក់ទាំងការគាំទ្រ និងពង្រឹងដល់កំណែទម្រង់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដូច្នេះប្រព័ន្ធ និងរចនាសម្ព័ន្ធដែលមានស្រាប់នឹងត្រូវយកមកប្រើប្រាស់។

**សកម្មភាពទាំងឡាយនឹងត្រូវអនុវត្តដោយស្ថាប័ន អង្គភាពរបស់រដ្ឋាភិបាល និងសង្គមស៊ីវិល ឬអនុវត្តដោយស្ថាប័នទាំងពីរ។** ក្នុងការអនុវត្តជាក់ស្តែង សកម្មភាពមួយចំនួនដែលបានរៀបរាប់នៅក្នុងសមាសភាគទាំងបួនរបស់ ផ.អ.គ.ស នឹងត្រូវអនុវត្តដោយផ្នែកផ្គត់ផ្គង់ សកម្មភាពខ្លះទៀតត្រូវអនុវត្តដោយផ្នែកតម្រូវការ ហើយសកម្មភាពផ្សេងទៀតត្រូវអនុវត្តរួមគ្នាដើម្បីទទួលបានប្រសិទ្ធភាពកាន់តែប្រសើរ។ ភស្តុតាងបង្ហាញថា សកម្មភាពមួយចំនួននៃការងារគណនេយ្យភាពសង្គម ត្រូវដឹកនាំដោយរដ្ឋាភិបាល (ឧទាហរណ៍៖ ការចេញគោលការណ៍ណែនាំនានាដើម្បីឲ្យមានការបិទផ្សាយព័ត៌មានរបស់ផ្នែកផ្គត់ផ្គង់) ចំណែកសកម្មភាពផ្សេងៗទៀត (ឧទាហរណ៍៖ ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃរបស់ប្រជាពលរដ្ឋ) ត្រូវបានអនុវត្តដោយឯករាជ្យ ដោយមានការគាំទ្រពីអង្គការសង្គមស៊ីវិល ហើយចំណេះដឹងនេះត្រូវប្រើប្រាស់ដើម្បីធ្វើការសម្រេចចិត្តថាអ្នកណាត្រូវធ្វើអ្វី និងត្រូវរៀបចំដោយរបៀបណា។ មានសកម្មភាពពីររបស់ ផ.អ.គ.ស ដែលត្រូវធ្វើស្របគ្នា និងមានការសម្របសម្រួលរវាងផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់។ ឧបសម្ព័ន្ធ១ បែងចែកសកម្មភាពណាដែលដឹកនាំដោយរដ្ឋាភិបាល សកម្មភាពណាដែលដឹកនាំដោយអង្គការសង្គមស៊ីវិល និងសកម្មភាពណាដែលត្រូវដឹកនាំរួមគ្នា។ ជាការសំខាន់ណាស់ដែលត្រូវធ្វើការកត់សំគាល់ថា បើទោះបីជាមានសកម្មភាពខ្លះត្រូវរដ្ឋាភិបាលមានតួនាទីនាំមុខក៏ដោយ ក៏សង្គមស៊ីវិលមាន តួនាទីសំខាន់ក្នុងការគាំទ្រទៅវិញទៅមក។ ការធានាឲ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងការ កសាងទំនាក់ទំនងការងារដើម្បីទទួលបានលទ្ធផលល្អប្រសើររវាងស្ថាប័ន អង្គភាពរដ្ឋ និងសង្គមស៊ីវិល (នៅគ្រប់កម្រិតថ្នាក់ទាំងអស់) គឺជាកត្តាចម្បងដែលធ្វើឲ្យការអនុវត្តផ.អ.គ.ស ទទួលបានជោគជ័យ។

**ភ្នាក់ងារអនុវត្តសម្រាប់សកម្មភាពផ្នែកផ្គត់ផ្គង់នៃ ផ.អ.គ.ស គឺ គ.ជ.អ.ប។** លេខាធិការដ្ឋាន គ.ជ.អ.ប គឺជាភ្នាក់ងារអនុវត្តរាល់ការសម្របសម្រួលទាំងអស់ សម្រាប់កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការអនុវត្តផែនការអនុវត្តបីឆ្នាំ(ផអ៣) ដែលក្នុងនោះផ.អ.គ.ស ក៏ជាផ្នែកមួយនៃផែនការនេះដែរ។ រហូតមកដល់បច្ចុប្បន្ននេះ គ.ជ.អ.ប បានចូលរួមនៅក្នុងដំណើរការនេះយ៉ាងជិតស្និទ្ធិ និងបានដឹកនាំបញ្ចប់ និងបានអនុម័តឯកសារក្របខ័ណ្ឌគណនេយ្យភាពសង្គម ដែលជាផែនការយុទ្ធសាស្ត្រសម្រាប់ការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ[31] ។ លេខាធិការដ្ឋានគ.ជ.អ.ប គឺជាអង្គភាពសមស្របបំផុតក្នុងការដឹកនាំការអនុវត្ត ដោយសារតែលេខាធិការដ្ឋាននេះមានតួនាទីក្នុងការគ្រប់គ្រងកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការរៀបចំគោលនយោបាយនានាសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ នៅពេលដែលសកម្មភាពសម្រាប់ផ្នែកតម្រូវការនឹងត្រូវ

---

[31] គ.ជ.អ.ប ស្នើសុំជំនួយពីធនាគារក្នុងការរៀបចំឲ្យមានក្របខ័ណ្ឌគណនេយ្យភាពសង្គម។ គ.ជ.អ.បធ្វើជាម្ចាស់ផ្ទះក្នុងសិក្ខាសាលាពិគ្រោះយោបល់ និងអនុម័តកិច្ចប្រជុំផ្សេងទៀតជាមួយអង្គការសង្គមស៊ីវិល ហើយក៏បានតាំងចិត្តយ៉ាងមុតមាំក្នុងការរៀបចំក្របខ័ណ្ឌគណនេយ្យភាពសង្គម និងផែនការអនុវត្ត។

ចាប់ផ្តើមរៀបចំ និងធ្វើការសាកល្បងនៅក្នុងដំណាក់កាលនៃការបិទបញ្ចប់គម្រោងអភិបាលកិច្ចល្អ (DFGG)។ គ.ជ.អ.ប នឹងសម្របសម្រួលជាមួយនាយកសម្របសម្រួលគម្រោងរបស់ក្រសួងមហាផ្ទៃក្នុងការរៀបចំតាក់តែងលំអិត ការសាកល្បង និងអនុវត្ត[32]។ តួនាទី និងការទទួលខុសត្រូវជាក់លាក់ នឹងត្រូវរៀបរាប់នៅក្នុងផ្នែក៣.២ ខាងក្រោម។ **ខាងផ្នែកតម្រូវការ នឹងត្រូវចាត់ចែងដោយដោយភ្នាក់ងារ ឬរចនាសម្ព័ន្ធសម្របសម្រួលមួយ** (មិនទាន់កំណត់ជាក់លាក់នៅឡើយ) ដែលធ្វើការជាមួយក្រុមអង្គការដៃគូមួយចំនួននៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន (សូមមើលរូបភាពលេខ៣.១ និងផ្នែក ៣.៣)។

## ៣.២ ការទទួលខុសត្រូវរបស់អង្គភាពរដ្ឋ

នៅក្នុងស្ថាប័ន អង្គភាពមួយណារបស់រដ្ឋាភិបាលជាអ្នកទទួលខុសត្រូវ? តើសកម្មភាពនានាត្រូវបានរៀបចំដោយរបៀបណា?

នៅក្នុងស្ថាប័នរដ្ឋ លេខាធិការដ្ឋាន គ.ជ.អ.ប ដែលជាអង្គភាពទទួលខុសត្រូវអនុវត្តផ.អ.៣ នឹងរៀបចំឲ្យមានគោលនយោបាយ និងលិខិតបទដ្ឋានចាំបាច់នានាដើម្បីអនុវត្ត ផ.អ.គ.ស នៅពេលចាប់ផ្តើម និងដើរតួនាទីសម្របសម្រួលជាទូទៅក្នុងពេលអនុវត្តក្របខ័ណ្ឌនោះ។ តួនាទីទាំងនោះរួមមាន៖

- *ដឹកនាំនិងសម្របសម្រួលនៅថ្នាក់ជាតិ៖* ដើម្បីធានាឲ្យមានការចូលរួមពីក្រសួងសំខាន់ៗ និងតំណាងសង្គមស៊ីវិល។
- *ការដឹកនាំនៅថ្នាក់ក្រោមជាតិ៖* បង្កើតនិងលើកកម្ពស់តួនាទីរបស់ក្រុមប្រឹក្សាក្នុងការពិនិត្យមើលពីលើ និងតួនាទីជាតំណាង ពាក់ព័ន្ធនឹងការផ្តល់សេវានានាបែបរិសហមជ្ឈការ ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ មានតួនាទីគាំទ្រដល់សមាជិកក្រុមប្រឹក្សានៅក្នុងការត្រួតពិនិត្យតាមដានការអនុវត្ត ផ.អ.គ.ស និងធ្វើសេចក្តីរាយការណ៍ពីលទ្ធផលសម្រេចបាន។
- *កិច្ចសហការ៖* សហការជាមួយក្រសួងអប់រំ និងក្រសួងសុខាភិបាលដើម្បីធានាថាលិខិតបទដ្ឋានសំខាន់ៗត្រូវបានរៀបចំឡើង និងអនុវត្តដើម្បីលើកកម្ពស់ការផ្សព្វផ្សាយជាសាធារណៈ និងការផ្តល់សេវាតាមរយៈការពង្រឹងគណនេយ្យភាព។
- *ការគាំទ្រផ្នែកបច្ចេកទេស៖* ផ្តល់ការគាំទ្រតាមរយៈអង្គភាពវិភាគនិងអភិវឌ្ឍន៍គោលនយោបាយ និងអង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន ដើម្បីជួយរៀបចំបញ្ចប់ ដោយបញ្ចូលយន្តការសំខាន់ៗនៃយុទ្ធសាស្ត្រព័ត៌មាននៅក្នុងក្របខ័ណ្ឌការងារគណនេយ្យភាពសង្គម កញ្ចប់ព័ត៌មានI4Cs និងយន្តការចាំបាច់ដើម្បីឆ្លើយតបចំពោះការតាមដានរបស់ប្រជាពលរដ្ឋ (កិច្ចប្រជុំរួមគ្នា ផែនការសកម្មភាពគណនេយ្យភាព គណៈកម្មការតាមដានផែនការសកម្មភាពរួមគ្នា)។ យន្តការទាំងនេះមានបញ្ចូលផងដែរនូវការបង្កើតឲ្យមានគោលការណ៍ណែនាំពាក់ព័ន្ធនឹងការផ្សព្វផ្សាយព័ត៌មាន ការសម្រេចថាត្រូវធ្វើយ៉ាងណាដើម្បីពង្រឹងការអនុវត្តគោលការណ៍ទាំងនេះ ព្រមទាំងត្រូវមានការលើកទឹកចិត្តរបៀបណាដល់ក្រុមប្រឹក្សាដើម្បីផ្តល់ព័ត៌មាន និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋឲ្យកាន់តែប្រសើរ។

[32] ទំនាក់ទំនងនេះដូចគ្នានឹងអ្វីដែលបានបង្កើតឡើងសម្រាប់គ.ជ.អ.ប ក្នុងការអនុវត្តសមាសភាគការិយាល័យច្រកចេញចូលតែមួយ។

ការចូលរួមរបស់អង្គភាពរដ្ឋនៅមូលដ្ឋានពិតជាមានសារៈសំខាន់ដូចជា ឃុំ ស្រុក សាលារៀន និង មណ្ឌលសុខភាព (មានន័យថាសមាជិកក្រុមប្រឹក្សាឃុំ គ្រូបង្រៀន និងនាយកសាលា និងប្រធានមណ្ឌលសុខភាព)។ តួនាទី របស់ពួកគេម្នាក់ៗទាមទារឲ្យមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ដែលតាមរយៈនេះ ផ.អ.គ.សនឹង ជួយពួកគេឲ្យសម្រេចបានតួនាទីនេះ។

❖ **ក្រុមប្រឹក្សា និងរដ្ឋបាលស្រុក** មានតួនាទីក្នុងការផ្តល់ព័ត៌មាន ប្រមូលចងក្រងព័ត៌មាន និងសម្របសម្រួល។ តួនាទីនោះរួមមានៈ
  - ធ្វើការចងក្រងព័ត៌មាននៅថ្នាក់ស្រុក
  - ធ្វើការយ៉ាងសកម្មជាមួយអង្គការសង្គមស៊ីវិលនៅមូលដ្ឋាន (អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អង្គការសហគមន៍មូលដ្ឋាន និងអង្គការដៃគូនៅមូលដ្ឋាន) ក្នុងការទទួលបានកញ្ចប់ព័ត៌មាន (I4Cs)
  - គាំទ្រសកម្មភាពផ្សព្វផ្សាយព័ត៌មាន និងសម្របសម្រួលនៅថ្នាក់ស្រុក (ដូចជា ព្រឹត្តិការណ៍ព័ត៌មានដែលពាក់ព័ន្ធនឹងកញ្ចប់ព័ត៌មានI4Cs លទ្ធផលប័ណ្ណដាក់ពិន្ទុ និងផែនការសកម្មភាពគណនេយ្យភាព ព្រមទាំងការបញ្ចូលផែនការសកម្មភាពគណនេយ្យភាព ទៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ...។ល។)
  - ចូលរួមនៅក្នុងដំណើរការគណនេយ្យភាពសង្គម (ព័ត៌មាន ការងារថវិកា និងការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ) នៅពេលដែលមានមូលនិធិក្រុង ស្រុក។

❖ **ក្រុមប្រឹក្សាឃុំ** នឹងមានតួនាទីសំខាន់ពីរ ក្នុងនាមជាអ្នកដែលត្រូវមានគណនេយ្យភាពចំពោះ អ្នកប្រើប្រាស់សេវារបស់ក្រុមប្រឹក្សាឃុំ និងក្នុងនាមជាតំណាងកើតឡើងដោយការបោះឆ្នោតដែលត្រូវមានគណនេយ្យភាពទៅកាន់អ្នកដែលបោះឆ្នោតឲ្យ៖
  - ធ្វើការជាមួយអង្គការសង្គមស៊ីវិលនៅមូលដ្ឋាន (អ្នកសម្របសម្រួល គណនេយ្យភាពសហគមន៍ អង្គការសហគមន៍មូលដ្ឋាន និងអង្គការដៃគូនៅមូលដ្ឋាន) ដើម្បីធានានូវការទទួលបាននូវព័ត៌មាន និងថវិកា(I4Cs) ព្រមទាំងស្តាប់និងឆ្លើយតបចំពោះលទ្ធផលការនៃការត្រួតពិនិត្យ តាមដានរបស់ប្រជាពលរដ្ឋ (កិច្ចប្រជុំរួមគ្នា)
  - ដើរតួនាទីយ៉ាងសកម្មក្នុងការបង្កើតឲ្យមានផែនការសកម្មភាព ក្នុងនាមជាតំណាងប្រជាពលរដ្ឋជាអ្នកផ្តល់សេវា និងត្រួតពិនិត្យមើលការផ្តល់សេវានៅមូលដ្ឋាន
  - ដឹកនាំគណៈកម្មាការតាមដានការអនុវត្តផែនការសកម្មភាពរួម ។

❖ **អ្នកផ្តល់សេវា** [33] ក៏ដើរតួនាទីសំខាន់ផងដែរនៅក្នុងការធ្វើឲ្យប្រសើរឡើងក្នុងការទទួលបានព័ត៌មាន សហការជាមួយនឹងការត្រួតពិនិត្យតាមដានរបស់សហគមន៍ និងសម្របសម្រួលក្នុងការកែលំអឲ្យកាន់តែប្រសើរតាមរយៈ៖
  - ផ្តល់ព័ត៌មាន (ទាក់ទងនឹងការងារថវិកា ការបំពេញការងារ) តាមតម្រូវការក្នុងដំណាក់កាលនៃការប្រមូលព័ត៌មាន

[33] តួនាទីរបស់គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព និងគណៈកម្មការទ្រទ្រង់សាលានឹងត្រូវរៀបចំបន្ថែមដោយមានការប្រឹក្សាយោបល់ជាមួយ ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា។ ដើម្បីធានាឲ្យមានការទំនាក់ទំនងមួយដែលមិនមានការខ្វះចន្លោះ សំណើនឹងធ្វើឲ្យមានការទំនាក់ទំនងដោយផ្ទាល់រវាងអ្នកផ្តល់សេវានានា (ឧទាហរណ៍ រវាងគ្រូបង្រៀន និងនាយកសាលា ប្រធានមណ្ឌលសុខភាព និងបុគ្គលិក)។

- ធ្វើការជាមួយអង្គការសង្គមស៊ីវិលនៅមូលដ្ឋាន (អ្នកសម្របសម្រួល គណនេយ្យភាពសហគមន៍ អង្គការសហគមន៍មូលដ្ឋាន និងអង្គការដៃគូនៅមូលដ្ឋាន) ដើម្បីទទួលបានព័ត៌មាន និងការងារថវិកា(I4Cs) ដែលទាក់ទងនឹងសេវាកម្មរបស់ខ្លួន ចូលរួមជាមួយប្រជាពលរដ្ឋក្នុងដំណើរការត្រួតពិនិត្យតាមដាន និងចូលរួមនៅក្នុងកិច្ចប្រជុំរួមគ្នា។
- បំពេញតួនាទីសកម្មនៅក្នុងការបង្កើត និងឆ្លើយតបចំពោះសកម្មភាពដែលបានលើកឡើងនៅក្នុងផែនការសកម្មភាព ផ.ស.គ.រ និងធានាឲ្យមានការព្រមព្រៀងចំពោះសកម្មភាពដែលត្រូវបានអនុវត្ត
- ធ្វើឲ្យការផ្តល់សេវាមានភាពប្រសើរឡើង និងមាននិរន្តរភាព។

❖ **ការិយាល័យអប់រំ និងការិយាល័យសុខាភិបាលស្រុក៖** មន្ត្រីការិយាល័យអប់រំ និងការិយាល័យសុខាភិបាលស្រុក បានដើរតួនាទីសម្របសម្រួលនិងត្រួតពិនិត្យមើលពីលើ។ ការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម នឹងធ្វើឲ្យមន្ត្រីទាំងនេះ បំពេញការងារបានល្អប្រសើរជាងមុន តាមរយៈការផ្តល់មតិយោបល់កែលំអបានច្បាស់លាស់ជាងមុន ព្រមទាំងតាមរយៈការផ្តល់ធាតុចូលពីមូលដ្ឋានដើម្បីមន្ត្រីទាំងនោះបំពេញការងារដែលប្រគល់ឲ្យបានកាន់តែប្រសើរឡើង។ មន្ត្រីថ្នាក់ស្រុកនឹងបំពេញការងារចម្បងៗរួមមាន៖

- ផ្តល់ និងចងក្រងទិន្នន័យសម្រាប់កញ្ចប់ព័ត៌មាន I4Cs
- គាំទ្រការអនុវត្តសកម្មភាពនៅមូលដ្ឋានដែលបានកំណត់នៅក្នុងផែនការសកម្មភាពរួម
- ដើរតួជាអ្នកពាំនាំនូវព័ត៌មាន និងយោបល់ត្រឡប់ទៅកាន់ក្រសួងជំនាញដែលពាក់ព័ន្ធ។

## ៣.៣ ការទទួលខុសត្រូវរបស់សង្គមស៊ីវិល

**តើអង្គការសង្គមស៊ីវិលណាមួយជាអ្នកទទួលខុសត្រូវ? តើដៃគូសង្គមស៊ីវិលត្រូវរៀបចំរបៀបណា?**

អង្គការសង្គមស៊ីវិល នឹងមានអ្នកពាក់ព័ន្ធនៅកម្រិតផ្សេងៗគ្នាចូលរួមដូចរៀបរាប់នៅក្នុងរូបភាព ៣.១។

### រូបភាព ៣.១ ការរៀបចំការអនុវត្តសម្រាប់ផ្នែកតម្រូវការ




**ការសម្របសម្រួលនៅថ្នាក់ជាតិ៖** រចនាសម្ព័ន្ធក្នុងការសម្របសម្រួលមួយ នឹងបង្កើតឡើងដើម្បីធានាឲ្យមានការសម្របសម្រួលជាទូទៅខាងផ្នែកតម្រូវការ នៅក្នុងគណនេយ្យភាពសង្គម។ តួនាទីរបស់ភ្នាក់ងារឬគណៈកម្មការសម្របសម្រួល នឹងមានទំនាក់ទំនងជាមួយ គ.ជ.អ.ប ក្រសួងមហាផ្ទៃ និងក្រសួងផ្សេងៗទៀតទៅតាមការចាំបាច់ និងត្រូវរាយការណ៍ទៅកាន់ក្រុមសម្របសម្រួលថ្នាក់ជាតិ និងដៃគូផ្ដល់ជំនួយ។ ការងារជាក់លាក់រួមមាន៖

- **បង្កើតនីតិវិធី និងគោលការណ៍ណែនាំក្នុងការគ្រប់គ្រងផ្នែកតម្រូវការ សម្រាប់ការប្រើប្រាស់ដោយអង្គការ អន្តរជាតិ** ។ ដើម្បីដំណើរការផ្នែកតម្រូវការ ក្រុមការងាររៀបចំតាក់តែង នឹងរៀបចំសៀវភៅណែនាំដើម្បីគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន ដៃគូអង្គការសហគមន៍មូលដ្ឋាន និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ក្នុងការអនុវត្តនូវកម្មវិធី[34]។ ភាគីពាក់ព័ន្ធក្នុងការសម្របសម្រួលទូទៅ នឹងត្រូវរៀបចំសម្ភារៈធនធានចាំបាច់សម្រាប់ផ្នែកផ្គត់ផ្គង់ ។
- **ផ្ដល់ការសម្របសម្រួលទូទៅក្នុងផ្នែកតម្រូវការ៖** អង្គការឬរចនាសម្ព័ន្ធសម្របសម្រួលនឹងទទួលខុសត្រូវក្នុងការគាំទ្រដល់ក្រុមអង្គការដៃគូផ្សេងៗ ព្រមទាំងធ្វើឲ្យមានការសម្របសម្រួលនិងការប្រាស្រ័យទាក់ទងឲ្យកាន់តែមានប្រសិទ្ធភាពរវាងអង្គការទាំងនោះ។ អង្គការសម្របសម្រួល នឹងរាយការណ៍អំពី

[34] តាមរយៈដំណើរការរួមគ្នាដែលផ្ដល់ការគាំទ្រដោយគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន នៅក្នុងដំណាក់កាលដំបូងនៃការ រៀបចំតាក់តែង និងសាកល្បងក្រុមរៀបចំតាក់តែង ផ.អ.គ.ស នឹងទទួលខុសត្រូវក្នុងការរៀបចំឲ្យមាន ឧបករណ៍ សម្រាប់ ផ្នែកតម្រូវការ ដូចជា ប័ណ្ណដាក់ពិន្ទុសហគមន៍ ដំណើរការក្នុងការកំណត់ និងវាយតម្លៃសកម្មភាពត្រួតពិនិត្យស៊ីជម្រៅ គោលការណ៍ណែនាំស្ដីពីការចងក្រងសហគមន៍គោលការណ៍ណែនាំយុទ្ធនា ការលើកកម្ពស់ការយល់ដឹង និងការប្រើ ប្រាស់សារព័ត៌មាន ព្រមទាំងយុទ្ធសាស្ត្រក្នុងការរៀបចំស្ថាប័នផ្សេងៗសម្រាប់ការសម្របសម្រួល។

វឌ្ឍនភាព មានការប្រជុំជាទៀតទាត់ជាមួយអង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិ ក្នុងការរៀបចំការងារអភិបាលកិច្ចរបស់គម្រោង និងជួយបង្កើតឲ្យមានឧបករណ៍ចាំបាច់នានា ។

**ក្រុមអង្គការជាដៃគូ៖** ផែនការសកម្មភាពក្នុង ផ.អ.គ.ស នឹងធានាថាប្រជាពលរដ្ឋទទួលបានការគាំទ្រ ពីបណ្តាអ្នកពាក់ព័ន្ធនានារបស់អង្គការសង្គមស៊ីវិល (ដូចជា អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អង្គការសហគមន៍មូលដ្ឋាន និងអង្គការដៃគូនៅមូលដ្ឋាន) ដើម្បីចូលរួមក្នុងដំណើរការការងារគណនេយ្យភាពសង្គម។ ដូចបានរៀបរាប់ខាងលើ សកម្មភាពគណនេយ្យភាពសង្គមតាមសហគមន៍ នឹងនាំមុខដោយប្រជាពលរដ្ឋដែលមានការគាំទ្រដោយបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដែលទទួលបាននូវការបង្ហាត់បង្ហាញ និងគ្រប់គ្រងដោយអង្គការដៃគូនៅមូលដ្ឋាន និងអង្គការនៅថ្នាក់ខេត្ត និងថ្នាក់ជាតិដែលមានជំនាញក្នុងការសម្របសម្រួល ជំរុញ និងគាំទ្រ ព្រមទាំងបង្ហាត់បង្រៀន។ រចនាសម្ព័ន្ធដែលបានស្នើឡើង មានបង្ហាញក្នុងរូបភាព ៣.១ ហើយមុខងារដែលបានស្នើឡើងមានរៀបរាប់ខាងក្រោម។

- **អង្គការនានាដែលអនុវត្តគម្រោង៖** ធ្វើការជាមួយអង្គការដៃគូនៅថ្នាក់មូលដ្ឋាន ដោយបង្កើតភាពជាដៃគូថ្មីជាមួយអង្គការផ្សេងទៀតតាមការជាក់ស្តែង។ អង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិ ខេត្ត នឹង អនុវត្តសកម្មភាពមួយចំនួនដូចជា គ្រប់គ្រងចាត់ចែងលើការប្រើប្រាស់មូលនិធិ ផ្តល់ការគាំទ្រ ផ្តល់ ការបង្ហាត់បង្ហាញណែនាំ ផ្តល់ការបណ្តុះបណ្តាល និងដោះស្រាយបញ្ហាផ្សេងៗ ផ្តល់ការធានាលើគុណភាពការងារ ធ្វើរបាយការណ៍ ត្រួតពិនិត្យ និងបង្កើតបរិយាកាសឲ្យមានការសិក្សារៀនសូត្របទ ពិសោធន៍។ អង្គការដែលអនុវត្តគម្រោង នឹងផ្តល់មូលនិធិដល់ការចំណាយលើផ្នែកបុគ្គលិករបស់អង្គការនៅមូលដ្ឋាន (ក្នុងនោះមាន គ្រូបង្គោល អ្នកផ្តល់យោបល់ដែលធ្វើការពេញម៉ោងបីនាក់ និងអ្នកគ្រប់គ្រងមួយរូបដែលធ្វើការក្រៅម៉ោង) ចំណាយដោយផ្ទាល់លើការបណ្តុះបណ្តាល ការផ្តល់យោបល់ និងការរៀនសូត្រតាមរយៈការអនុវត្តសកម្មភាពផ្ទាល់ (ដូចជា ការធ្វើដំណើរ ប្រាក់បេសកកម្ម និងចំណាយសម្រាប់ការប្រជុំ)។ សកម្មភាពសំខាន់ៗរួមមាន (១) រៀបចំលក្ខណៈវិនិច្ឆ័យ និងលក្ខខ័ណ្ឌការងារសម្រាប់អង្គការនៅមូលដ្ឋាន (២)ជ្រើសរើសអង្គការដៃគូ និងចុះអនុស្សារណៈយោគយល់គ្នា ព្រមទាំងចុះកិច្ចសន្យាជាមួយអង្គការជាដៃគូទាំងនោះ និង(៣)រៀបចំកិច្ចប្រជុំប្រចាំត្រីមាសដើម្បីត្រួតពិនិត្យលើការបំពេញការងារ បញ្ហានានា និងការប្រឈមនានាក្នុងការអនុវត្តសកម្មភាពដែលពាក់ព័ន្ធនឹងផ្នែកតម្រូវការ។។
- **អង្គការដៃគូនៅមូលដ្ឋាន៖** អង្គការដៃគូនៅមូលដ្ឋានដែលមានទំនាក់ទំនងស្រាប់ជាមួយ ឃុំគោលដៅនឹងចាត់តាំងអ្នកសម្របសម្រួលដែលមានជំនាញ៣នាក់ក្នុងស្រុកនីមួយៗ ដើម្បីណែនាំ និងគាំទ្រ សកម្មភាពគណនេយ្យភាពសង្គម និងការអភិវឌ្ឍសមត្ថភាព។ អ្នកសម្របសម្រួលត្រូវមានស្ត្រីយ៉ាងតិចពាក់កណ្តាល ហើយមួយភាគបួននៃអ្នកសម្របសម្រួលត្រូវមានអាយុក្រោម៣០ឆ្នាំ។ គេរំពឹងថា អ្នកសម្រប សម្រួលជាទូទៅគឺជាអ្នកដែលធ្វើការជាបុគ្គលិករបស់អង្គការនៅមូលដ្ឋានឬស្ថិតនៅក្នុងបណ្តាញ របស់អង្គការដែលមានជំនាញក្នុងការសម្របសម្រួល ការបញ្ចុះបញ្ចូល និងតស៊ូមតិ ជំរុញ ឲ្យមានការសន្ទនាគ្នាក្នុងន័យស្ថាបនា និងយកចិត្តទុកដាក់បំពេញតួនាទី។ អ្នកសម្របសម្រួលរបស់ អង្គការដៃគូនៅមូលដ្ឋាន នឹងបង្កើត ពង្រឹង ព្រមទាំងផ្តល់យោបល់ ដល់បណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងអង្គការសហគមន៍មូលដ្ឋានដៃគូនានា ដូចដែលបានរៀបរាប់នៅផ្នែកខាងក្រោម។ តួនាទី អ្នកសម្របសម្រួលរបស់អង្គការនៅមូលដ្ឋានរួមមាន៖

- សម្របសម្រួលឲ្យមានការបង្កើតជាក្រុម និងការពង្រឹងសមត្ថភាព
- អភិវឌ្ឍសមត្ថភាពរបស់ក្រុមអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (ដោយផ្ដោតលើស្ត្រី និងយុវវ័យ)
- គាំទ្រដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដើម្បីធ្វើការសម្របសម្រួលលើសកម្មភាពផ្នែកតម្រូវការពាក់ព័ន្ធកញ្ចប់ព័ត៌មាន I4Cs ដោយជំរុញឲ្យមានការទាមទារនិង ស្វែងយល់ព័ត៌មាន រួមទាំងសមត្ថភាពយល់ដឹងអំពីថវិកា
- គាំទ្រដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដើម្បីធ្វើការសម្របសម្រួល ការអនុវត្តការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ (រួមមាន ការសម្របសម្រួលឲ្យមានការជួបជុំប្រជាពលរដ្ឋនៅថ្នាក់ឃុំ ដើម្បីត្រួតពិនិត្យឡើងវិញ និងប្រមូលយកលទ្ធផលនានា និងបង្ហាញលទ្ធផលទាំងនេះនៅក្នុងទម្រង់ងាយយល់ក្នុងកិច្ចប្រជុំរួមគ្នា)
- គាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដើម្បីធ្វើការសម្របសម្រួលនៅក្នុងកិច្ចប្រជុំរួមគ្នារវាងប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ អ្នកផ្ដល់សេវានានា (ដូចជា គ្រូបង្រៀន និងបុគ្គលិកសុខាភិបាល) និងមន្ត្រីថ្នាក់ស្រុក
- ធ្វើការជាមួយអ្នកពាក់ព័ន្ធនានាដើម្បីបញ្ចប់ផែនការសកម្មភាពរួម គាំទ្រឲ្យមានការអនុវត្តការត្រួតពិនិត្យស៊ីជម្រៅ និងដាក់ចូលទៅក្នុងដំណើរការអនុវត្តរួម (ដូចជា កិច្ចប្រឹងប្រែងដើម្បីបង្កើតទំនាក់ទំនងក្នុងការបំពេញប័ណ្ណដាក់ពិន្ទុសហគមន៍សម្រាប់សេវាសុខាភិបាល)
- ការរៀបចំ និងបង្ហាញពីលទ្ធផលពាក់ព័ន្ធនឹងការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងផ.ស.គ.រ នៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក និងសម្រាប់ប្រព័ន្ធ ព័ត៌មាននៅថ្នាក់ស្រុក
- ត្រួតពិនិត្យមើលលើការផ្ដល់កញ្ចប់ព័ត៌មាន(I4Cs) និងការអនុវត្តផែនការសកម្មភាពផ.ស.គ.រ

➢ **អង្គការសហគមន៍មូលដ្ឋាន និងអ្នកសម្របសម្រួលសហគមន៍៖** ផ.អ.គ.ស រំពឹងថានឹងមានការចូលរួមពីក្រុមប្រជាពលរដ្ឋ ក្រុមអ្នកប្រើប្រាស់ ឬអង្គការសហគន៍នៅថ្នាក់ឃុំ ភូមិ ដើម្បីប្រាស្រ័យទាក់ទងជា មួយស្ថាប័ន អង្គភាពរដ្ឋ និងផ្ដល់ឱកាសសម្រាប់ប្រជាពលរដ្ឋធ្វើការបញ្ចេញមតិ ដោយគ្មានការភ័យខ្លាច[35]។ សមាជិកសហគមន៍ចំនួន៤នាក់នឹងត្រូវជ្រើសរើស (ក្នុងនោះចំនួន២នាក់យ៉ាងតិចជាស្ត្រី) ពីឃុំនីមួយៗ ដើម្បីទទួលការបណ្ដុះបណ្ដាលជាអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដោយធ្វើឲ្យពួកគេអាចអភិវឌ្ឍចំណេះដឹង និងជំនាញចាំបាច់ក្នុងការធ្វើការសម្របសម្រួល និងបង្រៀនដល់ប្រជាពលរដ្ឋ ជួយប្រជាពលរដ្ឋឱ្យទទួលបាននូវព័ត៌មាន សម្របសម្រួលការអនុវត្តគណនេយ្យភាពសង្គម ព្រមទាំងបង្កើតឲ្យមានទំនាក់ទំនងការងារប្រកបដោយការស្ថាបនារវាងប្រជាពលរដ្ឋ និងអាជ្ញាធរ មូលដ្ឋាន ឬអ្នកផ្ដល់សេវានានា។ តួនាទីរបស់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដែលស្ម័គ្រចិត្តទាំងនេះមានសារៈសំខាន់ណាស់ក្នុងការពង្រឹងសមត្ថភាព នៅក្នុងសហគមន៍ ដើម្បីធ្វើឲ្យការអនុវត្តគណនេយ្យភាពសង្គមមាននិរន្តរភាព នៅពេលដែលកម្មវិធីនេះត្រូវបានបញ្ចប់ ឬនៅពេលដែលអង្គការដៃគូនៅមូលដ្ឋានធ្វើការកាត់បន្ថយការងាររបស់ពួកគេនៅតាមសហគមន៍។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ឬសិក្ខាកាមនឹងត្រូវបានជ្រើសរើសដោយផ្អែកលើការប្រកួតប្រជែង។ នៅចុងបញ្ចប់នៃកម្មវិធីគោលដៅ គឺត្រូវឲ្យមាន

[35] នៅមូលដ្ឋានមានក្រុមជាច្រើនត្រូវបានបង្កើតឡើង ប៉ុន្តែមិនមានដំណើរការដោយប្រសិទ្ធភាពទេ (ដូចជា អ្នកទ្រទ្រង់សុខភាពភូមិ ដែលត្រូវបានបង្កើតឡើងមិនមែនសម្រាប់គោលបំណងនេះនៅឡើយ ហើយក្រុមផ្សេងទៀតដែលត្រូវមានគណនេយ្យភាពនោះគឺសមាជិកនានារបស់ក្រុម។

អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ឲ្យបានច្រើន (ចំនួនប្រហែល៤០នាក់) ដែលមកពីសង្គមស៊ីវិល និងអង្គភាពរបស់រដ្ឋសម្រាប់ស្រុកគោលដៅនីមួយៗ ដែលអាចផ្តល់ការគាំទ្រជាប្រចាំក្នុងការអនុវត្តគណនេយ្យភាពសង្គម។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នឹងត្រូវ៖

- ចូលរួមដ៏សកម្មនៅក្នុងកម្មវិធីបណ្តុះបណ្តាលរយៈពេល១០ខែ និងចូលរួមកម្មវិធីសិក្សារៀនសូត្របទពិសោធន៍តាមរយៈការអនុវត្តបណ្តើររៀនបណ្តើរ
- គាំទ្រការពង្រឹងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋានជាដៃគូ ដោយផ្តោតលើការពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការចងក្រងសមាជិកសហគមន៍ កំណត់តម្រូវការ និងអាទិភាព និងគាំទ្រដល់ដំណើរការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ និងការងារគណនេយ្យភាពសង្គម
- អនុវត្តសកម្មភាពការលើកកម្ពស់ការយល់ដឹងនៅតាមភូមិ ដើម្បីឲ្យប្រជាពលរដ្ឋមានចំណាប់អារម្មណ៍នៅក្នុងការងារគណនេយ្យភាពសង្គម
- រៀបចំ និងសម្របសម្រួលឲ្យមានព្រឹត្តិការណ៍ "ព័ត៌មាន ការអប់រំ ការប្រាស្រ័យទាក់ទង" និងការយល់ដឹងពីថវិកា
- រៀបចំ និងសម្របសម្រួលការបំពេញប័ណ្ណដាក់ពិន្ទុតាមវិស័យនានា
- ចូលរួមចំណែកដល់ការអនុវត្តសកម្មភាពត្រួតពិនិត្យតាមដាន ដោយប្រជាពលរដ្ឋឲ្យកាន់តែស៊ីជម្រៅ (មាន៣សកម្មភាពក្នុងស្រុកនីមួយៗ)
- រៀបចំ និងសម្របសម្រួលកិច្ចប្រជុំរួមគ្នា
- គាំទ្រដល់ការអនុវត្ត និងត្រួតពិនិត្យលើផែនការសកម្មភាពរួម

នៅចុងបញ្ចប់នៃការបណ្តុះបណ្តាល សិក្ខាកាមទាំងអស់ដែលបានបញ្ចប់វគ្គសិក្សា ដោយជោគជ័យ នឹងទទួលបានលិខិតបញ្ជាក់ការសិក្សា ដែលបញ្ជាក់ថាពួកគេទទួលបានការបណ្តុះបណ្តាលជាអ្នកសម្របសម្រួលគណនេយ្យភាពសង្គម។ អ្នកដែលបញ្ចប់វគ្គសិក្សាប្រកបដោយជោគជ័យត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងក្រុមអនុវត្ត និងទទួលបានការគាំទ្រនៅក្នុងការផ្សព្វផ្សាយពីជំនាញរបស់ពួកគេ។ ថ្វីត្បិត អ្នកសម្របសម្រួលគណនេយ្យភាពសង្គមមិនបានទទួលប្រាក់កម្រៃក្នុងការចូលរួមក្នុងការអនុវត្តកម្មវិធី តែជំនាញដែលពួកគេបានរៀនសូត្រមុខងារដែលទទួលនៅក្នុងសហគមន៍ និងការដែលគេទទួលបានលិខិតបញ្ជាក់ការសិក្សាត្រូវបានចាត់ទុកថាជាការលើកទឹកចិត្តដ៏សំខាន់។

ដូចបានរៀបរាប់នៅក្នុងសមាសភាគទី៣និងទី៤ ការជ្រើសរើសស្ថាប័នដៃគូដែលមានជំនាញ២ ត្រូវបានរំពឹងថានឹងចូលរួមក្នុងដំណើរការគាំទ្រការបណ្តុះបណ្តាល និងការសិក្សារៀនសូត្រ៖

- **ដៃគូផ្តល់ការបណ្តុះបណ្តាលដែលមានជំនាញ៖** តាមរយៈការប្រើប្រាស់វិធីសាស្ត្របណ្តុះបណ្តាលគ្រូបង្គោល(ToT) អង្គការដៃគូដែលផ្តល់ការបណ្តុះបណ្តាលលើការអនុវត្ត ផ.អ.គ.ស នឹងត្រូវជ្រើសរើស ហើយដៃគូនោះត្រូវរៀបចំឲ្យមានកម្មវិធីសិក្សា សម្ភារៈសម្រាប់ការបណ្តុះបណ្តាល និងរៀបចំឲ្យមានការបណ្តុះបណ្តាលពាក់ព័ន្ធនឹងផ្នែកផ្គត់ផ្គង់ និងតម្រូវការ។ សម្រាប់ផ្នែកតម្រូវការ ការបណ្តុះបណ្តាលរួមមាន៖ ការបណ្តុះបណ្តាលសម្រាប់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (ការបណ្តុះបណ្តាល សម្រាប់ជនបង្គោលរបស់អង្គការនៅមូលដ្ឋាន អ្នកផ្តល់យោបល់) ដូចដែលបានរៀបរាប់នៅក្នុងសមាសភាគ៣ខ។ សម្រាប់ផ្នែកផ្គត់ផ្គង់ ការបណ្តុះបណ្តាលរួមមាន ការបណ្តុះបណ្តាលសម្រាប់មន្ត្រីរបស់រដ្ឋនៅមូលដ្ឋាន

និងផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកក្រុមប្រឹក្សាស្រុក និងមន្ត្រីផ្សេងៗ ព្រមទាំង ការិយាល័យសុខាភិបាល និងការិយាល័យអប់រំស្រុក។

- **ដៃគូជំនាញឯករាជ្យផ្នែកប្រមូលមេរៀន បទពិសោធន៍ និងការត្រួតពិនិត្យតាមដាន៖** ដៃគូឯករាជ្យនេះនឹងត្រូវបានជ្រើសរើស ដើម្បីគ្រប់គ្រងចាត់ចែងលើការរៀបចំវេទិកា សម្រាប់ការប្រមូលមេរៀនបទពិសោធន៍ និងចូលរួមអនុវត្តសមាសភាគប្រមូលមេរៀន បទពិសោធន៍ និងការត្រួតពិនិត្យតាមដាន ។ ដោយផ្តោតការយកចិត្តទុកដាក់លើការផ្តល់យោបល់ត្រឡប់ជាប្រចាំ និងរៀនសូត្រពីបទពិសោធន៍ និងការកែសម្រួល កាតព្វកិច្ចដៃគូជំនាញនេះរួមមាន៖ ប្រមូល និងចងក្រងមេរៀនបទពិសោធន៍ពីមូលដ្ឋាន ព្រមទាំងបញ្ចូលបទពិសោធន៍ដែលបានរៀនសូត្រទាំងនេះ ទៅក្នុងដំណើរការនៃការកែសម្រួលលើគោលនយោបាយ និងការអនុវត្ត។ អង្គការដៃគូនៅថ្នាក់ជាតិ នឹងទទួលបានការគាំទ្រនូវវិធីសាស្ត្រនៃការប្រមូលមេរៀន និងបទពិសោធន៍ និងធ្វើការជាមួយអង្គការដៃគូនៅមូលដ្ឋានដើម្បីធ្វើការចងក្រង និងឆ្លុះបញ្ចាំងពីការងារនេះថា បានដំណើរការដូចម្តេចខ្លះ ដូចជាភាពជោគជ័យ បរាជ័យ ភាពរាំងស្ទះ និងឱកាសនានា ការផ្តួចផ្តើមនានាឲ្យមានវេទិកា រួម សម្រាប់ធ្វើការឆ្លុះបញ្ចាំង និងផ្តល់យោបល់ត្រឡប់លើដំណើរការ (ការធ្វើសវនកម្មលើដំណើរ) និង លទ្ធផលនានា ដែលបង្កើតឲ្យមានការត្រួតពិនិត្យមើលឡើងវិញ និងការវាយតម្លៃ ការផ្សព្វផ្សាយ ព័ត៌មាន ឧបករណ៍នានា ករណីសិក្សា និងលើកកម្ពស់ការយល់ដឹងពាក់ព័ន្ធ នឹងគណនេយ្យភាព សង្គមក្នុងចំណោមស្ថាប័ន អង្គភាពរបស់រដ្ឋ និងមិនមែនរដ្ឋនៅប្រទេសកម្ពុជាដូចបានរៀបរាប់នៅក្នុងសមាសភាគទី៤ក។

**ការរៀបចំយន្តការសម្របសម្រួល៖** ផ.អ.គ.ស មានការពាក់ព័ន្ធទាំងសកម្មភាពផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ ដែលត្រូវមានការសម្របសម្រួល និងតម្រូវឲ្យមានការរៀបចំ យន្តការអភិបាលកិច្ចកម្រិតខ្ពស់សម្រាប់ការសម្រេចចិត្តជាយុទ្ធសាស្ត្រ ការត្រួតពិនិត្យមើលពីលើ និងការសម្របសម្រួលនានា។ ក្រុមសម្របសម្រួលថ្នាក់ជាតិរួមមាន មន្ត្រីជាន់ខ្ពស់បីរូបមកពីស្ថាប័ន អង្គភាពរបស់រដ្ឋាភិបាល (គ.ជ.អ.ប ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា) តំណាងអង្គការសង្គមស៊ីវិលជានាយកប្រតិបត្តិបីរូប និងដៃគូអភិវឌ្ឍ ដែលផ្តល់ហិរញ្ញប្បទាន (ក្នុងនាម ជាអ្នកសង្កេតការណ៍ ឬជាសមាជិកសកម្ម)។ អ្នកសម្របសម្រួលផ្នែកតម្រូវការ នឹងដើរតួជាលេខាធិការដ្ឋានសម្រាប់ក្រុមសម្របសម្រួលថ្នាក់ជាតិ (រៀបចំកំណត់ហេតុកិច្ចប្រជុំធ្វើបទបង្ហាញ និងផ្តល់សម្ភារៈនានាតាមការស្នើសុំ)។ អង្គការជាដៃគូនានា (រួមមានដៃគូផ្តល់ការបណ្តុះបណ្តាល ដៃគូប្រមូល មេរៀនបទពិសោធន៍ និងដៃគូអនុវត្ត) ជាតំណាងនៅក្នុងក្រុមការងារថ្នាក់ខ្ពស់ នឹងត្រូវស្នើឲ្យចូលរួមរួមក្នុងកិច្ចប្រជុំរួមសម្រាប់ធ្វើការរាយការណ៍ និងក្នុងគោលបំណងចែករំលែកព័ត៌មាន។ គ.ជ.អ.ប (រួមជាមួយនឹងអង្គភាពសម្របសម្រួលសម្រាប់ផ្នែកផ្គត់ផ្គង់) នឹងធ្វើការគ្រប់គ្រងចាត់ចែងលើសកម្មភាពដូចតទៅ៖ រៀបចំកិច្ចប្រជុំសម្របសម្រួលប្រចាំត្រីមាសជាទៀងទាត់ រៀបចំឲ្យមានការត្រួតពិនិត្យពាក់កណ្តាលកម្មវិធី ការវាយតម្លៃបញ្ចប់កម្មវិធី និងធ្វើសវនកម្មខាងក្រៅប្រចាំឆ្នាំ។

# ផ្នែកទី៤
# ការចាប់ផ្តើមអនុវត្តគម្រោង

## ៤.១ ការចាប់ផ្តើម

ដំណាក់កាលនៃការចាប់ផ្តើមនឹងធ្វើឡើងក្នុងចន្លោះខែកក្កដា-ធ្នូ ឆ្នាំ២០១៣ ដោយប្រើប្រាស់មូលនិធិនៃគម្រោងអភិបាលកិច្ចល្អ (សមាសភាគស្ថាប័នមិនមែនរដ្ឋ និងការិយាល័យច្រកចេញចូលតែមួយ) ដោយមានជំនួយបច្ចេកទេសពីធនាគារពិភពលោក។ ក្នុងអំឡុងពេលនេះ៖

- ឧបករណ៍សំខាន់ៗ និងដំណើរការនានានឹងត្រូវរៀបចំឡើង
- ទម្រង់បែបបទ និងឧបករណ៍សំខាន់ៗមួយចំនួន នឹងដាក់ឲ្យសាកល្បងនៅក្នុងស្រុកមួយចំនួន ដើម្បីជាការត្រួតពិនិត្យផ្ទៀងផ្ទាត់ (ទម្រង់បែបបទនិងឧបករណ៍ទាំងនោះបានបង្កើតឡើងដោយផ្អែកលើឧបករណ៍ដែលធ្លាប់បានប្រើប្រាស់ដោយអង្គកាដៃគូនៅមូលដ្ឋានពីមុនមក)
- វិធីសាស្ត្រការបណ្តុះបណ្តាល និងកសាងសមត្ថភាពនឹងត្រូវបង្កើតឡើង
- ប្រភពមូលនិធិ នឹងត្រូវបានកំណត់។

ក្រុមការងាររៀបចំតាក់តែងឯកសារនេះ នឹងធ្វើការយ៉ាងជិតស្និទ្ធិជាមួយសង្គមស៊ីវិល និងរដ្ឋាភិបាល ក្នុងការរៀបចំចងក្រងឯកសារឲ្យទៅជាកម្មវិធីដើម្បីអនុវត្ត។ នៅក្នុងការបង្កើតឧបករណ៍ និងរៀបចំដំណើរការនានាផែនការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គមនឹងពង្រឹងឧបករណ៍ និងបទពិសោធន៍ដែលមានស្រាប់ ក៏ដូចជាសិក្សារៀនសូត្រពីការអនុវត្តកន្លងមកដើម្បីចៀសវាងការធ្វើសកម្មភាពដដែលៗ។ ទោះបីយ៉ាងណាក៏ដោយ ដំណើរការនេះត្រូវធ្វើការពិភាក្សា និងសាកល្បងលើមធ្យោបាយ ឧបករណ៍សំខាន់ៗ និងឯកសារនានាសម្រាប់ធ្វើការណែនាំដូចដែលបានលើកឡើងនៅក្នុងសមាសភាគទី១ ទី២ និងទី៣ខាងលើ។ ឧទាហរណ៍ ការអនុវត្តនានាដើម្បីធ្វើឲ្យប្រសើរឡើងនូវការយល់ដឹងពីព័ត៌មាន និងការងារថវិកា វិធីសាស្ត្របំពេញប័ណ្ណដាក់ពិន្ទុលើការផ្តល់សេវារបស់វិស័យនានា ព្រមទាំងផែនការសកម្មភាពគណនេយ្យភាពរួមគ្នា។ វិធីសាស្ត្រទាំងនេះនឹងសាកល្បងនូវការរៀបចំយន្តការសម្របសម្រួល (យកបទពិសោធន៍ពីលក្ខណៈផ្សេងៗគ្នារបស់ស្ថាប័ននីមួយៗ)។

សម្រាប់ផ្នែកផ្គត់ផ្គង់ ការប្រើប្រាស់មូលនិធិរបស់គម្រោងអភិបាលកិច្ចល្អ គ.ជ.អ.ប នឹងរៀបចំព្រមគ្នានូវសៀវភៅណែនាំ គោលការណ៍ និងឧបករណ៍នានាសម្រាប់ដំណើរការ។ ការខិតខំប្រឹងប្រែងបង្កើតឲ្យមានការណែនាំតម្រង់ទិសពាក់ព័ន្ធនឹងផ្នែកផ្គត់ផ្គង់ រួមជាមួយនឹងការពង្រឹងសមត្ថភាពនានានៅមូលដ្ឋានគឺតម្រូវការចាំបាច់ក្នុងដំណើរការនេះ ដែលជួយដល់សកម្មភាពបណ្តុះបណ្តាលសម្រាប់ផ្នែកតម្រូវការដើម្បីអនុវត្តនៅដើមឆ្នាំ ២០១៤។

## ៤.២ ក្របខ័ណ្ឌពេលវេលាសម្រាប់អនុវត្ត

ដោយទទួលស្គាល់ថាការរៀបចំកិច្ចការនេះត្រូវការពេលវេលាច្រើន ដើម្បីបញ្ចប់នូវសៀវភៅណែនាំយន្តការហិរញ្ញប្បទាន និងការសម្របសម្រួលនានា ហេតុនេះផែនការអនុវត្តគណនេយ្យភាពសង្គមនឹងអាចអនុវត្តបាននៅក្នុងដំណាក់កាលបីសំខាន់ៗដែលត្រូវពង្រីកទៅដល់ស្រុកចំនួន១២០ នៅឆ្នាំទី៣៖

- ២០១៤៖ ចំនួន ២០- ៣០ស្រុក
- ២០១៥៖ ចំនួន ៥០ស្រុកបន្ថែមទៀត (២០ (ឆ្នាំទី១) + ៥០ (ឆ្នាំទី២))
- ២០១៦៖ ចំនួន ៥០ស្រុកបន្ថែមទៀត (២០ (ឆ្នាំទី១) + ៥០ (ឆ្នាំទី២) + 50)
- ២០១៧៖ ផែនការអនុវត្តសម្រាប់សង្កាត់ ខ័ណ្ឌ ក្រុង នឹងត្រូវចាប់ផ្តើមឡើង
- តំបន់គ្របដណ្តប់ គឺអាស្រ័យលើធនធានដែលមានសម្រាប់ការអនុវត្តរបស់សង្គមស៊ីវិល។ សូមមើលផ្នែកទី៥ (កថាខ័ណ្ឌទី៨) "ការសម្រេចចិត្តចូលរួម" ។

# ផ្នែកទី ៥
# សង្ខេបការផ្តល់ហិរញ្ញវត្ថុ និងថវិកា

## ៥.១. ការចំណាយ

ក្នុងរយៈពេលពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦ គម្រោងចំណាយក្នុងការអនុវត្ត ផ.អ.គ.ស ក្នុងរយៈពេល ៣ឆ្នាំមានចំនួន១២.៨លានដុល្លារអាមេរិក ក្នុងនោះចំនួន៨.២លាន ដុល្លារសម្រាប់សកម្មភាពផ្នែកតម្រូវការ និង ២.៧លានដុល្លារសម្រាប់សកម្មភាពផ្នែកផ្គត់ផ្គង់ ហើយថវិកាចំនួន១.៨លានដុល្លារទៀត សម្រាប់ផ្តល់ឲ្យសកម្មភាព ទាំងពីរផ្នែកនេះ ប៉ុន្តែប្រសិនថវិកានេះត្រូវបានផ្តល់ដល់ស្ថាប័ន ឬអ្នកជំនាញការឯករាជ្យគឺជាការប្រសើរ។

ផ្អែកលើការវាស់វែង ដែលបានកំណត់ក្នុងសមាសភាគទី ១និងទី២ ដែលមានគ្រប់សកម្មភាពនៅមូលដ្ឋាន ទាំងអស់ដូចជាការពង្រឹងសមត្ថភាពនៅថ្នាក់ឃុំ ភូមិ និងសហគមន៍ ការចំណាយប្រចាំឆ្នាំក្នុងការអនុវត្តក្នុង មួយស្រុក គឺជាមធ្យមប្រហែល៤០.០០០ដុល្លារក្នុងរយៈពេល៣ឆ្នាំ សម្រាប់ទាំងការចំណាយផ្នែកផ្គត់ផ្គង់ និង ផ្នែកតម្រូវការនៅថ្នាក់មូលដ្ឋាន (បើទោះបីការចំណាយមានការធ្លាក់ចុះបណ្តើរៗនៅឆ្នាំទី២និងទី៣ក៏ដោយ)។

**តារាង៥.១. គម្រោងចំណាយតាមសមាសភាគ (សម្រាប់រយៈពេល៣ ឆ្នាំ ២០១៤-២០១៦)**

| សមាសភាគ | 2013 | 2014 | 2015 | 2016 | សរុប | % |
|---|---|---|---|---|---|---|
| **សមាសភាគទី១** ភាពងាយទទួលបានព័ត៌មានស្តីពីស្តង់ដា ថវិកា និងការបំពេញមុខងារ | $157.000 | $265.000 | $966.000 | $1.365.000 | $2.753.000 | 22% |
| **សមាសភាគទី២** ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ | $116.000 | $545.000 | $1.517.000 | $2.389.000 | $4.567.000 | 36% |
| **សមាសភាគទី៣** ការសម្របសម្រួល និងការពង្រឹងសមត្ថភាព | $0 | $271.000 | $856.000 | $1.229.000 | $2.355.000 | 18% |
| **សមាសភាគទី៤** ការប្រមូលមេរៀនបទពិសោធន៍និងការត្រួតពិនិត្យតាមដាន | $0 | $386.000 | $265.000 | $309.000 | $960.000 | 8% |
| ការសម្របសម្រួល គ្រប់គ្រង | $36.000 | $172.000 | $757.000 | $1.141.000 | $2.106.000 | 17% |
| **សរុប** | **$309.000** | **$1.639.000** | **$4.361.000** | **$6.433.000** | **$12.742.000** | **100%** |
| % | **2%** | **13%** | **34%** | **50%** | **100%** | |

(ថវិកាគិតតាមឆ្នាំនីមួយៗ គឺឆ្នាំ២០១៤ សម្រាប់២០ស្រុកថ្មី ឆ្នាំ២០១៥សម្រាប់៥០ស្រុកថ្មី និងឆ្នាំ២០១៦ សម្រាប់ចំនួន៥០ស្រុកថ្មី) តាមផែនការគ្រោង ស្រុកដែលនឹងអនុវត្តគណនេយ្យភាពសង្គមនឹងមានចំនួន១២០ ស្រុកគិតត្រឹមដំណាច់ឆ្នាំ២០១៧។)

តារាង ៥.២  ការចំណាយប្រចាំឆ្នាំ ២០១៣-២០១៦ សម្រាប់សកម្មភាពរបស់រដ្ឋាភិបាល និង អង្គការសង្គមស៊ីវិល

| | សរុប | |
|---|---|---|
| ថវិកាសម្រាប់សកម្មភាពអង្គការសង្គមស៊ីវិល (ផ្នែកតម្រូវការ) | $8.205.000 | 64% |
| ថវិកាសម្រាប់សកម្មភាពរដ្ឋាភិបាល(ផ្នែកផ្គត់ផ្គង់) (រួមទាំងសិក្សារៀនសូត្រនិងការបណ្តុះបណ្តាល | $3.538.000 | 36% |
| សរុប | $12.742.000 | |

ថវិកាគិតតាមឆ្នាំនីមួយៗ គឺឆ្នាំ២០១៤ សម្រាប់២០ស្រុកថ្មី ឆ្នាំ២០១៥សម្រាប់៥០ស្រុកថ្មី និងឆ្នាំ២០១៦ សម្រាប់ចំនួន៥០ស្រុកថ្មី) តាមផែនការគ្រោង ស្រុកដែលនឹងអនុវត្តគណនេយ្យភាពសង្គមនឹងមានចំនួន១២០ ស្រុកគិតត្រឹមដំណាច់ឆ្នាំ២០១៧។

តាម ផ.អ.គ.ស ទាំងរដ្ឋាភិបាល និងសង្គមស៊ីវិលត្រូវមានការប្តេជ្ញាចិត្តស្មើគ្នាក្នុងការអនុវត្ត ផ.អ.គ.ស ដែលមានន័យថា ភាគីទាំងពីរក៏ត្រូវការចំណាយដែលមានចំនួនស្មើគ្នាដែរ។ តែតាមការអនុវត្តជាក់ស្តែងការងារជាច្រើនរបស់រដ្ឋាភិបាលពុំមានការផ្តល់ថវិកាទេពីព្រោះការងារទាំងនេះកំពុងបានអនុវត្តដោយមន្ត្រីរដ្ឋាភិបាលរួចហើយក្នុងតួនាទីរបស់ខ្លួនដែលត្រូវបំពេញភារកិច្ចទាំងនោះ។

## ៥.២. ការផ្តល់ហិរញ្ញប្បទាន

**គោលការណ៍៖** ការផ្តល់ហិរញ្ញប្បទានសម្រាប់អនុវត្តផ.អ.គ.សមានភាពស៊ាំញ៉ាំ ដោយសារតែការផ្តល់ថវិកាត្រូវធ្វើឱ្យបានសមស្របចំពោះរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីអាចអនុវត្តសកម្មភាពទាំងនោះបាន និងត្រូវមានការប្តេជ្ញាចិត្តពីភាគីទាំង២។ គោលការណ៍ផ្តល់ហិរញ្ញវត្ថុខាងក្រោមនេះ ត្រូវអនុវត្តទៅតាមលទ្ធភាព ៖

- ថវិកាសម្រាប់រដ្ឋាភិបាលគួរត្រូវបញ្ចូលទៅក្នុងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់គ.ជ.អ.ប រីឯថវិកាសម្រាប់អង្គការសង្គមស៊ីវិលគួរដាក់ដោយឡែកពី ថវិកាសម្រាប់រដ្ឋាភិបាលហើយត្រូវគ្រប់គ្រងចាត់ចែងនិងប្រើប្រាស់ដោយអង្គការសង្គមស៊ីវិល។ (អ្នកដែលទទួលបានថវិកាសម្រាប់អនុវត្តសកម្មភាព ត្រូវគោរពតាមគោលការណ៍ដែលធនាគារពិភពលោកតម្រូវ)។
- ថវិកាសម្រាប់ផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់គួររក្សាឲ្យមានតុល្យភាពតាមលទ្ធភាពដែលធ្វើបានដើម្បីបង្ហាញនូវការប្តេជ្ញាចិត្ត និងភាពជាម្ចាស់ (សូមពិនិត្យនូវលក្ខណៈសម្បត្តិដូចបង្ហាញខាងលើ)
- ការផ្តល់ថវិកាសម្រាប់សមាសភាគទី៤ "ការសិក្សាស្វែងយល់ និងការត្រួតពិនិត្យតាមដាន" គួរកំណត់ជាក់លាក់យ៉ាងហោចណាស់សម្រាប់រយៈពេល២ឆ្នាំ
- ការផ្តល់ថវិកាពីប្រភពផ្សេងៗ (រួមមានទាំងការផ្តល់ថវិកាតាមវិស័យ) នឹងត្រូវបានសម្របសម្រួល និងលើកទឹកចិត្តបន្ថែមទៀតសម្រាប់ការចំណាយតាមផែនការអនុវត្ត
- ក្របខ័ណ្ឌសម្រាប់ការផ្តល់ហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពសម្រាប់សកម្មភាពនានា គួរត្រូវបានបង្កើតឡើងតាមរយៈការអនុវត្តផ្ទាល់។

ទំហំការងារត្រូវផ្សារភ្ជាប់នឹងការផ្តល់ហិរញ្ញវត្ថុ៖ ផ.អ.គ.ស បង្កើតនូវអភិក្រមប្រកបដោយនិរន្តរភាព និងកំណត់គោលដៅដែលអាចសម្រេចបានសម្រាប់កញ្ចប់សកម្មភាពចំនួនបីរួមមាន ព័ត៌មាននានា ព័ត៌មានថវិកា និងការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ (រួមទាំងការរៀបចំផែនការសកម្មភាពរួមគ្នា)។ ផ.អ.គ.ស បំពេញបន្ថែមការខ្វះចន្លោះនៃដំណើរការនានាដែលមានស្រាប់តាមរយៈការអនុវត្តនូវកញ្ចប់សកម្មភាពរួមមួយចំនួន។ ដូច្នេះ ខណៈដែលទំហំការងារកាន់តែធំ នោះតម្រូវការថវិកានឹងកាន់តែច្រើន។ ចំនួនស្រុកដែលចូលរួមអនុវត្តនឹងត្រូវបានកំណត់ផ្អែកលើមូលនិធិ ដែលមានសម្រាប់រយៈពេល៣ឆ្នាំដំបូង។ ទិដ្ឋភាពសំខាន់មួយនៃ ផ.អ.គ.ស ដែលជាកម្មវិធីអនុវត្តទូទាំងប្រទេស គឺការណែនាំនូវរបៀបអនុវត្តប្រកបដោយនិរន្តរភាព ដែលអាចអនុវត្តបាននៅគ្រប់ស្រុកទាំងអស់នៅទូទាំងប្រទេស ។

**ការផ្តល់ហិរញ្ញវត្ថុ ក្នុងរយៈពេលចាប់ផ្តើមដំបូងនៃផែនការអនុវត្តក្របខ័ណ្ឌការងារគណនេយ្យភាពសង្គម៖** ក្នុងរយៈពេលចាប់ផ្តើមដំបូង ការងារនេះត្រូវបានផ្តល់ថវិកាគាំទ្រដោយគម្រោងគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន សមាសភាគទី១D (គម្រោងការិយាល័យច្រកចេញចូលតែមួយដែលចាត់ចែងដោយគ.ជ.អ.ប រួមទាំងសមាសភាគសម្រាប់បង្កើនការយល់ដឹងសម្រាប់ប្រជាពលរដ្ឋ) និងសមាសភាគទី២ (សមាសភាគសម្រាប់តួអង្គមិនមែនរដ្ឋ) ។ ថវិកាប្រហែល ៤៣៥.០០០ដុល្លារ ត្រូវបានវិភាជន៍សម្រាប់សកម្មភាពដូចខាងក្រោម៖

- សម្រាប់ការរៀបចំកញ្ចប់ព័ត៌មាន (ឧបករណ៍ និងទម្រង់ព័ត៌មានរបស់ផ្នែកផ្គត់ផ្គង់សម្រាប់ព័ត៌មាន និងថវិកា ព្រមទាំងការណែនាំចាំបាច់នានាសម្រាប់សកម្មភាពផ្សេងៗនៅក្នុងស្រុកគោលដៅក្នុង ឆ្នាំ២០១៤ ចំនួន១៣៥.០០០ដុល្លារ (គ្រប់គ្រងចាត់ចែងដោយ គ.ជ.អ.ប)
- សម្រាប់សកម្មភាពផ្នែកតម្រូវការ (រួមទាំងការរៀបចំយន្តការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ ហើយសកម្មភាពផ្នែកតម្រូវការដែលពាក់ព័ន្ធជាមួយព័ត៌មាននិងថវិកា) ចំនួន២៥០.០០០ដុល្លារ (ចាត់ចែង ដោយមូលនិធិអាស៊ី)
- សម្រាប់ការសិក្សានានា និងជំនួយបច្ចេកទេសពីធនាគារពិភពលោកចំនួន១០០.០០០ដុល្លារ (ចាត់ចែងដោយធនាគារពិភពលោក)។

**ការផ្តល់ហិរញ្ញវត្ថុសម្រាប់សកម្មភាពនៃផែនការអនុវត្ត គណនេយ្យភាពសង្គមដែល អនុវត្តដោយរដ្ឋាភិបាល (នៅក្នុងសមាសភាគទី ១ និងទី២)។** សកម្មភាពផ្នែកផ្គត់ផ្គង់ ត្រូវបញ្ចូលទៅក្នុងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំនៃផអ៣ ព្រមទាំងទៅក្នុងផែនការអនុវត្តនានា។ សកម្មភាពនានានៃផ.អ.គ.ស ដែលមាននៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃផអ៣ឆ្នាំ២០១៤ របស់គ.ជ.អ.ប នឹងរៀបចំដោយអ្នកជំនាញការផ្នែកផ្គត់ផ្គង់ ហើយត្រូវអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ សាលារៀន និងមណ្ឌលសុខភាព។ ធនាគារពិភពលោក ធ្លាប់បានពិភាក្សាជាមួយ គ.ជ.អ.ប និងបានកំនត់ថា សម្រាប់គម្រោងអភិវឌ្ឍន៍និងអភិបាលកិច្ចមូលដ្ឋាន(LGDP) នាពេលខាងមុខ នឹងបញ្ចូលសមាសភាគតម្លាភាព និងគណនេយ្យភាពដើម្បីគាំទ្រសកម្មភាពចាំបាច់នានារបស់រដ្ឋាភិបាល។

**ការផ្តល់ហិរញ្ញវត្ថុសម្រាប់សកម្មភាពនៃផែនការអនុវត្តក្របខ័ណ្ឌការងារគណនេយ្យភាពសង្គម ដែលអនុវត្តដោយអង្គការសង្គមស៊ីវិល (នៅក្នុងសមាសភាគ ទី១ ទី២ និងទី៣ក)។** ការផ្តល់ហិរញ្ញវត្ថុសម្រាប់ សកម្មភាពអនុវត្តដោយអង្គការសង្គមស៊ីវិលមានលក្ខណៈស្មុគស្មាញ ហើយទាមទារនូវការសម្របសម្រួល ជាមួយដៃគូមួយចំនួន។

យុទ្ធសាស្ត្រផ្តល់ហិរញ្ញវត្ថុសម្រាប់ការអនុវត្តរបស់ផ្នែកតម្រូវការរបស់ ផ.អ.គ.ស បច្ចុប្បន្នកំពុងតែរៀបចំព្រមទាំងផ្តល់មូលនិធិនៅដំណាច់ឆ្នាំ២០១៣។ យុទ្ធសាស្ត្រសំខាន់២រួមមាន៖

- **ជំរុញការចូលរួម៖** អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានលើកទឹកចិត្តឲ្យចូលរួមគាំទ្រអនុវត្តផ.អ.គ.ស ។ អង្គការមិនមែនរដ្ឋាភិបាលនានានឹងប្តេជ្ញាចិត្តក្នុងការអនុវត្តនូវកញ្ចប់សកម្មភាពសំខាន់ៗ នៅក្នុងស្រុកដែលបានកំនត់រួចមកហើយ ហើយដែលភាគច្រើននៃអង្គការទាំងនោះមានទំនាក់ទំនង និងសកម្មភាពស្រាប់នៅទីនោះរួចហើយ។ គ.ជ.អ.ប ក៏ប្តេជ្ញាចិត្តអនុវត្តលើសកម្មភាពផ្នែកផ្គត់ផ្គង់នៅក្នុងស្រុកដែលបានកំណត់នោះផងដែរ។ ការប្តេជ្ញាចិត្តទាំងសងខាងនេះ នឹងធានាថាសកម្មភាពផ្នែកផ្គត់ផ្គង់ត្រូវបានគ្រោងនិងអនុវត្តនៅក្នុងស្រុកទាំងនោះ ដែលក្នុងស្រុកទាំងនោះបានទទួលមូលនិធិសម្រាប់សកម្មភាពផ្នែកតម្រូវការ។ ការអញ្ជើញឲ្យមានការចូលរួមនឹងធ្វើឡើងនៅក្នុងឆ្នាំ២០១៤ ដើម្បីធ្វើការសម្រេចកំនត់ចំនួនស្រុកដែលត្រូវអនុវត្ត ផ.អ.គ.ស។ ការរៀបចំឲ្យមានការចូលរួម ត្រូវរៀបចំក្នុងអំឡុងពេលចាប់ផ្តើម (ក្នុងនោះ មានអនុសារណៈយោគយល់គ្នា ការកំណត់ពេលវេលាជាដើម នឹងត្រូវបានរៀបចំក្នុងអំឡុងពេលចាប់ផ្តើម)។
- **ការបង្កើនថវិកា៖** ផ.អ.គ.សមិនមានការផ្តល់ថវិកា តាមរយៈគម្រោងដាច់ដោយឡែក ដូចដែលធ្លាប់បានអនុវត្តនៅក្នុងប្រទេសកម្ពុជាកន្លងមកនោះទេ។ ផ្ទុយទៅវិញ អង្គការមិនមែនរដ្ឋាភិបាលដែលកំពុងអនុវត្តសកម្មភាពរបស់ខ្លួននៅក្នុងឃុំ ស្រុកទាំងនោះ ត្រូវបន្ថែមថវិកាលើថវិការបស់ខ្លួន ដែលមានស្រាប់ដើម្បីអនុវត្តកញ្ចប់សកម្មភាពសំខាន់ៗ។ ការបន្ថែមថវិកានេះ អាចមានចំនួនពី ៨.០០០-១២.០០០ដុល្លារសម្រាប់១ស្រុកក្នុង១ឆ្នាំ (ប្រហែល១.០០០ដុល្លាសម្រាប់១ឃុំក្នុង១ឆ្នាំ)។ របៀបអនុវត្តបែបនេះ គឺដើម្បីធានាប្រសិទ្ធភាព និងនិរន្តរភាព ព្រមទាំងដើម្បីឲ្យអង្គការមិនមែនរដ្ឋាភិបាល ទាំងនោះបញ្ចូលការងារគណនេយ្យភាពសង្គមទៅក្នុងកម្មវិធី ដែលមានស្រាប់នៅតាមតំបន់ដែលអង្គការ ទាំងនោះមានទំនាក់ទំនង និងសកម្មភាពការងារនៅទីនោះ។ ការអនុវត្តបែបនេះ អាចជួយជំរុញឲ្យមានមធ្យោបាយថ្មី ក្នុងការអនុវត្តកិច្ចការអ្វីមួយ ជៀសវាងធ្វើគម្រោងតូចៗ និងមានលក្ខណៈដាច់ដោយឡែក។
- **ការផ្តល់ហិរញ្ញវត្ថុដោយដៃគូអភិវឌ្ឍន៍៖** ដៃគូអភិវឌ្ឍន៍ណាក៏ដោយ អាចចូលរួមក្នុងការផ្តល់មូលនិធិសម្រាប់ការអនុវត្តផ.អ.គ.ស។ ដៃគូអភិវឌ្ឍន៍នីមួយៗដែលមានតម្រូវការផ្សេងៗគ្នាសម្រាប់ការផ្តល់មូលនិធិគាំទ្រដល់អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល នឹងត្រូវបានលើកទឹកចិត្តដើម្បីពិភាក្សាជាមួយដៃគូផ្តល់ជំនួយនានា (បន្ទាប់ពីពិភាក្សាអាចសម្រេចចូលរួម)។ ការគាំទ្ររបស់ដៃគូអភិវឌ្ឍមានដូចខាងក្រោម៖
    - **ធនាគារពិភពលោកនឹងចាត់ចែងមូលនិធិ**Trust Fund៖ ក្រុមធនាគារពិភពលោកកំពុងរៀបចំសំណើផ្តល់ហិរញ្ញវត្ថុ **Trust Fund** សម្រាប់សកម្មភាពអង្គការសង្គមស៊ីវិល។ នេះគឺជាដំណើរការដែលត្រូវការពេលវេលាច្រើន និងទាមទារការអនុម័តជាច្រើនដំណាក់។ មូលនិធិនេះនឹងត្រូវទទួលនិងអនុវត្តដោយដៃគូ ដែលមានប្រព័ន្ធត្រួតពិនិត្យសុច្ចរិតភាពតាមលក្ខខ័ណ្ឌតម្រូវ។ ធនាគារពិភពលោក នឹងកំណត់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមិនលើសពី២ ធ្វើជាអ្នកគ្រប់គ្រងចាត់ចែងក្រុមអង្គការ មិនមែនរដ្ឋាភិបាលក្នុងស្រុក ហើយនឹងលើកទឹកចិត្តអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ឲ្យរួមចំណែកមូលនិធិ ព្រមទាំងបញ្ចូលនូវប្រតិបត្តិការកាន់តែទូលំទូលាយស្របតាមគោលបំណង និងការអនុវត្ត ផ.អ.គ.ស។

- **សហភាពអឺរ៉ុប៖** មូលនិធិសម្រាប់សង្គមស៊ីវិលរបស់សហភាពអឺរ៉ុប នឹងផ្តល់ជាឱកាសសម្រាប់អង្គការសង្គមស៊ីវិល ស្នើសុំឥណទានសម្រាប់អនុវត្តសកម្មភាពនានានៅក្នុងប្រទេសកម្ពុជា។ ការអនុវត្ត ផ.អ.គ.ស គឺស្របជាមួយលក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់ហិរញ្ញវត្ថុនេះ ហើយសហភាពអឺរ៉ុបអាចប្រកាសឲ្យមានការដាក់សំណើមកខ្លួន ដើម្បីអនុវត្តផ.អ.គ.ស។ សហភាពអឺរ៉ុប បានបើកឱកាសគាំទ្រដល់សង្គមស៊ីវិល ដែលប្រការនេះស្របទៅនឹងការគាំទ្ររបស់ខ្លួនលើការងារកំណែទម្រង់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហើយការងារនេះក៏គាំទ្រដល់ការចូលរួមរបស់ប្រជាពលរដ្ឋដូចបានបរិយាយក្នុងឯកសារផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម។
- **គម្រោងភាពជាដៃគូសកលសម្រាប់គណនេយ្យភាពសង្គម(GPSA)៖** ធនាគារពិភពលោក ក៏នឹងគ្រប់គ្រងចាត់ចែង (នៅទីស្នាក់ការកណ្តាលរបស់ខ្លួន) នូវមូលនិធិដែលផ្តោតជាពិសេសលើសកម្មភាពគណនេយ្យភាពសង្គម។ ដើម្បីឲ្យអង្គការមិនមែនរដ្ឋាភិបាលអាចទទួលបានមូលនិធិនេះ(គ.ជ.អ.ប) ត្រូវចុះហត្ថលេខាជាដៃគូជាមួយគម្រោងភាពជាដៃគូសកលសម្រាប់គណនេយ្យភាពសង្គម។ តំណាង អង្គការមិនមែនរដ្ឋាភិបាលបានចាប់ផ្តើមពិភាក្សាជាមួយគ.ជ.អ.ប ដើម្បីរៀបចំកិច្ចព្រមព្រៀង ប៉ុន្តែតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីមានកិច្ចព្រមព្រៀងនៅដំណាក់កាលបន្ទាប់។ កិច្ចព្រមព្រៀងនេះ គួរផ្តោតលើសកម្មភាព ផ.អ.គ.ស ។ ការផ្តល់មូលនិធិតាមរយៈយន្តការនេះមិនមានចំនួនច្រើននោះទេ (ថវិកាប្រហែល ៥០០.០០០ដុល្លារក្នុងរយៈពេល៣ឆ្នាំ) ប៉ុន្តែអ្នកទទួលថវិកា ត្រូវចូលរួមជាមួយដៃគូផ្សេងៗទៀតដើម្បីសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក។ នេះជាយន្តការមួយដែលមានលក្ខណៈស្ថាបនា និងគាំទ្រគ្នាទៅវិញទៅមក។
- **ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែត (Sida)** បានប្រកាសរួចហើយនូវគម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋឈ្មោះ **PROCEED** ដែលអនុវត្តនៅក្នុងស្រុកចំនួន៨ ក្នុងការសាកល្បងដំណើរការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈដៃគូជាអង្គការសង្គមស៊ីវិលក្នុងស្រុក។ **Sida** បានបញ្ជាក់ថាអង្គការ សង្គមស៊ីវិលទទួលបានថវិកាតាមរយៈគម្រោងនេះ អាចសម្រេចចូលរួម ដើម្បីអនុវត្តសកម្មភាពក្របខ័ណ្ឌការងារគណនេយ្យភាពសង្គម។ គេមិនទាន់ដឹងនៅឡើយទេ ថាតើអង្គការមិនមែនរដ្ឋាភិបាលទាំង៥ នឹងបន្តតាមរបៀបដែលអនុវត្តកន្លងមក ឬបង្វែរមកអនុវត្តតាមគោលនយោបាយនៃក្របខ័ណ្ឌការងារគណនេយ្យភាពសង្គមវិញ។
- **ទីភ្នាក់ងារ USAID** នឹងផ្តល់មូលនិធិសម្រាប់គម្រោង២ លើវិស័យសុខាភិបាល ក្នុងរយៈពេលពី ឆ្នាំ ២០១៤-២០១៨៖ ការផ្តល់សិទ្ធិអំណាចដល់សហគមន៍សម្រាប់កែលំអស្ថានភាពសុខភាព និងព័ត៌មានពាក់ព័ន្ធសុខភាព គោលនយោបាយ និងការតស៊ូមតិ ដើម្បីជួយពង្រឹងការអនុវត្តសកម្មភាព ផ.អ.គ.ស ដែលពាក់ព័ន្ធនឹងសកម្មភាពលើកកម្ពស់សុខភាព។ មានការពិភាក្សាពីរបៀបដើម្បីបញ្ចូលគម្រោងនេះទៅក្នុងផ.អ.គ.ស។

ការផ្តល់ហិរញ្ញវត្ថុសម្រាប់អ្នកផ្តល់ការបណ្តុះបណ្តាលស្តីពី ផ.អ.គ.ស (នៅក្នុងសមាសភាគទី៣ខ) នឹងត្រូវពិភាក្សាបន្តទៀត។ ទាំងនេះគឺអាស្រ័យលើការផ្តល់ហិរញ្ញវត្ថុពីLGDP ឬការផ្តល់ពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត។ ទាល់តែមានការផ្តល់ហិរញ្ញវត្ថុនេះជាក់ស្តែង ទើបអង្គការមិនមែនរដ្ឋាភិបាល ដែលអនុវត្តការងារទាំងនេះអាចធ្វើ

ការបណ្ដុះបណ្ដាលបន្តទៀត។ តាមការគ្រោងទុកចាប់ពីពេលនេះរហូតដល់ឆ្នាំ២០១៤ ត្រូវមានការរៀបចំផ្ដល់នូវវិធីសាស្ត្រ និងមេរៀនជាមូលដ្ឋានសម្រាប់ការបណ្ដុះបណ្ដាល (នេះគឺអាស្រ័យលើគម្រោង DFGG ក្នុងការផ្ដល់ហិរញ្ញវត្ថុឲ្យបានឆាប់ ហើយការងារនេះត្រូវបញ្ចប់មុនដំណាច់ខែមិនាឆ្នាំ២០១៤។

**ការផ្ដល់ហិរញ្ញវត្ថុសម្រាប់ការសិក្សាស្វែងយល់ និងអ្នកត្រួតពិនិត្យតាមដានផែនការអនុវត្តគណនេយ្យភាពសង្គម (សមាសភាគទី ៤)។** សមាសភាគនេះ ត្រូវផ្ដល់ហិរញ្ញវត្ថុដាច់ដោយឡែកដើម្បីធានាថាការសិក្សាស្វែងយល់ និងការត្រួតពិនិត្យតាមដានត្រូវបានអនុវត្តដោយប្រុងប្រយ័ត្ន និងមាននិរន្តរភាព។ ប្រភពនៃការផ្ដល់ហិរញ្ញវត្ថុនឹងត្រូវពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍នានា។

ជំហានបន្ទាប់៖

- **អង្គការមិនមែនរដ្ឋាភិបាលកំពុងដំណើរការប្រជុំជាមួយដៃគូអភិវឌ្ឍន៍នានា៖** ដៃគូអភិវឌ្ឍន៍នានាអាចផ្ដល់មូលនិធិដល់អង្គការមិនមែនរដ្ឋាភិបាលដើម្បីអនុវត្ត ផ.អ.គ.ស ដោយអនុវត្តតាមគោលការណ៍ណែនាំ និងលក្ខខ័ណ្ឌកំណត់នានា។ ដៃគូអភិវឌ្ឍន៍ទាំងអស់ ប្រហែលមិនរួមគ្នាផ្ដល់មូលនិធិ ដល់សង្គមស៊ីវិលទេ ប៉ុន្តែពួកគេអាចចូលរួមក្នុងផែនការសម្របសម្រួលដើម្បីការអនុវត្តសកម្មភាពពាក់ព័ន្ធនានានៅមូលដ្ឋានឲ្យមានប្រសិទ្ធភាព។
- **ក្រុមរៀបចំតាក់តែងផែនការអនុវត្តសម្រាប់ក្របខ័ណ្ឌការងារគណនេយ្យភាពសង្គម នឹងរៀបចំយន្តការសម្រាប់ការចូលរួម** ព្រមទាំងពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល និង គ.ជ.អ.ប អំពីរបៀបនៃការអនុវត្ត។ ក្រុមការងាររបស់ធនាគារពិភពលោក នឹងបន្តផ្ដល់នូវការគាំទ្រផ្សេងៗ។
- **ធនាគារពិភពលោកកំពុងរៀបចំនូវឯកសារទស្សនទាន សម្រាប់ទទួលបានឥណទានពីមូលនិធិអភិវឌ្ឍន៍សង្គមរបស់ប្រទេសជប៉ុន (JSDF)សម្រាប់គាំទ្រសកម្មភាពផ្នែកតម្រូវការ៖** មានការរៀបចំនូវសំណើសុំចំនួន២ដែលមានថវិកាប្រហែល៤.៥លានដុល្លារអាមេរិច ដើម្បីគាំទ្រសកម្មភាពផ្នែកតម្រូវការសម្រាប់ផ.អ.គ.ស។ ទម្រង់នៃការផ្ដល់ឥណទាននេះ ទាមទារឲ្យអ្នកទទួលគឺមកពីសង្គមស៊ីវិល រីឯភ្នាក់ងាររដ្ឋាភិបាលមិនមានសិទ្ធិស្នើសុំឥណទាននេះទេ។ គេរំពឹងថាអ្នកទទួលបានឥណទាននេះគឺជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលមានសមត្ថភាពគ្រប់គ្រងចាត់ចែងហិរញ្ញវត្ថុស្របតាម ការទទួលខុសត្រូវផ្នែកសុចរិតភាពរបស់ធនាគារពិភពលោក។
- ដោយមានការគាំទ្រពីការិយាល័យប្រចាំប្រទេសរបស់ធនាគារពិភពលោក អង្គការមិនមែនរដ្ឋាភិបាល នឹងស្វែងរកឲ្យមានការព្រមព្រៀងគ្នាជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីក្លាយជាសមាជិកនៃក្រុមដៃគូសកលសម្រាប់ការងារគណនេយ្យភាពសង្គម។ មូលនិធិសម្រាប់ក្រុមដៃគូសកលសម្រាប់ការងារគណនេយ្យភាពសង្គមត្រូវបានបង្កើតឡើងនាពេលថ្មីៗនេះ នៅក្នុងធនាគារពិភពលោក។ ប្រទេសនានាអាចចូលរួមក្នុងក្រុមដៃគូសកលសម្រាប់ការងារគណនេយ្យភាពសង្គម ដើម្បីក្លាយជាប្រទេសសមាជិក និងដើម្បីអាចឲ្យអង្គការសង្គមស៊ីវិលស្វែងរកមូលនិធិ សម្រាប់អនុវត្តសកម្មភាពគណនេយ្យភាពសង្គម។ ក្រៅពីដំណើរការនេះ ប្រទេសកម្ពុជា នឹងព្រមព្រៀងទៅលើយុទ្ធសាស្ត្រសម្រាប់ការផ្ដល់ មូលនិធិ។ គេរំពឹងថាយុទ្ធសាស្ត្រនេះ នឹងផ្ដោតទៅលើសកម្មភាពគណនេយ្យភាពសង្គម។ ការផ្ដល់មូលនិធិតាមរយៈយន្តការនេះ មិនមានចំនួនច្រើនទេ (ប្រហែល៥០០.០០០ដុល្លារ សម្រាប់រយៈពេល ៣ឆ្នាំ)។

- ក្រុមការងាររបស់ធនាគារពិភពលោក និងក្រុមតាក់តែងឯកសារនឹងរៀបចំក្របខ័ណ្ឌការងារ (TOR) សម្រាប់ការផ្តល់ហិរញ្ញវត្ថុដល់ដៃគូដែលទទួលខុសត្រូវក្នុងការបណ្តុះបណ្តាល និងការសិក្សានានា។ ក្រុមរៀបចំការតាក់តែងឯកសារ មានTOR រួចហើយសម្រាប់ដៃគូគាំទ្រក្នុងស្រុកចំនួន២។
- ធនាគារពិភពលោក នឹងសម្របសម្រួលជាមួយUSAID ដើម្បីពិនិត្យមើលតើគម្រោងផ្នែកសុខភាពដែលគាំទ្រដល់សហគមន៍មូលដ្ឋាន និងសកម្មភាពអភិបាលកិច្ចដែលនឹងអនុវត្តនាពេលខាងមុខអាចបញ្ចូលទៅក្រោមក្របខ័ណ្ឌនៃផែនការអនុវត្តក្របខ័ណ្ឌការងារគណនេយ្យភាពសង្គមបានដែរឬទេ។

# ផ្នែកទី ៦
# ការគ្រប់គ្រងហានិភ័យ

ការអនុវត្តក្របខ័ណ្ឌការងារគណនេយ្យភាពសង្គម គឺជាកម្មវិធីដែលមានមហិច្ឆិតា ហើយក៏មានហានិភ័យផងដែរ។ មានវិធានការមួយចំនួនអាចកាត់បន្ថយបាននូវហានិភ័យចម្បងៗដូចបានបង្ហាញខាងក្រោមនេះ

## ៦.១. ហានិភ័យនិងវិធានការកាត់បន្ថយ

| ហានិភ័យ | ការវាយតម្លៃ | វិធានការកាត់បន្ថយ |
|---|---|---|
| 1. សមត្ថភាព (ភ្នាក់អនុវត្ត) | មធ្យម | • ហានិភ័យទាក់ទងនឹងសមត្ថភាពកើតមានឡើង នៅក្នុងការផ្តល់ឥណទានបន្តទៅឲ្យអង្គការមិនមែនរដ្ឋាភិបាល ហើយហានិភ័យនេះនឹងកាន់តែរីកធំឡើង នៅពេលដែលមិនមានថវិកាគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ការអនុវត្តការងារ ការត្រួតពិនិត្យ និងវាយតម្លៃ។ ហានិភ័យនេះអាចកាត់បន្ថយបានតាមរយៈការជ្រើសរើសអង្គការដៃគូណា ដែលធ្លាប់មានប្រវត្តិការងារល្អក្នុងការកសាង សមត្ថភាព និងគ្រប់គ្រងហិរញ្ញវត្ថុ។<br>• គ.ជ.អ.ប កំពុងអនុវត្តសមាសភាគគម្រោងDFGG ដែលអាចមានហានិភ័យតិចតួច។ កម្រិតនៃហានិភ័យនឹងមិនកើនឡើងទេ។ |
| 2. នយោបាយ | មធ្យម | • ក្នុងប្រព័ន្ធនយោបាយដែលមិនមានការប្រកួតប្រជែងខ្លាំង ការផ្តល់ព័ត៌មានអាចជាបញ្ហាលំបាកដែលកំពុងជំរុញដោយគណបក្សប្រឆាំង។ គណបក្សប្រឆាំងបានជំរុញឲ្យមានច្បាប់ជាតិស្តីពីសេរីភាពសារព័ត៌មាន។<br>• ម្យ៉ាងវិញទៀត ការផ្តល់ព័ត៌មាននៅមូលដ្ឋាន និងការចូលរួមរបស់ប្រជាពលរដ្ឋ គឺមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ សម្រាប់រដ្ឋបាលមូលដ្ឋាន។ គណនេយ្យភាពសង្គមអាចជាមធ្យោបាយមួយ ដើម្បី អនុវត្តនូវគោលការណ៍នានាដែលមានចែង។ |
| 3. ការសម្រប សម្រួលកម្មវិធី | បង្គួរ | • សកម្មភាពនានា ត្រូវអនុវត្តដោយរដ្ឋាភិបាលនិងសង្គមស៊ីវិល។ សកម្មភាពទាំងនេះ ស្របគ្នាជាមួយវដ្តនៃការងារគណនេយ្យភាពសង្គម។ កម្មវិធីនេះពាក់ព័ន្ធទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការក្នុងការរួមចំណែកដល់ដំណើរការរួម ដល់ការសម្រេចបានលទ្ធផល និងគោលបំណងនានា។ ក្រុមការងារថ្នាក់ជាតិ (រួមមានរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍) បានបង្កើតឡើង ប៉ុន្តែនៅមិនទាន់ដឹងតើមានប្រសិទ្ធភាពកម្រិតណានៅឡើយទេ។<br>• ការពន្យាពេលនៃការអនុវត្តដោយរដ្ឋាភិបាល នឹងមានផលប៉ះពាល់ទៅដល់កម្មវិធីទាំងមូល អាចធ្វើឲ្យការអនុវត្តកម្មវិធីមិនបានទៅតាមកាលវិភាគ។ ការរៀបចំមេរៀន និងការផ្តល់ការបណ្តុះបណ្តាលសម្រាប់ទាំងរដ្ឋាភិបាល និងសង្គមស៊ីវិល នឹងត្រូវអនុវត្តដោយភាគីទី៣។<br>• សកម្មភាពគណនេយ្យភាពសង្គមមួយចំនួនផ្សេងទៀត នៅមូលដ្ឋានកំពុងដំណើរការដោយដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលមួយចំនួន។ សកម្មភាពខ្លះបានជួយសម្របសម្រួល និងគាំទ្រដល់ផែនការអនុវត្តគណនេយ្យភាពសង្គម ហើយមួយចំនួនទៀតនឹងបន្តតាមយន្តការស្របគ្នា។ សកម្មភាពទាំងនោះនឹងមិនប៉ះពាល់ដល់ការអនុវត្ត ផ.អ.គ.សទេ លើកលែងតែធនធានសម្រាប់ផ. |

| | | |
|---|---|---|
| | | អ.គ.ស មិនបានទទួលពីដៃគូអភិវឌ្ឍន៍ដើម្បីយកទៅអនុវត្តសកម្មភាពទាំងនោះ។ |
| 4. ភាពជាម្ចាស់របស់រដ្ឋាភិបាល | មធ្យម | • ផ.អ.គ.ស ត្រូវបញ្ចូលក្នុងកម្មវិធីដែលកំពុងអនុវត្តដោយរដ្ឋាភិបាល ហើយយុទ្ធសាស្ត្ររបស់ផ្នែកផ្គត់ផ្គង់ត្រូវដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពរបស់រដ្ឋាភិបាល។ ដំណើរការរៀបចំ និងការចូលរួមផ្សេងៗត្រូវបានចំណាយពេលយ៉ាងយូរ ហើយផែនការសកម្មភាពនិងថវិកាមានចំនួនតិចជាងតម្រូវការដែលបានស្នើឡើងក្នុងការអនុវត្តគណនេយ្យភាពសង្គម។<br>• នៅមូលដ្ឋានការអនុវត្ត អាចនឹងមានភាពការយឺតយ៉ាវ ហេតុនេះត្រូវមានការណែនាំពីថ្នាក់ជាតិ។ |
| 5. ការផ្តល់សេវាការត្រួតពិនិត្យនិងនិរន្តរភាព | បង្គួរ | • ការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម គឺមានការលំបាកខ្លាំងដោយសារតែអ្នកចូលរួមមិនសូវយល់ពីទស្សនទានរបស់វា ដែលតម្រូវឲ្យមានការអភិវឌ្ឍទាំងជំនាញ និងការផ្លាស់ប្តូរឥរិយាបថ។ ដោយសារដំណើរការនេះពាក់ព័ន្ធការបណ្តុះបណ្តាលគ្រូបង្គោល និងយន្តការបណ្តុះបណ្តាលពីលើដល់ក្រោមរបស់រដ្ឋាភិបាលដូច្នេះហានិភ័យក្នុងផ្តល់សេវាគឺមានកម្រិតបង្គួរ។ ជំនួយបច្ចេកទេសនឹងត្រូវផ្តល់ដល់រដ្ឋាភិបាលក្នុងអំឡុងពេលអនុវត្តកម្មវិធីនេះដោយសារទស្សនទាននេះ អាចជារឿងថ្មីដែល ទាមទារនូវការយល់ដឹងបន្ថែមទៀត ។<br>• ដូច្នេះការងារជាអាទិភាព គឺបង្កើតយន្តការជាក់លាក់មួយដើម្បីធានានូវការត្រួតពិនិត្យ និងការសិក្សាស្វែងយល់ប្រកបដោយប្រសិទ្ធភាព។<br>• ហានិភ័យនៃនិរន្តរភាពគឺមានកម្រិតមធ្យមសម្រាប់សកម្មភាពផ្នែកផ្គត់ផ្គង់ ដោយសារការងារនេះត្រូវបានបញ្ចូលក្នុងការងាររបស់រដ្ឋាភិបាល ប៉ុន្តែមានកម្រិតបង្គួរសម្រាប់សកម្មភាពរបស់ផ្នែកតម្រូវការ ដោយសារសកម្មភាពទាំងនោះតម្រូវឲ្យមានការផ្តល់មូលនិធិតាមយន្តការឯករាជ្យ ឬតាមយន្តការរបស់រដ្ឋាភិបាល (ដូចជាយន្តការមូលនិធិឃុំសង្កាត់) ដែលងាយក្នុងការជាប់គាំង។ |
| 6. ថវិកាមិនគ្រប់គ្រាន់ និងវិសាលភាពមានទំហំតូច | ទាប-មធ្យម | • ផែនការអនុវត្តក្របខ័ណ្ឌការងារគណនេយ្យភាពសង្គមបានបង្កើតឡើងតាមរបៀបមួយដែលងាយស្រួលក្នុងការពង្រីកសកម្មភាពប្រសិនបើមានការផ្តល់ហិរញ្ញវត្ថុបន្ថែម។<br>• ថវិកាដែលមានស្រាប់ មានចំនួនគ្រប់គ្រាន់ក្នុងការអនុវត្តសកម្មភាពសំខាន់ៗនៃការងារគណនេយ្យភាពសង្គម និងមានការកត់ត្រាត្រឹមត្រូវ ដែលនឹងទាក់ទាញការចាប់អារម្មណ៍របស់ដៃគូអភិវឌ្ឍន៍ក្នុងការផ្តល់ថវិកាគាំទ្រ។ |

# ផ្នែកទី ៧
# លទ្ធផលរំពឹងទុកពីការអនុវត្ត

លទ្ធផលដែលរំពឹងទុកបានឆ្លុះបញ្ចាំងនៅក្នុងឯកសារក្របខ័ណ្ឌគណនេយ្យភាពសង្គម (ខែធ្នូឆ្នាំ២០១២)។ សកម្មភាពគណនេយ្យភាពសង្គម ទទួលបានលទ្ធផលដូចខាងក្រោម៖

- មានការប្រែប្រួល ឬការឆ្លើយតបដោយរដ្ឋាភិបាល ដោយសារការបង្កើតឲ្យមានទំនាក់ទំនងគ្នាទៅវិញ ទៅមក និងមានការចូលរួមពីប្រជាពលរដ្ឋ និង/ឬ តំណាងប្រជាពលរដ្ឋ
- សមត្ថភាពប្រជាពលរដ្ឋ (ទាំងស្ត្រី និងបុរស) និងអង្គការតំណាងរបស់ពួកគាត់មានការកើនឡើង ដែលអាចបន្តការលើកកម្ពស់ទំនាក់ទំនងជាមួយរដ្ឋាភិបាល ក្នុងការពង្រឹងគោលដៅគណនេយ្យភាពតាមបែបប្រជា ធិបតេយ្យ។

ការអនុវត្តការងារក្របខ័ណ្ឌគណនេយ្យភាពសង្គមរួមចំណែកដល់៖

- **ការផ្តល់សេវា និងការវិភាជន៍ធនធានកាន់តែមានប្រសិទ្ធិភាព សមធម៌ និងកាន់តែមានគណនេយ្យភាព។** ការចូលរួមរបស់ស្ថាប័ន អង្គភាពផ្តល់សេវាសាធារណៈ គួរត្រូវបានគ្រប់គ្រងឲ្យកាន់តែប្រសើរ កាន់តែមានការឆ្លើយតបមានគណនេយ្យភាព និងតម្លាភាព។ សកម្មភាពរបស់ស្ថាប័ន អង្គភាពទាំងនោះគួរឆ្លើយតបឲ្យកាន់តែប្រសើរតាមតម្រូវការអាទិភាពរបស់ម្ចាស់ឆ្នោត ហើយត្រូវខិតខំការពារនិងបម្រើផលប្រយោជន៍របស់ក្រុមជនងាយរងគ្រោះ។
- **ការផ្តល់សិទ្ធិអំណាចកាន់តែប្រសើរ៖** សហគមន៍ និងប្រជាពលរដ្ឋ ពិសេសស្ត្រី និងយុវវ័យ ដែលបានចាត់ទុកថាជាភ្នាក់ងារធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងសំខាន់ គួរត្រូវបានផ្តល់សិទ្ធិអំណាចដើម្បីអាចយល់ដឹងនូវសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគាត់ ក្នុងការបង្កើនទំនាក់ទំនងជាមួយរដ្ឋាភិបាល។
- **មូលធនសង្គមកាន់តែប្រសើរ៖** ការកសាងមូលធនសង្គម និងការកើនឡើងនូវទំនុកចិត្ត រវាងសមាជិកសហគមន៍ និងរវាងប្រជាពលរដ្ឋ ជាមួយអង្គភាពរបស់រដ្ឋ គឺមានសារៈសំខាន់ណាស់សម្រាប់ទាំងការអភិវឌ្ឍសង្គម និងការរីកចំរើនផ្នែកសេដ្ឋកិច្ច។
- **ការរួបរួម និងឯកភាពគ្នាក្នុងសង្គមកាន់តែប្រសើរ៖** មូលធនសង្គមកាន់តែបានពង្រឹងនឹងនាំដល់ការ ឯកភាពក្នុងសង្គម មានអត្តសញ្ញាណ និងទំនុកចិត្តរបស់សង្គមកាន់តែរឹងមាំ ដែលជាសមាសធាតុ ដ៏ចាំបាច់ក្នុងការអភិវឌ្ឍមូលដ្ឋាន។
- **សមធម៌សង្គម និងការអភិវឌ្ឍកាន់តែមានការចូលរួម៖** មានការចូលរួមជាមតិយោបល់ប្រកបដោយសមធម៌ និងគ្រប់ ជ្រុងជ្រោយរបស់ស្ត្រី យុវវ័យ និងក្រុមជនងាយរងគ្រោះនៅក្នុង៖ (ក) ដំណើរការនយោបាយនៅមូលដ្ឋាន និង(ខ) ការរៀបចំសម្រាប់ការផ្តល់សេវា និងការកែលំអស្ថានភាពរូបវ័ន្តដែលមានឥទ្ធិពលដល់ក្រុមប្រជាពលរដ្ឋក្រីក្រ។

## ៧.១. គោលបំណង និងសូចនាកររួម

**តើការផ្លាស់ប្តូរប្រែប្រួលមានអ្វីខ្លះដែលគេរំពឹងទទួលបានពីការអនុវត្ត ផ.អ.គ.ស?**

១. **គោលបំណងអភិវឌ្ឍន៍៖** គោលបំណងអភិវឌ្ឍន៍នៃផែនការផ.អ.គ.ស គឺដើម្បីធ្វើឲ្យប្រសើរនូវគណនេយ្យភាព និងការឆ្លើយតបរបស់អ្នកផ្តល់សេវា និងរដ្ឋបាលមូលដ្ឋាន សម្រាប់ការផ្តល់សេវា និងការវិភាជន៍ធនធាន ឲ្យកាន់តែប្រសើរ (ពិសេសសម្រាប់ស្ត្រី យុវវ័យ និងក្រុមជនងាយរងគ្រោះ)។

២. សូចនាករនៃគោលបំណងខាងលើ អាចវាស់វែងបានតាមរយៈការផ្លាស់ប្តូរប្រែប្រួលលើ៤ទិដ្ឋភាព៖

- ភាពឆ្លើយតប៖ សេវាត្រូវបានផ្តល់ប្រកបដោយសមធម៌
- គណនេយ្យភាព៖ កម្រិតនៃការបើកទូលាយនិងការឆ្លើយតបចំពោះការផ្តល់យោបល់ត្រឡប់របស់ សហគមន៍
- សម្លេង និងការផ្តល់សិទ្ធិអំណាច
- បរិយាកាសគាំទ្រ

## ៧.២ សមាសភាគគោលបំណង និងសូចនាករ

គោលបំណង និងសូចនាកររបស់សមាសភាគនីមួយៗ នឹងវាស់វែងនូវការផ្លាស់ប្តូរប្រែប្រួល ដើម្បីសម្រេចបាននូវលទ្ធផល ។ គោលបំណង និងសូចនាករភាគច្រើនមានការផ្សារភ្ជាប់គ្នា ដែលនឹងនាំឲ្យមានការផ្លាស់ប្តូរប្រែប្រួល។

- **សមាសភាគទី១ ធ្វើឲ្យកាន់តែងាយស្រួលក្នុងការទទួលបានព័ត៌មានក្នុងមូលដ្ឋាន និងព័ត៌មានពាក់ព័ន្ធថវិកាដើម្បីឲ្យសមត្ថភាព និងចំណេះដឹងរបស់អ្នកពាក់ព័ន្ធកាន់តែប្រសើរ។** ការផ្លាស់ប្តូរប្រែប្រួលនឹងត្រូវបានវាស់វែងតាមរយៈលំហូរព័ត៌មាន ការបើកទូលាយថវិកាមូលដ្ឋាន និងការប្រើប្រាស់ព័ត៌មាននានា និងព័ត៌មានថវិកា
- **សមាសភាគទី២ ធ្វើឲ្យប្រសើរនូវការផ្តល់យោបល់ត្រឡប់របស់ប្រជាពលរដ្ឋ ការត្រួតពិនិត្យតាម ដានលើការផ្តល់សេវានានា និងការវិភាជន៍ធនធាន។** ត្រូវបានវាស់វែងតាមរយៈការប្រែប្រួលនៅក្នុងកម្រិតនៃការចូលរួមត្រួតពិនិត្យតាមដាន និងការផ្តល់យោបល់ត្រឡប់របស់ប្រជាពលរដ្ឋ និងអ្នកទទួលផល សមធម៌ការវិភាជន៍ធនធាន និងឥរិយាបថ ឬទង្វើផ្សេងៗ។
- **សមាសភាគទី៣ បង្កើនសម្លេងរបស់ប្រជាពលរដ្ឋ ផ្តល់សិទ្ធិអំណាច និងសមត្ថភាព សម្រាប់ ដំណើរការគណនេយ្យភាពសង្គម។** ត្រូវបានវាស់វែងការប្រែប្រួលតាមរយៈការទទួលបានសិទ្ធិអំណាច និងសមត្ថភាព របស់សហគមន៍ ក៏ដូចជាសមត្ថភាពរបស់តួអង្គផ្សេងៗទៀតនៅមូលដ្ឋាន។
- **សមាសភាគទី៤ បង្កើនសមត្ថភាពអ្នកពាក់ព័ន្ធនានាឲ្យមានការយល់ដឹង និងការចូលរួមក្នុងដំណើរការផ្លាស់ប្តូរប្រែប្រួល។** ត្រូវបានវាស់វែងតាមរយៈការចូលរួមរបស់អ្នកពាក់ព័ន្ធនានានៅក្នុង ដំណើរការផ្លាស់ប្តូរប្រែប្រួល និងជំរុញឲ្យមានការផ្លាស់ប្តូរប្រែប្រួលលើគោលនយោបាយ និងការអនុវត្តផ្សេងៗ។

## តារាង ៧.១. លទ្ធផលសំខាន់ៗ និងការវាស់វែង

| តើការប្រែប្រួលអ្វីខ្លះនិងទទួលបានពី ផ.ស.គ.ស | តើលទ្ធផលអ្វីខ្លះនឹងទទួលបានក្នុងរយៈពេល៣ឆ្នាំ? | តើអ្វីជាខ្នាតវាស់វែង? | តើការវាស់វែងត្រូវធ្វើដូចម្តេច? |
|---|---|---|---|
| សូចនាករ | | | |
| ការប្រែប្រួលក្នុងការ ផ្តល់សេវា និងសមធម៌ក្នុងការផ្តល់សេវា | ប្រជាពលរដ្ឋទទួលបានសេវាកាន់តែប្រសើរ និងទទួលបាននូវសេវាផ្សេងៗទៀតនៅមូលដ្ឋាន។ | - ភាគរយប្រជាពលរដ្ឋដែលរាយការណ៍ពេញចិត្តមានការកើនឡើងស្របនឹងកញ្ចប់សេវា ដែលបាន ផ្តល់ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវា | លទ្ធផលប័ណ្ណដាក់ពិន្ទុប្រចាំឆ្នាំដែលបានចងក្រងនឹង ធ្វើការប្រៀបធៀបជាមួយក្រុមដែលមិនទាន់បានអនុវត្តសកម្មភាព |
| | មានការផ្លាស់ប្តូរប្រែប្រួលជារួមទាំងស្ត្រី យុវវ័យ និងប្រជាពលរដ្ឋក្រីក្រក្នុងការទទួលបានផលប្រយោជន៍ពីការផ្តល់សេវា | - ភាគរយស្ត្រី យុវវ័យ និងក្រុមប្រជាពលរដ្ឋងាយរងគ្រោះដែលរាយការណ៍ថាការពេញចិត្តមានការកើនឡើងស្របនឹងកញ្ចប់សេវា ដែលបានផ្តល់ដោយរដ្ឋបាលថ្នាក់ ក្រោមជាតិ និងអ្នកផ្តល់សេវា | លទ្ធផលប័ណ្ណដាក់ពិន្ទុប្រចាំឆ្នាំដែលបានចង ក្រងនឹង ធ្វើការប្រៀបធៀបជាមួយក្រុមដែលមិនទាន់បានអនុវត្តសកម្មភាព |
| ការប្រែប្រួល លើការបញ្ចេញសម្លេង និង សិទ្ធិអំណាច | ដំណើរការផ្លាស់ប្តូរប្រែប្រួលនឹងផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋក្នុងការលើកយកកង្វល់របស់ខ្លួន និងទាមទារឲ្យមានគណនេយ្យភាពពីអ្នកផ្តល់សេវា និងមន្ត្រី រដ្ឋាភិបាល | - ភាគរយស្រុកដែលប្រជាពលរដ្ឋ អាចបញ្ចេញសម្លេងរបស់គាត់ ក្រៅពីស្រុក គោលដៅផ.ស.គ.ស | ការវាយតម្លៃលើការផ្តល់សិទ្ធិអំណាចនិងសមត្ថភាព (បែងចែកតាមស្ត្រីនិងយុវវ័យ) |
| ការប្រែប្រួល លើបរិយាកាសគាំទ្រ (អភិបាលកិច្ចមូលដ្ឋាន) | ស្ថានភាព យន្តការអនុវត្តច្បាប់អាចឲ្យសង្គមស៊ីវិលចូលរួមក្នុងការត្រួតពិនិត្យលើការបំពេញការងាររបស់រដ្ឋាភិបាល។<br>ថវិកាត្រូវបានវិភាជន៍សម្រាប់ការអនុវត្ត។<br>ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងផ្តល់ឱកាសសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋ | **(ការផ្លាស់ប្តូរគោលយោបាយ)**<br>- ភាគរយនៃសកម្មភាពធ្វើឲ្យមានការផ្លាស់ប្តូរផ្អែកតាមរបាយការណ៍របស់អង្គការសង្គមស៊ីវិល។<br>**(ថវិកាអនុវត្តគោលនយោបាយ)**<br>- ភាគរយស្រុកដែលមានថវិកាគាំទ្រសកម្មភាពដើម្បី លើកកម្ពស់ការទទួលបានព័ត៌មាននៅមូលដ្ឋាន ថវិកា និងការត្រួតពិនិត្យតាមដាន របស់ប្រជាពលរដ្ឋ។<br>**(ការអនុវត្តគោលនយោបាយ)**<br>- ភាគរយស្រុកគោលដៅ ដែលអនុវត្តគោលនយោ- បាយស្របតាមលិខិត បទដ្ឋាននានា។ | ការកត់ត្រារបាយការណ៍ប្រចាំខែពីការរីកចម្រើនលើការរៀបចំគោលនយោបាយ។<br>របាយការណ៍ប្រចាំត្រីមាសពីNGOsនៅមូលដ្ឋាននិងរបាយការណ៍របស់គ.ជ.អ.ប (ការធ្វើសវនកម្មលើព័ត៌មាន)<br>ការវាយតម្លៃលើការផ្តល់សិទ្ធិអំណាចនិងសមត្ថភាព។ |

| | | | |
|---|---|---|---|
| | | (និរន្តរភាព)<br>- គ.ជ.អ.បបន្តផ្តល់អាទិភាពលើការងារគណនេយ្យភាពសង្គមក្នុងផែនការរបស់ខ្លួន។ | |
| **សមាសភាគទី១ ភាពងាយទទួលបានព័ត៌មានស្តីពីស្តង់ដា ថវិកា និងការបំពេញមុខងារ** | | | |
| **ការប្រែប្រួល អំពីតម្លាភាព និងភាពបើកទូលាយ** | កញ្ចប់ព័ត៌មាន (I4Cs) ត្រូវបានចងក្រង ស្របតាមសេចក្តីណែនាំ | - ភាគរយស្រុកដែលជារដ្ឋបាលថ្នាក់ក្រោមជាតិ ឬអ្នកផ្តល់សេវាមូលដ្ឋាន ច្រើនជាង៧០%បានប្រមូលនិងចងក្រងកញ្ចប់ពត៌មាន (I4Cs) ស្របតាមសេចក្តីណែនាំ | ដៃគូអង្គការសង្គមស៊ីវិលធ្វើរបាយការណ៍ ប្រចាំត្រីមាស ឬរបាយ ការណ៍អធិការកិច្ចប្រចាំឆ្នាំ និងព័ត៌មានសវនកម្ម |
| | ថវិកាត្រូវបានបិទផ្សាយជាសាធារណៈ ស្របតាមទម្រង់គំរូ | **(ការវាស់វែងអំពីព័ត៌មានដែលមាន)**<br>- ភាគរយស្រុកដែលជារដ្ឋបាលថ្នាក់ក្រោមជាតិ ឬអ្នកផ្តល់សេវាមូលដ្ឋានច្រើនជាង៧០% បានបង្ហាញថវិកាស្របតាមទម្រង់គំរូដែលផ្តល់ឲ្យ។<br>- ភាគរយស្រុកដែលមានមន្ត្រីមានសមត្ថភាពកើនឡើងក្នុងការយល់ដឹងពីថវិកានិងតម្លាភាព ថវិកា | ដៃគូអង្គការសង្គមស៊ីវិលធ្វើរបាយការណ៍ប្រចាំត្រីមាស |
| | ការអនុវត្តលិខិតបទដ្ឋាននានាត្រូវបានពង្រឹង | **(ការវាស់វែងការអនុវត្តតាម)**<br>- ភាគរយស្រុកអនុវត្តតាមគោលការណ៍ និងលិខិតបទដ្ឋាននានា | របាយការណ៍អនុវត្ត របស់ស្រុក អាចធ្វើ ប្រចាំឆ្នាំនិងរបាយការណ៍អធិការកិច្ច |
| **ការប្រែប្រួល លើភាពងាយស្រួលទទួលបានព័ត៌មាន និង ការយល់ដឹងអំពីថវិកា** | ប្រជាពលរដ្ឋអាចទទួលបានកញ្ចប់ព័ត៌មាន (I4Cs) ហើយបានយល់ដឹងពីខ្លឹមសារនិងអាចប្រើប្រាស់ព័ត៌មានបាន | **(ការវាស់វែងពីការយល់ដឹង)**<br>- ភាគរយប្រជាពលរដ្ឋយល់ដឹងថាមានព័ត៌មាន និងយល់អំពីខ្លឹមសាររបស់កញ្ចប់ព័ត៌មាន (I4Cs)។<br>**(ការវាស់វែងការប្រើប្រាស់)**<br>- ភាគរយកិច្ចប្រជុំដែលបានយកកញ្ចប់ព័ត៌មាន(I4Cs) ធៀបជាមួយស្តង់ដារបំពេញការងារ និងគោលនយោបាយ ក្នុងដំណើរការត្រួតពិនិត្យតាមដាន។ | គំរូកំណត់ហេតុនៃកិច្ច ប្រជុំស្តីពីប័ណ្ណដាក់ពិន្ទុ។ ដៃគូអង្គការសង្គមស៊ីវិលធ្វើរបាយការណ៍ ប្រចាំត្រីមាសដាក់ជូនស្ថាប័នសម្របសម្រួលថ្នាក់ជាតិ។ |

| | | | |
|---|---|---|---|
| | ប្រជាពលរដ្ឋមានការយល់ដឹងអំពីថវិកា និងចេះប្រើប្រាស់ព័ត៌មានទាំងនោះ | - ភាគរយស្រុក ដែលមានប្រជាពលរដ្ឋពិភាក្សាពីបញ្ហាថវិកា និងការចំណាយក្នុងការកិច្ចប្រជុំត្រួតពិនិត្យតាមដាន។<br>- ភាគរយស្រុក ដែលបញ្ហាថវិកាត្រូវបានលើកឡើងក្នុងវេទិកាធំៗនានា។ | មានគំរូកំណត់ហេតុ នៃកិច្ចប្រជុំសម្រាប់កត់ត្រានូវប្រធានបទពិភាក្សា។<br>របាយការណ៍អនុវត្តប្រចាំត្រីមាសរបស់ដៃគូអង្គការសង្គមស៊ីវិលធ្វើ ដើម្បីដាក់ជូនស្ថាប័នសម្របសម្រួលថ្នាក់ជាតិ។ |
| **សមាសភាគទី២ ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ** | | | |
| **ការប្រែប្រួល លើការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការត្រួតពិនិត្យការបំពេញការងារនិងផ្តល់យោបល់ត្រឡប់ (គណនេយ្យភាព)** | ការត្រួតពិនិត្យតាមដានដោយសហគមន៍ប្រជាពលរដ្ឋដោយមានផែនការសកម្មភាពគណនេយ្យភាពរួមគ្នា (ផ.ស.គ.រ) ក្លាយជាផ្នែកនៃវដ្តអនុវត្តប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងភ្នាក់ងារផ្តល់សេវានានា។ | - ភាគរយស្រុកដែលជារដ្ឋបាលថ្នាក់ក្រោមជាតិ និង អ្នកផ្តល់សេវានៅមូលដ្ឋាន បានបញ្ចប់ការធ្វើប័ណ្ណដាក់ពិន្ទុប្រចាំឆ្នាំ។<br>- ភាគរយនៃផ.ស.គ.រ ដែលបានបញ្ចប់ស្របតាមសេចក្តីណែនាំធ្វើប្រចាំឆ្នាំ (ជាឧទាហរណ៍ មានសកម្មភាពចំនួន៤៖ សហគមន៍ ក្រុមប្រឹក្សាឃុំ/ស្រុក អ្នកផ្តល់សេវា និងសកម្មភាពរបស់មន្ត្រីស្រុក)។<br>- ភាគរយនៃផ.ស.គ.រ ដែលត្រូវបានអនុវត្ត (ឧទាហរណ៍ជាង ៧០%នៃសកម្មភាពត្រូវបានអនុវត្ត)។<br>- ភាគរយនៃផ.ស.គ.រ ក្នុងតំបន់គោលដៅដែល បានស្នើសុំ ឬ បំពេញប័ណ្ណដាក់ពិន្ទុស៊ីជម្រៅប្រចាំឆ្នាំក្នុងវិស័យអាទិភាព។ | របាយការណ៍អនុវត្ត ប្រចាំត្រីមាសរបស់ ដៃគូអង្គការសង្គមស៊ីវិល។ |
| **ការប្រែប្រួលលើការរួបរួមបញ្ចូលគ្នា (ភាពឆ្លើយតប)** | ផ.ស.គ.រ បានឆ្លុះបញ្ចាំងអំពីការព្រួយបារម្ភរបស់ប្រជាពលរដ្ឋ និងក្រុមជនងាយរងគ្រោះ | - ភាគរយរដ្ឋបាលឃុំ ស្រុក ដែលមានការចំណាយ របស់ឃុំ ស្រុក សាលារៀននិងមណ្ឌលសុខភាព ដែលមានឆ្លុះបញ្ចាំងក្នុង ផ.ស.គ.រ។<br>- ភាគរយនៃផ.ស.គ.រ ដែលបានដោះស្រាយប្រចាំឆ្នាំ នូវចំនួនសកម្មភាពអាទិភាពរបស់ ស្ត្រី យុវវ័យ | របាយការណ៍អនុវត្ត ប្រចាំត្រីមាសរបស់ ដៃគូអង្គការសង្គមស៊ីវិល |

| | | | |
|---|---|---|---|
| **ការប្រែប្រួល លើការវិភាជន៍ធនធាន (ភាពឆ្លើយតប)** | ឯកសារថវិកានិងការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវា មានការប្រែប្រួលដែលឆ្លុះបញ្ចាំងពីបញ្ហានិងសកម្មភាពជាអាទិភាពដែលបានកំណត់ក្នុងដំណើរការបំពេញប័ណ្ណដាក់ពិន្ទុ | - ភាគរយឃុំ ស្រុក ដែលមានថវិកា ការចំណាយ របស់ឃុំ ស្រុក សាលា រៀននិង មណ្ឌលសុខភាព ត្រូវឆ្លុះបញ្ចាំងពីអាទិភាព ដែលមានក្នុងផ.ស.គ.រ។ | របាយការណ៍អនុវត្ត ប្រចាំត្រីមាសរបស់ ដៃគូអង្គការសង្គមស៊ីវិល |
| **ការប្រែប្រួល លើឥរិយាបថ និង ទង្វើនានា (ភាពឆ្លើយតប)** | ការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ និងសកម្មភាពជំរុញផ.ស.គ.រ ជាមួយអ្នកពាក់ព័ន្ធកំណត់នូវៈ<br>➢ អ្នកផ្តល់សេវា ដើម្បីកែលំអរឥរិយាបថ និងទង្វើនានា<br>➢ សមាជិកក្រុមប្រឹក្សាប្រើប្រាស់កាន់តែ ប្រសើរនូវតួនាទីរបស់ខ្លួនក្នុងការជំរុញឲ្យ មានការផ្លាស់ប្តូរប្រែប្រួល<br>➢ មន្ត្រីស្រុកកែលំអនូវរបៀបរបបអនុវត្ត<br>➢ សហគមន៍ចូលរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តសកម្មភាព<br>➢ រដ្ឋបាលស្រុក ធ្វើជាស្ថាប័ននីយកម្ម គ្រប់ដំណើរការនានា | **(ការបំពេញការងារ)**<br>- ភាគរយសាលារៀន មណ្ឌល សុខភាព មានការ កែលំអឥរិយាបថ បន្ទាប់ពីការអនុវត្តផ.ស.គ.រ (ដូចជា ពេលម៉ោងបំពេញ ការងារ អត្តចរិក ចំពោះ អ្នកជំងឺ លទ្ធភាពចុះបញ្ជីកំណើត បញ្ជីមរណភាព)<br>**(សិទ្ធិអំណាច និងទង្វើរបស់សមាជិកក្រុមប្រឹក្សា)**<br>- ភាគរយឃុំ ស្រុក ដែល សមាជិកក្រុមប្រឹក្សាត្រូវ បានផ្តល់សិទ្ធិអំណាចក្នុងការលើកកម្ពស់ការបំពេញការងាររបស់អ្នកផ្តល់សេវានៅមូលដ្ឋាន។<br>(ការអនុវត្តតាម/អធិការកិច្ច)<br>- ភាគរយស្រុកដែលមន្ត្រី មន្ទីរសុខាភិបាល និងមន្ទីរអប់រំ បានកែលំអការអនុវត្តតាម ឬ អធិការកិច្ចរបស់សាលារៀន និងមណ្ឌលសុខភាព។<br>**(មូលធនសង្គម ភាពជាដៃគូ)**<br>- ភាគរយនៃផ.ស.គ.រដែលបាន អនុវត្ត និងរួមបញ្ចូលកម្មភាពសហគមន៍ | របាយការណ៍អនុវត្តផ.ស.គ.រ របស់ដៃគូអង្គការសង្គមស៊ីវិល<br><br>ការប្រៀបធៀបប័ណ្ណដាក់ពិន្ទុ ជាមួយក្រុមដែលមិនទាន់បានអនុវត្តសកម្មភាព<br><br>ការសិក្សាពីការផ្តល់សិទ្ធិ អំណាច?<br><br>របាយការណ៍អនុវត្តផ.ស.គ.រ របស់ ដៃគូអង្គការសង្គមស៊ីវិល។<br><br>របាយការណ៍អនុវត្តផ.ស.គ.រ របស់ ដៃគូអង្គការសង្គមស៊ីវិល។ |
| **សមាសភាគទី៣ ការសម្របសម្រួល និងការពង្រឹងសមត្ថភាព** | | | |
| **ការប្រែប្រួលលើសិទ្ធិអំណាច និងសមត្ថភាពរបស់ប្រជាពលរដ្ឋ** | ការចូលរួមរបស់សហគម (ពិសេសស្ត្រី និងយុវវ័យ) ត្រូវបានផ្លាស់ប្តូរពីភាពអសកម្មទៅជាការចូលរួម | - ភាគរយនៃការប្រែប្រួលតាមរយៈ ឯកសារនៃកិច្ចប្រជុំនិងអ្នកចូលរួម<br>- ភាគរយកិច្ចប្រជុំរបស់សហគមន៍ | របាយការណ៍អនុវត្តផ.ស.គ.រ របស់ ដៃគូអង្គការសង្គមស៊ីវិល។ |

| | | | |
|---|---|---|---|
| | យ៉ាងសកម្មវិញ<br><br>ប្រជាពលរដ្ឋកាន់តែមានការយល់ដឹងអំពីសិទ្ធិទទួលបានសេវា និងការបំពេញនូវការផ្តល់សេវា | ដែលពិភាក្សាពីគម្លាតរវាងបទដ្ឋានស្តង់ដារជាមួយការបំពេញការងារ ជាក់ស្តែង<br>- ភាគរយស្រុក ដែលតាមរយៈការវិភាគពីគម្លាត នាំឲ្យមានសកម្មភាពបញ្ចូលទៅក្នុងផ.ស.គរ។ | មានការសិក្សាអំពីសិទ្ធិអំណាចនិងសមត្ថភាព |
| **ការប្រែប្រួលផ្នែកសមត្ថភាពរបស់អ្នក ពាក់ព័ន្ធនានានៅមូលដ្ឋាន** | អ្នកសម្របសម្រួល សហគមន៍កាន់តែមានឆន្ទៈ និងសមត្ថភាពលើដំណើរការសម្របសម្រួល និងបញ្ជ្រាបការងារគណនេយ្យភាពបានដល់គ្រប់កន្លែង។<br>ដៃគូអង្គការសង្គមស៊ីវិលនៅមូលដ្ឋានកាន់ តែមានលទ្ធភាព ហ្វឹកហ្វឺន និងគាំទ្រ ដល់សកម្មភាពសហគមន៍។<br>អង្គភាពនានារបស់រដ្ឋបាលមូលដ្ឋានកាន់តែបានយល់ច្បាស់នូវគណនេយ្យភាពរបស់ខ្លួនហើយមានលទ្ធភាពក្នុងការធ្វើសកម្មភាព។ | - ភាគរយនៃប័ណ្ណដាក់ពិន្ទុត្រូវបានប្រែក្លាយជា ផែនការសកម្មភាពជាក់ស្តែង។<br>- ចំនួនប័ណ្ណដាក់ពិន្ទុនិងដំណើរការផ.ស.គ.រ ត្រូវបានពង្រីកអនុវត្តចំពោះវិស័យផ្សេងៗទៀត។<br>- ការវាយតម្លៃចំណេះដឹង និងលទ្ធភាពប្រើប្រាស់ យន្តការគណនេយ្យភាព សង្គម | មានការសិក្សាអំពីសិទ្ធិអំណាចនិងសមត្ថភាព |
| សមាសភាគទី ៤ ការប្រមូល មេរៀនបទពិសោធន៍ និងការត្រួតពិនិត្យតាមដាន | | | |
| **ការផ្លាស់ប្តូរលើទម្លាប់នានានៃការសិក្សាស្វែងយល់ និងដកស្រង់បទពិសោធន៍<br>(សមត្ថភាព)** | សមត្ថភាពនិងឆន្ទៈ ចូលរួមក្នុងការរៀនសូត្រ នូវមេរៀននានា<br>គុណភាពនៃការទុកដាក់ឯកសារនិងការពិគ្រោះយោបល់ស្តីពីដំណើរការផ្លាស់ប្តូរត្រូវបានធ្វើឲ្យប្រសើរឡើង។ | - ការវាយតម្លៃមេរៀននានាពីដំណើរការអនុវត្តដែលត្រូវបានចងក្រងជាឯកសារនិងអាចរកបាន។<br>- ការវាយតម្លៃចំណងទាក់ទងនានាត្រូវបានធ្វើឡើងមេរៀន នានាត្រូវបានចងក្រង និងអនុវត្តតាម។<br>- ការវាយតម្លៃការបណ្តុះបណ្តាល និងកម្មវិធីពង្រឹងសមត្ថភាពនានាដែលប្រើប្រាស់មេរៀនទាំងនោះ។ | របាយការណ៍ប្រចាំ ត្រីមាសរបស់អង្គការ សង្គមស៊ីវិល។<br><br>របាយការណ៍ប្រចាំ ត្រីមាសស្តីពីដំណើរ ការនៃការរៀនសូត្រពីបទពិសោធន៍។<br><br>មានការសិក្សាអំពីសិទ្ធិអំណាចនិងសមត្ថភាព |
| **ការផ្លាស់ប្តូរលើរបៀប នៃរៀបចំបង្កើតគោលនយោបាយ** | មេរៀន និងយោបល់ ត្រឡប់នានាជំរុញឲ្យមានការផ្លាស់ ប្តូរគោលនយោបាយ និងការអនុវត្ត | ចំនួនមេរៀន ដែលជំរុញ ឲ្យមានការផ្លាស់ប្តូរនានា នៅក្នុងគោលនយោបាយ និងការអនុវត្ត | |